# ការសិក្សាពីធនធានជីវសាស្ត្រ

Draft

Draft

## ៥.៣ ការសិក្សាពីធនធានជីវសាស្ត្រ

តំបន់សិក្សាវាយតម្លៃលើជីវចម្រុះ របស់ក្រុមហ៊ុន Meng Xin Hong FA (Camodia) Resource Investment Co.,Ltd ស្ថិតនៅក្នុងភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប ដែលមានចម្ងាយពីភ្នំពេញប្រមាណជា ៣០០គីឡូម៉ែត្រ។ តំបន់គម្រោងមានផ្ទៃដីសរុប **៣.៦០០ហិកតា** ក្នុងនោះផ្ទៃដីដែលមានព្រៃឈើទំហំ **២.៩០៦ហិកតា** ដែលត្រូវធ្វើការដាក់តាំងឡូត៍គំរូសិក្សាលើសារព័ន្ធរុក្ខជាតិរួមមានកូនដំណុះ កូនឈើ និងដើមឈើ។ តាមផែនទីទីតាំងភូមិសាស្ត្រដែលផ្តល់ឲ្យ ដោយក្រុមហ៊ុនបង្ហាញថានៅទីតាំងគម្រោងអាចនឹងនៅសេសសល់នូវគ្រាប់មីនមិនទាន់ផ្ទុះខ្លះ ដែលបន្សល់ទុកពីសម័យសង្គ្រាម។

ប៉ុន្តែបច្ចុប្បន្នដោយសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិ រួមជាមួយនឹងការលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងទី៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយលើកស្ទួយវិស័យ កសិ-ឧស្សាហកម្ម និងកសិកម្ម។ ការផ្តល់ដីព្រៃឈើសម្រាប់ធ្វើកសិ-ឧស្សាហកម្ម និងកសិកម្ម ទាមទារឲ្យមានការសិក្សាវាយតម្លៃជាមុន ដើម្បីប្រាកដថារាល់ដំណើរការអភិវឌ្ឍន៍ត្រូវបានកាត់បន្ថយ និងដោះស្រាយនូវបញ្ហាប៉ះពាល់បរិស្ថាន និង សង្គម។ ប៉ុន្តែក្នុងជំពូកនេះគឺផ្តោតសំខាន់ទៅលើការសិក្សា ជីវចម្រុះក្នុងតំបន់គម្រោងដែលរួមមានរុក្ខជាតិ និងសត្វព្រៃ (ថនិកសត្វ បក្សី ល្មូន និងមច្ឆជាតិជាដើម)។

ការសិក្សានេះមានគោលបំណង៖ **ទី១)** វាយតម្លៃអំពីស្ថានភាពប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់គម្រោងរួមមានវត្តមាននានាភាព នៃសារព័ន្ធរុក្ខជាតិទាំងក្នុងបរិវេណដី ដែលក្រុមហ៊ុននឹងធ្វើការអភិវឌ្ឍ និងតំបន់ទ្រនាប់ជងអូរ ព្រមទាំងបង្ហាញនូវប្រភេទរុក្ខជាតិដែលមានដោយកម្រ ជិតផុតពូជ និងរងការគំរាមកំហែងត្រូវបានការពារដោយច្បាប់ និងកំណត់ក្នុងបញ្ជីក្រហម (**IUCN Red list**) ។ **ទី២)** ធ្វើការប៉ាន់ស្មានលើនានាភាពនៃរុក្ខជាតិ ដង់ស៊ីតេ មាឌឈើ ជីវម៉ាស់លើដី ក្រោមដី និងជលស្តុករបស់កាបូន ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ **ទី៣)** វាយតម្លៃលើតម្លៃប្រើប្រាស់ដោយផ្ទាល់នៃព្រៃឈើក្នុងទីតាំងគម្រោង។

### ៥.៣.១ ការសិក្សាអំពីធនធានព្រៃឈើ

#### ៥.៣.១.១ វិធីសាស្ត្រសិក្សាធនធានព្រៃឈើ

**ក. ការកំណត់ចំនួនឡូត៍-អនុឡូត៍គំរូ**

ការកំណត់ចំនួនឡូត៍-អនុឡូត៍គំរូ គឺផ្អែកលើរូបមន្តជ្រើសរើសចំនួនសំណាក តាមគោលការណ៍ណែនាំសម្រាប់វាយតម្លៃជីវម៉ាស់ព្រៃឈើរបស់រដ្ឋបាលព្រៃឈើ និង អង្គការ Winrock។ តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្របានបង្ហាញថា ទីតាំងគម្រោងមានប្រភេទព្រៃបីប្រភេទ

រួមមានព្រៃស្រោងទំហំ **៦៣២ហិកតា** ព្រៃពាក់កណ្តាលស្រោង **៣១ហិកតា** និងព្រៃល្បោះទំហំ **២.២៤៣ហិកតា** និងដីពុំមានគម្របព្រៃឈើទំហំ **៦៩៤ហិកតា**។ ដូច្នេះការកំណត់ចំនួនឡូត៍ ត្រូវបានគណនាទៅតាមទំហំនៃប្រភេទព្រៃនីមួយៗដែលទំហំប្រភេទព្រៃនីមួយៗ ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ របស់រដ្ឋបាលព្រៃឈើជាមូលដ្ឋាន។

ការសិក្សាលើសារព័ន្ធរុក្ខជាតិក្នុងតំបន់គម្រោងនេះបានកំណត់យកឡូត៍អនុឡូត៍គំរូចំនួន ១៣ឡូត៍មកសិក្សាក្នុងកំរិតលម្អៀង ១០% ដែលនឹងដាក់តាំងទៅតាមប្រភេទព្រៃដូចខាងក្រោម៖

តារាង៥.១៨៖ ឡូត៍-អនុឡូត៍គំរូសម្រាប់សិក្សាសារព័ន្ធរុក្ខជាតិ

| ល.រ | ឡូត៍-អនុឡូត៍គំរូ | x | y | សំគាល់ |
|---|---|---|---|---|
| 1 | Plot 1 | 440987 | 1486346 | ព្រៃស្រោង |
| 2 | Plot 2 | 441760 | 1486475 | ព្រៃស្រោង |
| 3 | Plot 3 | 440746 | 1489580 | ព្រៃស្រោង |
| 4 | Plot 4 | 441357 | 1489580 | ព្រៃស្រោង |
| 5 | Plot 5 | 443175 | 1489564 | ព្រៃស្រោង |
| 6 | Plot 6 | 443208 | 1488856 | ព្រៃស្រោង |
| 7 | Plot 7 | 438832 | 1487311 | ព្រៃល្បោះ |
| 8 | Plot 8 | 438767 | 1486523 | ព្រៃល្បោះ |
| 9 | Plot 9 | 440810 | 1487778 | ព្រៃល្បោះ |
| 10 | Plot 10 | 441727 | 1487714 | ព្រៃល្បោះ |
| 11 | Plot 11 | 442484 | 1485542 | ព្រៃល្បោះ |
| 12 | Plot 12 | 443336 | 1484898 | ព្រៃល្បោះ |
| 13 | Plot 13 | 440762 | 1485188 | ព្រៃល្បោះ |

Draft




| ឡូត៍-អនុឡូត៍ | x | y | សំគាល់ |
|---|---|---|---|
| Plot 1 | 440987 | 1486346 | EF |
| Plot 2 | 441760 | 1486475 | EF |
| Plot 3 | 440746 | 1489580 | EF |
| Plot 4 | 441357 | 1489580 | EF |
| Plot 5 | 443175 | 1489564 | EF |
| Plot 6 | 443208 | 1488856 | EF |
| Plot 7 | 438832 | 1487311 | DF |
| Plot 8 | 438767 | 1486523 | DF |
| Plot 9 | 440810 | 1487778 | DF |
| Plot 10 | 441727 | 1487714 | DF |
| Plot 11 | 442484 | 1485542 | DF |
| Plot 12 | 443336 | 1484898 | DF |
| Plot 13 | 440762 | 1485188 | DF |

រូបភាព ៥.១៩៖ បង្ហាញទីតាំងឡូត៍ អនុឡូត៍គំរូសិក្សាសារព័ន្ធរុក្ខជាតិក្នុងតំបន់គម្រោង

## ខ. ការរៀបចំឡូត៍-អនុឡូត៍គំរូ

សារព័ន្ធរុក្ខជាតិត្រូវបានសិក្សានៅក្នុងឡូត៍ទំហំ ១៥០០ម៉ែត្រការេ (៣០ម x ៥០ម) និងមានអនុឡូត៍តូចៗ ចំនួន ០៤ ទៀតដូចបានពិពណ៌នាក្នុងតារាងខាងក្រោមៈ

តារាង៥.១៩ៈ ការបរិយាយនៃការរៀបចំឡូត៍-អនុឡូត៍គំរូ

| ល.រ | ឡូត៍-អនុឡូត៍ | ទំហំ (ម៉ែត្រការេ) | ការពិពណ៌នា |
|---|---|---|---|
| ១ | ២ម×២ម | ៤ | សិក្សាលើកូនដំណុះដែលកំពស់ទាបជាង ១ម រាប់បញ្ចូលទាំង ចុល្លព្រឹក្ស តិណទេស វល្លិ៍ ពពួកស្បូវ និងពពួកស្មៅជាដើម។ |
| ២ | ៥ម×៥ម | ២៥ | សិក្សាលើកូនឈើដែលកំពស់ពី ១-៤ម និងអង្កត់ផ្ចិតតូចជាង ៥ស.ម |
| ៣ | ១០ម×១០ម | ១០០ | សិក្សាលើឈើដែលមានអង្កត់ផ្ចិតពី ៥-១៥ស.ម |
| ៤ | ១៥ម×៣០ម | ៤៥០ | សិក្សាលើឈើដែលមានអង្កត់ផ្ចិតពី ១៥-៣០ស.ម |
| ៥ | ៣០ម×៥០ម | ១៥០០ | សិក្សាលើឈើដែលអង្កត់ផ្ចិតធំជាង ៣០ស.ម ឡើងទៅ |

ប្រភពៈ អង្គការ FAO សហការជាមួយរដ្ឋបាលព្រៃឈើ ឆ្នាំ២០១៣

Draft




រូបភាព ៥.១៥ៈ ប្លង់ឡូត៍-អនុឡូត៍គំរូសម្រាប់សិក្សាសារព័ន្ធរុក្ខជាតិ

## គ. ការវាស់អង្កត់ផ្ចិតដើមឈើ

គោលការណ៍សម្រាប់ឈើពាណិជ្ជកម្មដែលមានអង្កត់ផ្ចិតធំជាង ៥ស.ម ចំណុចវាស់អង្កត់ផ្ចិតគឺនៅកំពស់ ១,៣ម៉ែត្រ ពីនីវូដី ប៉ុន្តែវាអាស្រ័យទៅតាមស្ថានភាពដី និងលក្ខណៈរបស់ដើមឈើ ។ ដូច្នេះរបៀបវាស់អង្កត់ផ្ចិតគឺដូចរូបខាងក្រោម៖




ករណីចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ ១,៣ម៉ែត្រ ពីនីវូដីចំពីលើជំពាម នោះចំណុចវាស់អង្កត់ផ្ចិតត្រូវធ្វើការវាស់វែងចំនួន០២លើក និងគិតជាឈើចំនួន០២ដើម។ ករណីដើមឈើមានព្រឹងចំណុចវាស់អង្កត់ផ្ចិតត្រូវរំកិលទៅផ្នែកខាងលើព្រឹងប្រវែង៦៥សង់ទីម៉ែត្រ។




Draft

## ឃ. ការកត់ត្រាទិន្នន័យ

ក្នុងការកត់ត្រាទិន្នន័យដើមឈើ គឺក្រុមការងារនឹងប្រើប្រាស់ក្រដាស់កត់ត្រាទិន្នន័យដែលបានរៀបចំរួចជាស្រេច ដែលមានកំណត់នូវប៉ារ៉ាម៉ែត្រឈើ ទៅតាមទំហំឡូត៏អនុឡូត៏គំរូរួចជាស្រេច ដូចជាប្រភេទឈើ ចំនួនដើមឈើ និង អង្កត់ផ្ចិតឈើ (ករណីរអង្កត់ផ្ចិតធំជាង ៥ស.ម) ។ ដោយឡែកកំពស់ឈើឈរ ក្រុមការងារពុំបានវាស់នោះទេដោយសារ ក្នុងព្រៃក្រាស់ដូចជាស្រោង និងពាក់កណ្ដាលស្រោងមានភាពលំបាកក្នុងការប្រើប្រាស់ឧបករណ៍វាស់។ សារព័ន្ធរុក្ខជាតិ ដែលនឹងត្រូវកត់ត្រារួមមានចុល្លព្រឹក្ស តិណទេស បណ្ដូងជាតិ គុម្ពព្រឹក្ស និងដើមឈើរាប់បញ្ចូលទាំងឈើពាណិជ្ជកម្ម និងឈើមិនមែនពាណិជ្ជកម្ម។

### ៥.៣.១.២ ដំណើរការវិភាគទិន្នន័យ

**ក. វិធានការគណនាមាឌឈើ**

ការកំណត់មាឌឈើឈរដោយប្រើសមីការមាឌ តាមលំដាប់ថ្នាក់អង្កត់ផ្ចិតតាមប្រភេទព្រៃដូចខាងក្រោម:

**ប្រភេទព្រៃស្រោង**

**ប្រភេទឈើ** Dipterocarp

<15ស.ម មាឌ = $0.022 + 3.4 D^2$

15ស.ម+ មាឌ = $0.015 + 2.137 D^2 + 0.513 D^{2*}L$

ប្រភេទឈើ Non-dipterocarp

<30ស.ម មាឌ = $0.03 + 2.8 D^2$

30ស.ម+ មាឌ = $-0.0023 + 2.947D^2 + 0.262D^{2*}L$

**ប្រភេទព្រៃល្បោះ**

ប្រភេទឈើ Dipterocarp

<15ស.ម មាឌ = $0.00849 + 4.097 D^2$

15ស.ម+ មាឌ = $-0.031 + 4.637D^2 + 0.135 D^{2*}L$

ប្រភេទឈើ Non-dipterocarp

<15ស.ម មាឌ = $0.03 + 3.3 D^2$

15-30ស.ម មាឌ = $0.03 + 3.55 D^2$

30ស.ម+ មាឌ = $-0.285 + 4.782 D^2 + 0.269 D^{2*}L$

(ប្រភព៖ រដ្ឋបាលព្រៃឈើ, ២០១០)

Draft

**ខ. ការប៉ាន់ស្មានជីវម៉ាស់ឈើ និងកាបូន**

ដើម្បីប៉ាន់ស្មានបរិមាណជីវម៉ាស់ និងកាបូនក្នុងតំបន់សិក្សាគឺប្រើប្រាស់វិធីសាស្ត្រគណនា ជីវម៉ាស់លើដី តាមសមីការជីវម៉ាស់លើដី (AGB) ដែលត្រូវបានរៀបចំដោយអង្គការ Winrock (Sarah et al., 2009) ។ កាបូន (t/ha) នឹងត្រូវបានគណនាក្នុងដើមឈើមួយដើមៗ បន្ទាប់មកធ្វើការប៉ាន់ស្មានគិតជាមធ្យមក្នុងផ្ទៃដីមួយហិកតា ។

**ជីវម៉ាស់លើដី**

$$AGB = WD*\exp(-1.499+2.148*\ln(dbh)+0.207*(\ln(dbh)^2)-0.0281*(\ln(dbh))^3)$$

ដែល៖ AGB = Above Ground Biomass (ជីវម៉ាស់លើដី (គ.ក្រ)),

WD = Wood Density (ដង់ស៊ីតេឈើ (ក្រ/ស.ម³),

dbh = Diameter at breast height

(អង្កត់ផ្ចិតកំពស់ទ្រូង ១,៣ម៉ែត្រពីនីវ៉ូដី (គិតជាស.ម))

## ជីវម៉ាស់ក្រោមដី

ជាទូទៅជីវម៉ាសក្រោមដីស្មើនឹង ៣០% នៃជីវម៉ាស់លើដី (យោងតាម Brown, 1998 និងអង្គការ FAO)

BGB = AGB * 30% (BGB =Bellow Ground Biomass)

## ការគណនាកាបូន

C = WB * $r_c$ (ដែល C = Carbon, WB = Wood Biomass, $r_c$= Carbon stock value ($r_c$=50%))

### គ. ការគណនា Standard Error

ការគណនាកម្រិតលំអៀង (Standard Error (S.E)) គឺជាផលធៀបរវាងកម្រិតប្រែប្រួល (Standard deviation(S.D)) នឹងឬសការេនៃចំនួនឡូត៍-អនុឡូត៍សរុបដែលបានដាក់តាំងសិក្សាលើសារព័ន្ធរុក្ខជាតិ។

លទ្ធផលនៃការវិភាគគឺតំលៃមធ្យម ±S.E ដែលមានគម្លាតពី S.E មានតម្លៃទាបជាងមធ្យមទៅ S.E មានតម្លៃធំជាងមធ្យម។

$S.E = \frac{S.D}{\sqrt{n}}$ ដែល S.E = Standard Error(កម្រិតលំអៀង)

S.D = Standard Deviation(កម្រិតប្រែប្រួល)

n = ចំនួនសំណាក រឺឡូត៍ អនុឡូត៍គំរូ

### ឃ. ការគណនាកម្រិតនៃការបាត់បង់ព្រៃឈើ

អត្រានៃការបាត់បង់ព្រៃឈើ (Deforestation Rate – DR) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$DR = -\left[1 - \left(\frac{Forest\ area\ (Year\ N)}{Forest\ area\ (Year\ P)}\right)^{\frac{1}{t}}\right] \times 100$$ ដែល

DR = អត្រានៃការប្រែប្រួលប្រចាំឆ្នាំ

N = Forest area of end year

P = Forest area of start year

t = Time period, t2-t1 (year)

### ង. ក្រុមការងារសិក្សា

**១) ក្រុមសិក្សាសារព័ន្ធរុក្ខជាតិ** មានសមាជិកចំនួន ៥នាក់ ក្នុងនោះ៖
១នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផលវាស់វាប់
២នាក់ (ជំនួយការអ្នកបច្ចេកទេស) វាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និង ហៅឈ្មោះឈើ
២នាក់ (អ្នកភូមិ) ជំនួយការវាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និង ហៅឈ្មោះឈើ (ជាអ្នកស្គាល់ឈ្មោះឈើ និងការប្រើប្រាស់)

### ៥.៣.១.៣ លទ្ធផលសិក្សាស្រាវជ្រាវ

### ក. ការដាក់តាំងឡូត៍សិក្សាស្រាវជ្រាវ

ជាលទ្ធផលចុះដាក់តាំងឡូត៍-អនុឡូត៍សម្រាប់កត់ត្រាទិន្នន័យដើមឈើ នៅទីវាលជាក់ស្តែងបានចំនួន ១៣ឡូត៍-អនុឡូត៍គំរូ ដែលក្នុងនោះឡូត៍លេខ ៧ (Plot 7) និងឡូត៍លេខ ១១ (Plot 11) នៅទីវាលជាក់ស្តែងជា ប្រភេទព្រៃពាក់កណ្តាលស្រោង។ ម្យ៉ាងវិញទៀតទីតាំងឡូត៍មួយចំនួនត្រូវបានរំកិល ខណៈពេលដែលការចុះដាក់តាំងនៅទីវាល ជាក់ស្តែងក្នុងតំបន់គម្រោងត្រង់និយាមការលេខ ៥៩១៥០៣-១៥៨៦៥១៩ ជាទីតាំងចម្ការមីនដែលបន្សល់ទុកតាំងពីសម័យសង្គ្រាម (ជាអតីតជំរុំរបស់ខ្មែរក្រហម)។

ដូច្នេះ ទីតាំងឡូត៍-អនុឡូត៍ទី១ ទី២ ទី៩ និងទី១០ ត្រូវបានរំកិលទៅដាក់តាំងនៅចំនុចនិយាមការដូចបង្ហាញក្នុងផែនទី ទី៣ ដែលជាផែនទីបង្ហាញទីតាំងដាក់តាំងឡូត៍-អនុឡូត៍សិក្សាក្រោយពេលសារពើភ័ណ្ឌ (រូបភាព ៥.១៦)។

Draft




រូបភាព៥.១៦៖ ផែនទីបង្ហាញពីទីតាំងដាក់តាំងឡូត៍-អនុឡូត៍សិក្សាក្រោយពេលសារពើភ័ណ្ឌ

## ខ. ការប្រើប្រាស់ដីព្រៃ និងការប្រែប្រួលគម្របព្រៃ

នៅក្នុងតំបន់គម្រោងមានផ្ទៃដីសរុបទំហំ **៣៦០០ហិកតា** ក្នុងនោះក្រុមហ៊ុនបានសំអាតផ្ទៃដីទំហំប្រមាណជា **៥ហិកតា** សម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជាស្នាក់ការក្រុមហ៊ុន ទីតាំងខួងយករ៉ែ ទីតាំងរក្សាទុក និងប្រព័ន្ធផ្លូវ។ តាមការសង្កេតនៅទីតាំងគម្រោង ឃើញថាផ្ទៃដីមួយផ្នែកត្រូវបានកាប់រានយកដីធ្វើកសិកម្មដូចជា ធ្វើស្រែ និងដាំដំឡូងមី និងសកម្មភាពកាប់ឈើយ៉ាងអនាធិបតេយ្យផងដែរ។

ការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ របស់រដ្ឋបាលព្រៃឈើ បង្ហាញថាទីតាំងគម្រោងមានប្រភេទព្រៃចំនួន បីប្រភេទរួមមានព្រៃស្រោង ទំហំ **៦៣២ហិកតា** ព្រៃពាក់កណ្តាលស្រោងទំហំ **៣១ហិកតា** ព្រៃល្បោះទំហំ **២២៤៣ហិកតា** និងដីគ្មានគម្របព្រៃទំហំ **៦៩៤ហិកតា**។ ដោយធ្វើការគណនាលើអត្រានៃ ការបាត់បង់ព្រៃឈើគិតចាប់ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០១០ បង្ហាញថាទីតាំងគម្រោងមានអត្រាបាត់បង់ព្រៃឈើប្រចាំឆ្នាំខ្ពស់ ចន្លោះពី ១-២ភាគរយ។

## គ. ស្ថានភាពរុក្ខសាស្ត្រនៅក្នុងតំបន់សិក្សា

ការវាយតម្លៃសារព័ន្ធរុក្ខជាតិនៅក្នុងតំបន់គម្រោងនៃក្រុមហ៊ុន Meng Xin Hong FA (Cambodia) Resource Investment Co.,Ltd បានបង្ហាញថាតំបន់នេះមានវត្តមានសារព័ន្ធរុក្ខជាតិប្រមាណជា **១២៤ប្រភេទ** ដែល **១០២ប្រភេទ** ជារុក្ខជាតិឈើ និង**២២ប្រភេទ** ជារុក្ខជាតិគ្មានជាតិឈើ។ រុក្ខជាតិគ្មានជាតិឈើរួមមានពពួកមើមមានចំនួន **០៥ប្រភេទ** ពពួកវល្លិ៍មានចំនួន **១២ប្រភេទ** ស្មៅ និងព្រិចមានចំនួន **៥ប្រភេទ**។ ដោយឡែកប្រភេទឈើចំនួន **១០២ប្រភេទ** នេះមាន**៧៥ប្រភេទ** មានវត្តមានក្នុងព្រៃស្រោង ចំនួន**៣៣ប្រភេទ** មានវត្តមានក្នុងព្រៃពាក់កណ្តាលស្រោង និងចំនួន **៤០ប្រភេទ** មានវត្តមានក្នុងព្រៃល្បោះ។

តារាង ៥.២០៖ ស្ថានភាពរុក្ខសាស្ត្រក្នុងតំបន់សិក្សា

| ល.រ | ប្រភេទរុក្ខជាតិ | ពពួករុក្ខជាតិ | ចំនួនប្រភេទ |
|---|---|---|---|
| ១ | រុក្ខជាតិគ្មានជាតិឈើ | ពពួកមើម | ០៥ ប្រភេទ |
| | | ពពួកវល្លិ៍ | ១២ ប្រភេទ |
| | | ពពួលស្មៅ និងព្រិច | ០៥ ប្រភេទ |
| សរុប | | | ២២ ប្រភេទ |
| ២ | រុក្ខជាតិមានជាតិឈើ | វត្តមានក្នុងព្រៃស្រោង | ៧៥ ប្រភេទ |
| | | វត្តមានក្នុងព្រៃពាក់កណ្តាលស្រោង | ៣៣ប្រភេទ |
| | | វត្តមានក្នុងព្រៃល្បោះ | ៤០ ប្រភេទ |
| សរុប | | | ១០២ ប្រភេទ |

ប្រភេទឈើ **៣៤ប្រភេទ** ក្នុងចំណោម **១០២ប្រភេទ** ត្រូវបានការពារដោយ ប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី"ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ ប្រមូលផល" នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចាត់ទុកថាជាប្រភេទឈើមានគុណភាពរឹងមាំរួមមាន៖ ឈើប្រណិតចំនួន **៦ប្រភេទ** ឈើលេខ១ ចំនួន **១០ប្រភេទ** ឈើលេខ២ ចំនួន **៩ប្រភេទ** និង ឈើលេខ៣ ចំនួន **៩ប្រភេទ** (ឧបសម្ព័ន្ធទី១៖ *ស្តីពីប្រភេទសារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់របស់វា*)។

តាមបទពិសោធន៍របស់សហគមន៍មូលដ្ឋានលើការប្រើប្រាស់រុក្ខជាតិ ឯកសារស្រាវជ្រាវរបស់ឌីផុន ប៉ូលីន (២០០០)[1] និងមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ(២០០៦)[2] បានបង្ហាញថារុក្ខជាតិចំនួន **៣០ប្រភេទ** អាចបរិភោគបាន និងប្រើប្រាស់ជាលក្ខណៈប្រពៃណីដូចជាបរិភោគផ្លែទុំ រឺ គ្រាប់ និងស្លឹក រឺ ត្រួយធ្វើជាបន្លែ។ លើសពីនេះទៀតមានរុក្ខជាតិចំនួន **៥២ ប្រភេទ** ក្នុងចំណោមរុក្ខជាតិចំនួន **១២៤ប្រភេទ** គឺជាប្រភេទរុក្ខជាតិឱសថដ៏សំខាន់ដែលប្រជាជនមូលដ្ឋានតែងតែយកដើម ផ្លែ មើម សំបក ឬស ស្លឹក និងគ្រាប់ មកប្រើប្រាស់ធ្វើជាឱសថសម្រាប់ព្យាបាលជំងឺផ្សេងៗផងដែរ (*ឧបសម្ព័ន្ធទី ១ និង ទី២*)។

### គ.១ រុក្ខជាតិក្នុងព្រៃស្រោង និងពាក់កណ្តាលស្រោង

ការសិក្សាក្នុងស្រទាប់ព្រៃស្រោងបានដាក់តាំងឡូត៍គំរូ និងអនុឡូត៍ បានជួបប្រទះនូវសារព័ន្ធរុក្ខជាតិចំនួន **៨២ប្រភេទ** ក្នុងនោះមានកូនដំណុះរុក្ខជាតិដែលមានកំពស់ទាបជាង១ម មានចំនួន **២១ប្រភេទឈើ** កូនឈើដែលមានកំពស់ចាប់ពី១ម រហូតដល់អង្កត់ផ្ចិតតូចជាង ៥សង់ទីម៉ែត្រមានចំនួន **២២ប្រភេទឈើ** ។ នៅក្នុងចំនោមប្រភេទឈើ ៨២ប្រភេទ មានប្រភេទឈើប្រណិតចំនួន **៥ប្រភេទ** ប្រភេទឈើលេខ១ ចំនួន **៨ប្រភេទ** ប្រភេទឈើលេខ២ ចំនួន **៥ប្រភេទ** ប្រភេទឈើលេខ៣ ចំនួន **៨ប្រភេទ** ប្រភេទឈើក្រៅលំដាប់ថ្នាក់ចំនួន **៥១ប្រភេទ** និងពពួកវល្លិ៍ មើម ស្មៅមានចំនួន **៧ប្រភេទ** (ឧបសម្ព័ន្ធ ៣.១)។

តារាង ៥.២១៖ ប្រភេទឈើក្នុងព្រៃស្រោង និងពាក់កណ្តាលស្រោង

| ប្រភេទរុក្ខជាតិ | ប្រភេទឈើ | ចំនួន |
|---|---|---|
| រុក្ខជាតិក្នុងព្រៃស្រោង និងពាក់កណ្តាលស្រោង | ឈើប្រណិត | ៥ ប្រភេទ |
| | ឈើលេខ១ | ៨ ប្រភេទ |
| | ឈើលេខ២ | ៥ ប្រភេទ |
| | ឈើលេខ៣ | ៨ ប្រភេទ |

[1] ឌីផុន ប៉ូលីន (២០០០) ស្តីពី "រុក្ខជាតិប្រើប្រាស់នៅកម្ពុជា"

[2] មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ (២០០៦) រុក្ខជាតិឱសថកម្ពុជា។ ក្រសួងសុខាភិបាល។



Draft

| | | |
|---|---|---|
| | ឈើក្រៅលំដាប់ថ្នាក់ | ៥១ ប្រភេទ |
| | វល្លិ៍ មើម ស្មៅ | ៧ប្រភេទ |
| សរុប | | ៨២ ប្រភេទ |

នៅក្នុងប្រភេទព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ក្រុមការងារបានជួបប្រទះនូវដើមឈើដែលមានអង្កត់ផ្ចិត ចាប់ពី ៩៥-១៥០ស.ម មានដូចជាៈ ដើមស្រឡៅ (Lagerstroemia calyculata Kurz) ដើមក្រឡាញ់ (Dialium cochinchinensis, Pierre) ដើមព្រីង (Eugenia spp.) ដើមទ្រាស (Erythropheum succirubrum) ដើមចំបក់ (Irvingia malayana Oliv,ex Benn.) ដើមស្នួល (Dalbergianigreseens Kurzvar) ដើមត្របែក (Peltophorum dasyrrhachis Kurz, var) ដើមពពួលថ្ម (Vitex pinnata) និងដើមព្រះញ្ញៅ (Terminalia triptera)។

## គ.២ រុក្ខជាតិក្នុងព្រៃល្បោះ

ការសិក្សាក្នុងស្រទាប់ព្រៃល្បោះបានដាក់តាំងឡូត៏គំរូ និងអនុឡូត៏ បានជួបប្រទះនូវសារព័ន្ធរុក្ខជាតិចំនួន **៥៣ប្រភេទ** ក្នុងនោះមានកូនដំណុះរុក្ខជាតិដែលមានកំពស់ទាបជាង១ម មានចំនួន **១០ប្រភេទឈើ** កូនឈើដែលមានកំពស់ចាប់ពី១ម រហូតដល់អង្កត់ផ្ចិតតូចជាង ៥សង់ទីម៉ែត្រមានចំនួន **៧ប្រភេទឈើ**។ នៅក្នុងចំនោមប្រភេទឈើ **៥៣ប្រភេទ** មានប្រភេទឈើប្រណិតចំនួន **២ប្រភេទ** ប្រភេទឈើលេខ១ចំនួន **៥ប្រភេទ** ប្រភេទឈើលេខ២ចំនួន **៥ប្រភេទ** ប្រភេទឈើលេខ៣ចំនួន **៥ប្រភេទ** ប្រភេទឈើក្រៅលំដាប់ថ្នាក់ចំនួន **២៣ប្រភេទ** និងពពួកវល្លិ៍ មើម ស្មៅមានចំនួន **១៣ប្រភេទ** (ឧបសម្ព័ន្ធ ៥.៣)។ នៅក្នុងស្រទាប់ល្បោះបានជួបប្រទះនូវដើមឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៨០ស.ម មានដូចជាៈ ដើមផ្ចឹក (Shorea obtuse, Woll.) ដើមសុក្រំ (Xylia dolabriformis, Benth) ដើមកកោះ (Sindora cochinchinensis, Baill.) ដើមពពួលទឹក (Vitex glabrata) ដើមត្បែង (Dipterocarpus obtusifolius, Teysm.) ដើមត្រឡាត់ (Vatica philastreana, Pierre) ដើមពង្រ (Schleicheria oleosa (Lour.) Oken) ដើមស្នួល (Dalbergianigreseens Kurzvar) ដើមចំបក់ (Irvingia malayana Oliv,ex Benn.) និងដើមទ្រាស (Erythropheum succirubrum) ។

តារាង ៥.២២៖ ប្រភេទឈើក្នុងព្រៃល្បោះ

| ប្រភេទរុក្ខជាតិ | ប្រភេទឈើ | ចំនួន |
|---|---|---|
| រុក្ខជាតិក្នុងព្រៃល្បោះ | ឈើប្រណិត | ២ ប្រភេទ |
| | ឈើលេខ១ | ៥ ប្រភេទ |
| | ឈើលេខ២ | ៥ ប្រភេទ |
| | ឈើលេខ៣ | ៥ ប្រភេទ |

| | | |
|---|---|---|
| | ឈើក្រៅលំដាប់ថ្នាក់ | ២៣ ប្រភេទ |
| | វល្លិ មើម ស្មៅ | ១៣ប្រភេទ |
| សរុប | | ៥៣ ប្រភេទ |

ខាងក្រោមនេះជាប្រភេទដើមឈើធំៗ ដែលមានវត្តមានក្នុងតំបន់គម្រោង



រូបភាព៥.១៧៖ ដើមសុក្រំ
ចំណុចនិយាមកា (៤៣៨៦៨៩-១៤៨៦៦០៩)



រូបភាព៥.១៨៖ ដើមចំបក់
ចំណុចនិយាមកា (៤៣៨៧០៧-១៤៨៦៦៥២)



រូបភាព៥.១៩៖ ដើមធ្នង់
ចំណុចនិយាមកា (៤៤០៥៣១-១៤៨៦០១១)



រូបភាព៥.២០៖ ដើមស្រឡៅ
ចំណុចនិយាមកា (៤៤០៧១៥-១៤៨៧១៦៤)



រូបភាព៥.២១៖ ដើមក្រឡាញ់
ចំណុចនិយាមកា (៤៤៣០០២-១៤៨៩៣២៤)



រូបភាព៥.២២៖ ដើមធ្នឹក
ចំណុចនិយាមកា (៤៤០៤១៣-១៤៨៦៥១៧)

ក្រៅពីនេះក្រុមការងារបានសង្កេតឃើញថា ក្នុងតំបន់សិក្សានេះក៏មានប្រភេទអនុផលព្រៃឈើមួយចំនួនដូចជា ផ្សិតឈើ ផ្លែឈើព្រៃ និងអ័រគីដេរ ដែលប្រជាជនមូលដ្ឋានអាចចូលទៅក្នុងព្រៃប្រមូលយកមកប្រើប្រាស់ និងលក់ដូរ សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ និងតាំងលំអរនៅតាមផ្ទះផងដែរ។



រូបភាព៥.២៣៖ រុក្ខជាតិលំអរ(អ័រគីដេ)
(៤៤២៨១៥-១៤៨៩៥៦២)



រូបភាព៤.២៤៖ ផ្លែឈើព្រៃ
(៤៤២៧៤៣-១៤៨៨៧១៥)



រូបភាព៥.២៥៖ ផ្សិតឈើ
(៤៤២២២០-១៤៨៤៦៥៤)

## គ.៣ ប្រភេទឈើសំខាន់ៗការពារដោយច្បាប់

ប្រភេទឈើសំខាន់ៗចំនួន **៧ប្រភេទ** ត្រូវបានចាត់ទុកជាប្រភេទដែលជិតផុតពូជ និងរងការគំរាមកំហែង នៅក្នុងប្រទេសកម្ពុជា និងលើសកលលោក មានដូចជាដើមបេង ផ្ដៀក និងឈើទាលទឹក ក្នុងនោះមានប្រភេទឈើចំនួន **៣ប្រភេទ** ជាប្រភេទជិតផុតពូជ និង៣ប្រភេទទៀតជាប្រភេទរងការគំរាមកំហែង។ ប្រភេទឈើចំនួន **៥ប្រភេទ** ក្នុងចំនោមប្រភេទឈើ **១០ ប្រភេទ** ដែលបង្ហាញក្នុងតារាង៥.១៧ ខាងក្រោមជាប្រភេទត្រូវបានការពារ ដោយប្រកាសលេខ ០៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឧបសម្ព័ន្ធទី២ ស្ដីពីប្រភេទរុក្ខជាតិមានដោយកម្រ ដែលរួមមាន បេង ត្រយឹង ធ្នង់ អង្កត់ខ្មៅ និងច្រេស។ ប្រភេទឈើទាំងនេះមានដង់ស៊ីតេ និងអត្រាបាយទាប នៅក្នុងព្រៃធម្មជាតិនៃតំបន់សិក្សាស្រាវជ្រាវ ដែលអាចនិយាយថា បច្ចុប្បន្នការបន្តពូជក្នុងព្រៃធម្មជាតិមានសក្ដានុពលទាប ដូច្នេះវាមានតម្លៃផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ចសង្គម វប្បធម៌ និងអាចប្រឈមមុខចំពោះការគំរាមកំហែង ឬ ផុតពូជ បើសិនជា ពុំមានវិធានការសមស្របណាមួយអនុវត្តន៍ ទាន់ពេលវេលា។

ជាងនេះទៀតប្រភេទឈើ **៦ប្រភេទ** ផ្សេងទៀតក្នុងតំបន់សិក្សាស្រាវជ្រាវដូចជា បេង (Afzelia xylocarpa, (Kurz) Craib.) ផ្ដៀក (Anisopteracostata Korth) ឈើទាលទឹក (DipterocarpusalatusRoxb.) ត្បែង (Dipterocarpus obtusifolius, Teysm) ត្រាច (Dipterocarpus intricatus, Dyer) និងខ្លង (Dipterocarpus tuberculatus,Roxb.) ត្រូវបានកំណត់នៅក្នុងបញ្ជី IUCN Red List ជាប្រភេទជិតផុតពូជ ប្រភេទងាយរងគ្រោះ និងប្រភេទមានដោយបង្គួរជាសកល។

តារាង៥.២៣៖ ប្រភេទឈើចាំបាច់ត្រូវការពារក្នុងប្រទេសកម្ពុជា

| ល.រ | ប្រភេទ | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ | ការពារដោយប្រក/ក.ស.ក | កម្រិតគំរាមកំហែងក្នុងកម្ពុជា(១) | បញ្ជីក្រហម IUCN(២) |
|---|---|---|---|---|---|---|
| ១ | បេង | Afzelia xylocarpa, (Kurz) Craib. | ប្រណិត | ✓ | ៥ | EN |
| ២ | ត្រយឹង | Diospyros helferi, C.B.Clarke | ប្រណិត | ✓ | ៤ | |
| ៣ | ធ្នង់ | Pterocarpus pedatus, Pierre | ប្រណិត | ✓ | ៤ | |
| ៤ | អង្កត់ខ្មៅ | Diospyros bejaudii, Lecomte. | ប្រណិត | ✓ | ៤ | |
| ៥ | ច្រេស | Albizia lebbeck, (L) Benth. | ប្រណិត | ✓ | ៣ | |
| ៦ | ផ្ដៀក | AnisopteracostataKorth | លេខ ២ | ✓ | ២ | EN |
| ៧ | ឈើទាលទឹក | DipterocarpusalatusRoxb. | លេខ ២ | ✓ | ២ | EN |
| ៨ | ត្រាច | Dipterocarpus intricatus, Dyer | លេខ ២ | ✓ | | LC |
| ៩ | ខ្លង | Dipterocarpus tuberculatus, Roxb. | លេខ ២ | ✓ | | LC |
| ១០ | ត្បែង | Dipterocarpus obtusifolius, Teysm | លេខ ២ | ✓ | | LC |

**កំណត់ចំណាំ៖** [1]កម្រិតនៃការគំរាមកំហែង៖ ៥ = ជិតផុតពូជបំផុត, ៤ = ជិតផុតពូជ, ១-៣ = រងគំរាមកំហែង

[2]IUCN Red list:

EN=Endangered (ជិតផុតពូជ)៖ កំពុងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជិតផុតពូជនៅក្នុងព្រៃ

VU=Vulnerable (ងាយរងគ្រោះ)៖ កំពុងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជិតផុតពូជនៅក្នុងព្រៃ

LC= Least Concern (ប្រភេទមានដោយបង្គួរ)

### ឃ. ដង់ស៊ីតេ និងមាឌឈើតាមប្រភេទព្រៃនីមួយៗ

តារាងទី៤.១៨ ខាងក្រោមបង្ហាញអំពីលទ្ធផលនៃការប៉ាន់ស្មានដង់ស៊ីតេឈើ និងមាឌឈើឈរក្នុងផ្ទៃដី១ហិកតា។ ការធ្វើចំណាត់ថ្នាក់ប្រភេទឈើខាងក្រោមនេះគឺផ្អែកលើឧបសម្ព័ន្ធទី២ ស្តីពីប្រភេទឈើពាណិជ្ជកម្ម ក្នុងប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពី "ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ប្រមូលផល" របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

Draft

តារាង៥.២៤៖ ការប៉ាន់ស្មានដង់ស៊ីតេឈើ និងមាឌឈើឈរតាមប្រភេទព្រៃនីមួយៗ

| ប្រភេទឈើ | កូនឈើ និងចំណាត់ថ្នាក់អង្កត់ផ្ចិត | ព្រៃស្រោង | | ព្រៃល្បោះ | |
|---|---|---|---|---|---|
| | | ដង់ស៊ីតេ±SE. (ដ/ហ.ត) | មាឌ ±SE. (ម³/ហ.ត) | ដង់ស៊ីតេ±SE. (ដ/ហ.ត) | មាឌ ±SE. (ម³/ហ.ត) |
| | កូនដំណុះ | ៣០៩៣៨ ±៤៩៩៩ | | ៣៣០០០ ±៥៨៣១ | |
| | កូនឈើ | ៥០៥០ ±១២០៩ | | ២៥៦០ ±៨៨២ | |
| ប្រណិត | D = ៥-១៥ស.ម | ២០០ ±៤១,១៩ | ១១,៦០៩ ±២,៣២ | ១៣៣ ±៣៧,៤២ | ១០,០៥ ±៣,០៥ |
| | D = ១៥-៣០ស.ម | ៤៤ ±១០,៩១ | ៨,២០១ ±២,១១ | ៤៤ ±១២,៩៦ | ៨,៥៣២ ±២,២៩ |
| | D > ៣០ស.ម | ៧ ±០,៨៣ | ៣,២៦ ±០,៤១ | | |
| លេខ ១ | D = ៥-១៥ស.ម | ៦៦៧ ±២៨៥,៩៨ | ៤០,៦៥៩ ± ១៧,៦៩ | ៦៨០ ±១៧១,៤៦ | ៥៤,១៩៧ ± ១៧,៧៩ |
| | D = ១៥-៣០ស.ម | ៧២ ±១៣,១១ | ១៦,៣៨៦ ±៣,២៤ | ៦២ ±១៧,៧៨ | ២១,៥៦១ ±៦,៥៥ |
| | D > ៣០ស.ម | ២២ ±៥,៦៣ | ៥១,៩៩ ±២២,៥០ | ២២ ±៦,១៨ | ២៥,៨៨៤ ±១០,២៩ |
| លេខ ២ | D = ៥-១៥ស.ម | ២១៤ ±៧៦,៦២ | ១៣,០២៥ ±៤,៩៤ | ៣៤០ ±១០២,៩៦ | ៣៥,១៤៦ ± ១០,៩៧ |
| | D = ១៥-៣០ស.ម | ៥៩±១១,៨៨ | ១៥,៤៩ ±៣,៦៩ | ១៧ ±១៥,៧១ | ៥ ±៤,៨៨ |
| | D > ៣០ស.ម | | | ១០±២,៦៧ | ៦,៨៣៦ ±២,២១ |
| លេខ ៣ | D = ៥-១៥ស.ម | ៣៥៧ ±១១០,៩ | ២៤,៤៥៨ ±៨,៨០ | ២៥០ ±១០៤,៨៨ | ១៨,០៧៧ ±៦,០៧ |

| | | | | | |
|---|---|---|---|---|---|
| | D = ១៥-៣០ស.ម | ៣៥ ±៧,២ | ៥,៥១៤ ±១,២០ | ២២ ±៤,៤៤ | ៣,៨៣២ ±០,៩១ |
| | D >៣០ស.ម | ១៣ ±២,៧៥ | ៧,៩៦៩ ±១,៧៥ | | |
| ព្រៃលំដាប់ | D = ៥-១៥ស.ម | ១២៣៨±២២១,១៥ | ៧០,៤៧៧ ± ១១,៦ | ៧៤០ ±១៧៧,៧៦ | ៤៧,៥៥៧ ± ១២,៩៩ |
| | D = ១៥-៣០ស.ម | ១០៦ ±៣១,៩១ | ១៨,១៩៩ ±៥,៤៤ | ៧២ ±១៩,៣៧ | ១៥,០៤៥ ±៤,០៦ |
| | D >៣០ស.ម | ១៣ ±២,៨២ | ១១,២៩២ ±៤,០២ | ៨ ±១,៣៣ | ៦,៨១៧ ±២,០២ |

ចំណាំ៖D (dbh): Diameter (diameter at breast height) (អង្កត់ផ្ចិតកំពស់ត្រឹមទ្រូង)

SE.: Standard Error (កំរិតលំអៀង)

### ឃ.១ ដង់ស៊ីតេ និងមាឌឈើក្នុងព្រៃស្រោង

ព្រៃស្រោងមានកូនដំណុះឈើ ដែលមានកំពស់ទាបជាង១ម មានដង់ស៊ីតេជាមធ្យម ៣០៩៣៨ដើម/ហិកតា ±៩៩៩៩ កូនឈើមានកំពស់ខ្ពស់ជាង១ម៉ែត្រ រហូតដល់អង្កត់ផ្ចិតតូចជាង ៥ស.ម មានដង់ស៊ីតេជាមធ្យម ៥០៥០ដើម/ហិកតា ±១២០៩។

- **ភេទឈើប្រណិត**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ២០០ដើម/ហ.ត ±៥១,១៩ ស្មើនឹងមាឌ ១១,៦០៩ ម$^៣$/ហ.ត ±២,១១
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ៥៤ដើម/ហ.ត ±១០,៩១ ស្មើនឹងមាឌ ៨,២០១ ម$^៣$/ហ.ត ±២,៧៤
- អង្កត់ផ្ចិត D>៣០ស.ម មានដង់ស៊ីតេ ៧ដើម/ហ.ត ±០,៨៣ ស្មើនឹងមាឌ ៣,២៦ម$^៣$/ហ.ត ±០,៨១

- **ប្រភេទឈើលេខ១**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ៦៦៧ដើម/ហ.ត ±២៨៥,៩៨ ស្មើនឹងមាឌ ៥០,៦៥៩ ម$^៣$/ហ.ត ±១៧,៦៩
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ៧២ដើម/ហ.ត ±១៣,១១ ស្មើនឹងមាឌ ១៦,៣៨៦ម$^៣$/ហ.ត ±៣,២៤
- អង្កត់ផ្ចិត D>៣០ស.ម មានដង់ស៊ីតេ ២២ដើម/ហ.ត ±៥,៦៣ ស្មើនឹងមាឌ ៥១,៩៩ម$^៣$/ហ.ត ±២២,៥

- **ប្រភេទឈើលេខ ២**

- អង្កត់ផ្ចិត **D=**៥-១៥ស.ម មានដង់ស៊ីតេ ២១៤ដើម/ហ.ត ±៧៦,៦២ ស្មើនឹងមាឌ ១៣,០២៥ ម$^{៣}$/ហ.ត ±៤,៩៤

- អង្កត់ផ្ចិត **D=**១៥-៣០ស.ម មានដង់ស៊ីតេ ៥៩ដើម/ហ.ត ±១១,៨៨ ស្មើនឹងមាឌ ១៤,៥៩ ម$^{៣}$/ហ.ត ±៣,៦៩

- **ប្រភេទឈើលេខ ៣**

- អង្កត់ផ្ចិត **D=**៥-១៥ស.ម មានដង់ស៊ីតេ ៣៥៧ដើម/ហ.ត ±១១០,៩ ស្មើនឹងមាឌ ២៤,៥៥៨ ម$^{៣}$/ហ.ត ±៨,៨០

- អង្កត់ផ្ចិត **D=**១៥-៣០ស.ម មានដង់ស៊ីតេ ៣៥ដើម/ហ.ត ±៧,២ ស្មើនឹងមាឌ ៥,៥១៤ម$^{៣}$/ហ.ត ±១,២០

- អង្កត់ផ្ចិត **D>**៣០ស.ម មានដង់ស៊ីតេ ១៣ដើម/ហ.ត ±២,៧៥ ស្មើនឹងមាឌ ៧,៩៦៩ម$^{៣}$/ហ.ត ±១,៧៥

- **ប្រភេទឈើក្រៅលំដាប់ថ្នាក់**

- អង្កត់ផ្ចិត **D=**៥-១៥ស.ម មានដង់ស៊ីតេ ១២៣៨ដើម/ហ.ត ±២២១,១៥ ស្មើនឹងមាឌ ៧០,៤៧៧ម$^{៣}$/ហ.ត ±១១,៦

- អង្កត់ផ្ចិត **D=**១៥-៣០ស.ម មានដង់ស៊ីតេ ១០៦ដើម/ហ.ត ±៣១,៩១ ស្មើនឹងមាឌ ១៨,១៩៩ ម$^{៣}$/ហ.ត ±៥,៤៤

- អង្កត់ផ្ចិត **D>**៣០ស.ម មានដង់ស៊ីតេ ១៣ដើម/ហ.ត ±២,៨២ ស្មើនឹងមាឌ ១១,២៩២ម$^{៣}$/ហ.ត ±៤,០២

តាមរយៈលទ្ធផលសិក្សាសារព័ន្ធរុក្ខជាតិអាចវាយតំលៃជារួមបានថា ប្រភេទឈើនៅក្នុងស្រទាប់ព្រៃស្រោង មានឈើដែលមានអង្កត់ផ្ចិតចាប់ពី៥-១៥ស.ម ជាប្រភេទឈើបង្គោលមានចំនួន ៨៣,៥៧ភាគរយ ឈើដែលមានអង្កត់ផ្ចិតចាប់ពី១៥-៣០ស.ម មានចំនួន ១៤,៤៣ភាគរយ និងឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.មឡើងទៅមានចំនួន ២ភាគរយ ។

Draft

## ឃ.២ ដង់ស៊ីតេ និងមាឌឈើក្នុងព្រៃល្បោះ

ព្រៃល្បោះមានកូនដំណុះឈើដែលមានកំពស់ទាបជាង១ម មានដង់ស៊ីតេជាមធ្យម ៣៣០០០ដើម/ហិកតា±៥៨៣១ កូនឈើមានកំពស់ខ្ពស់ជាង១ម រហូតដល់អង្កត់ផ្ចិតតូចជាង៥ ស.ម មានដង់ស៊ីតេជាមធ្យម២៥៦០ដើម/ហិកតា ±៨៨២។

- **ប្រភេទឈើប្រណិត**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ១៣៣ដើម/ហ.ត ±៣៧,៤២ ស្មើនឹងមាឌ ១០,០៥ ម$^{៣}$/ហ.ត ±៣,០៥
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ៤៤ដើម/ហ.ត ±១២,៩៦ ស្មើនឹងមាឌ ៨,៥៣២ ម$^{៣}$/ហ.ត ±២,២៩

- **ប្រភេទឈើលេខ ១**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ៦៨០ដើម/ហ.ត ±១៧១,៤៧ ស្មើនឹងមាឌ ៥៤,១៩៧ ម$^{៣}$/ហ.ត ±១៧,៧៩
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ៦២ដើម/ហ.ត ±១៧,៧៨ ស្មើនឹងមាឌ ២១,៥៦១ ម$^{៣}$/ហ.ត ±៦,៥៥
- អង្កត់ផ្ចិត D>៣០ស.ម មានដង់ស៊ីតេ ២២ដើម/ហ.ត ±៦,១៨ ស្មើនឹងមាឌ ២៥,៨៨៤ម$^{៣}$/ហ.ត ±១០,២៩

- **ប្រភេទឈើលេខ ២**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ៣៤០ដើម/ហ.ត ±១០២,៩៦ ស្មើនឹងមាឌ ៣៥,១៤៦ ម$^{៣}$/ហ.ត ±១០,៩៧
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ១៧ដើម/ហ.ត ±១៥,៧១ ស្មើនឹងមាឌ ៥ម$^{៣}$/ហ.ត ±៤,៨៨
- អង្កត់ផ្ចិត D>៣០ស.ម មានដង់ស៊ីតេ ១០ដើម/ហ.ត ±២,៦៧ ស្មើនឹងមាឌ ៦,៨៣៦ម$^{៣}$/ហ.ត ±២,២១

- **ប្រភេទឈើលេខ ៣**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ២៥០ដើម/ហ.ត ±១០៤,៨៨ ស្មើនឹងមាឌ ១៨,០៧៧ម$^{៣}$/ហ.ត ±៦,០៧

Draft

- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ២២ដើម/ហ.ត ±៤,៩៩ ស្មើនឹងមាឌ ៣,៨៣២ ម³/ហ.ត ±០,៩១

- **ប្រភេទឈើក្រៅលំដាប់ថ្នាក់**

- អង្កត់ផ្ចិត D=៥-១៥ស.ម មានដង់ស៊ីតេ ៧៩០ដើម/ហ.ត ±១៧៧,៧៦ ស្មើនឹងមាឌ ៤៧,៥៥៧ ម³/ហ.ត ±១២,៩
- អង្កត់ផ្ចិត D=១៥-៣០ស.ម មានដង់ស៊ីតេ ៧២ដើម/ហ.ត ±១៩,៣៧ ស្មើនឹងមាឌ ១៥,០៩៥ ម³/ហ.ត ±៤,០៦
- អង្កត់ផ្ចិត D>៣០ស.ម មានដង់ស៊ីតេ ៨ដើម/ហ.ត ±១,៣៣ ស្មើនឹងមាឌ ៦,៩១៧ម³/ហ.ត ±២,០២

តាមរយៈលទ្ធផលសិក្សាសារពើភ័ន្ធរុក្ខជាតិអាចវាយតំលៃជារួមបានថា ប្រភេទឈើនៅក្នុងស្រទាប់ព្រៃល្បោះមានឈើដែលមានអង្កត់ផ្ចិតចាប់ពី ៥-១៥ស.ម ជាប្រភេទឈើបង្គោលមានចំនួន ៨៩,២៩ភាគរយ ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១៥-៣០ស.ម មានចំនួន ៩,០៤ភាគរយ និងឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.ម ឡើងទៅមានចំនួន ១,៦៧ភាគរយ។

លទ្ធផលនេះបានបញ្ជាក់អោយឃើញថានៅតាមប្រភេទនៃស្រទាប់ព្រៃនីមួយៗ ដែលភាគច្រើនជាប្រភេទឈើបង្គោលមានអង្កត់ផ្ចិតចាប់ពី ៥-១៥ស.ម និងឈើដែលមានអង្កត់ផ្ចិតធំជាង១៥ស.ម ឡើងទៅមានចំនួនតិចតួចបំផុត គឺមួយផ្នែកដោយសារតែការធ្វើអាជីវកម្មយ៉ាងអនាធិបតេយ្យតាមរយៈវត្តតាងដែលបន្សល់ទុកក្នុងព្រៃ មួយផ្នែកទៀតដោយសារប្រជាជនមូលដ្ឋានពួកគាត់បានកាប់រានដីយកធ្វើកសិកម្ម។ ដូច្នេះហើយទើបនៅក្នុងតំបន់សិក្សានេះ ពុំសូវជួបប្រទះនូវដើមឈើធំៗ។

**ឃ.៣ ការវាយតម្លៃឈើគុណភាពប្រភេទឈើ**

**១. ប្រភេទឈើសំណង់ និង ប្រភេទឈើកែច្នៃជាគ្រឿងសង្ហារឹម**

ដោយធ្វើការវាយតម្លៃលើគុណភាពឈើ ជាប្រភេទឈើដែលមានគុណភាពអាចវាយតម្លៃជាឈើស័ណង់ និងឈើគ្រឿងសង្ហារឹម គឺអាស្រ័យលើភាពត្រង់របស់វាចាប់ពីកំពស់ ៦ម៉ែត្រ ឡើងទៅដល់មែកអាជីវកម្ម សម្រាប់ឈើសំណង់ និងកំពស់ចាប់ពី៤ម ឡើងទៅដល់មែកអាជីវកម្មសម្រាប់ឈើគ្រឿងសង្ហារឹម។ ជាលទ្ធផលនៃការវិភាគ បង្ហាញថាប្រភេទឈើសំណង់ និងឈើដែលអាចកែច្នៃជាគ្រឿងសង្ហារឹមបានមានប្រមាណជា ៣,១៤ភាគរយ ដែលឈើអង្កត់ផ្ចិតចាប់ពី១៥-៣០ស.ម មានចំនួនតិចតួច ១,១២% និងអង្កត់ផ្ចិតធំជាង ៣០ស.ម មាន២,០២%។ ចំណែកក្នុងព្រៃល្បោះវិញ ឈើសំណង់ និងប្រភេទឈើកែច្នៃជាគ្រឿងសង្ហារឹមមានប្រមាណជា ២,២៥% ដែលឈើមានអង្កត់ផ្ចិតចាប់ពី១៥-៣០ស.ម មានចំនួន ១,១២% និងអង្កត់ផ្ចិតធំជាង ៣០ស.មមាន ១,១២%។

## ២. ប្រភេទឈើបង្គោល

ដោយឡែកការវាយតម្លៃលើប្រភេទឈើបង្គោល ជាប្រភេទឈើដែលមានអង្កត់ផ្ចិតចន្លោះពី ៥-១៥សង់ទីម៉ែត្រ អាស្រ័យលើភាពត្រង់របស់វាចាប់ពីកំពស់ ៤-៦ម៉ែត្រ ឡើងទៅដល់មែកអាជីវកម្ម។ ជារួមក្នុងប្រភេទព្រៃស្រោង លទ្ធផលនៃការវិភាគ បានបង្ហាញថាឈើបង្គោលមានប្រមាណជា ៧០,២៥% ដែលឈើមានអង្កត់ផ្ចិតចាប់ពី ៥-១៥សង់ទីម៉ែត្រ មានប្រមាណជា ៦៣% និង អង្កត់ផ្ចិតចាប់ពី ១៥-៣០សង់ទីម៉ែត្រ មាន ៧,២៥%។ ចំណែកក្នុងព្រៃល្បោះវិញ ឈើបង្គោលមានប្រមាណជា ៤៨,៧៥% ដែលឈើមានអង្កត់ផ្ចិតចាប់ពី ៥-១៥សង់ទីម៉ែត្រ មានចំនួន ៤៤,១៩% និងអង្កត់ផ្ចិតចាប់ពី ១៥-៣០សង់ទីម៉ែត្រ មានប្រមាណជា ៤,៥៦%។

## ៣. ប្រភេទអុស

ការវាយតម្លៃលើប្រភេទអុស ប្រភេទឈើដែលគ្មានគុណភាពទាំងអស់ដូចជា វៀច កោង និង ស្គមជាដើម ពោលគឺជាឈើដែលពុំអាចយកទៅកែច្នៃធ្វើអ្វីក្រៅពីឈើថាមពល។ ជារួមក្នុងប្រភេទព្រៃស្រោង លទ្ធផលនៃការវិភាគបង្ហាញថា ឈើដែលគ្មានគុណភាព រឺ អុសមានប្រមាណជា ២៦,៦២% ដែលឈើមានអង្កត់ផ្ចិតចាប់ពី ៥-១៥ **សង់ទីម៉ែត្រ** មានប្រមាណជា ២៤,៥៨% អង្កត់ផ្ចិតពី ១៥-៣០ **សង់ទីម៉ែត្រ** មាន ១,៦៨% និង អង្កត់ផ្ចិតធំជាង ៣០**សង់ទីម៉ែត្រ** មានតិចតួចបំផុត ០,៣៦%។ ដោយឡែកចំពោះប្រភេទព្រៃល្បោះវិញ មានឈើដែលគ្មានគុណភាព រឺអុស ប្រមាណជា ៣០,៦២% ដែលឈើមានអង្កត់ផ្ចិតចាប់ពី ៥-១៥ស.ម មានប្រមាណជា ២៩,៣២% អង្កត់ផ្ចិតពី ១៥-៣០ ស.មមាន ១,១២% និងអង្កត់ផ្ចិតធំជាង ៣០ស.ម មានតិចតួចបំផុត ០,១៨%។

## ង. ការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើ

តារាង៥.២៥៖ ការប៉ាន់ស្មានជីវម៉ាស់ឈើលើដី និងការស្តុកកាបូន

| ប្រភេទព្រៃ | ជីវម៉ាស់ឈើ±S.E (t/ha) | | | ការស្តុកកាបូន±S.E | ការស្រូបCO₂±S.E |
|---|---|---|---|---|---|
| | លើដី(AGB) | ក្រោមដី(BGB) | សរុប | (t/ha) | (t/ha) |
| ព្រៃស្រោង | ១៣៦,៩៧±<br>៥៣,២៧ | ៤១,០៩±<br>១៥,៩៨ | ១៧៨,០៦±<br>៦៩,២៦ | ៨៩,០៣±៣៤,៦៣ | ៣២៦,៤៥±<br>១២៦,៩៧ |
| ព្រៃល្បោះ | ៧៧,៣៦±<br>២៣,២៤ | ២៣,២១±<br>៦,៩៧ | ១០០,៥៧±<br>៣០,២២ | ៥០,២៨±១៥,១១ | ១៨៤,៣៧±<br>៥៥,៤០ |

**ចំណាំ៖** ចំពោះការប៉ាន់ស្មានជីវម៉ាស់ក្រោមដី របាយការណ៍សិក្សាស្រាវជ្រាវរបស់ **Nophea,** ឆ្នាំ២០០៧ បង្ហាញថាតម្លៃជីវម៉ាស់ក្រោមដីជាទូទៅស្មើនឹង ៣០% នៃជីវម៉ាស់លើដី ។

ការប៉ាន់ស្មានជីវម៉ាស់ឈើលើដី និងការស្តុកកាបូនក្នុងតារាង**៥.២៥** គឺផ្អែកលើ សមីការជីវម៉ាស់ដែលបានស្រាវជ្រាវ និងរៀបចំចងក្រងដោយអង្គការអន្តរជាតិគាំទ្រការត្រួតពិនិត្យ និងវាយតម្លៃកាបូនព្រៃឈើ Winrock។

Draft

លទ្ធផលនៃការគណនាខាងលើ គឺគ្រាន់តែជាទិន្នន័យបឋមមួយ ដែលក្រុមការងារបានប្រើប្រាស់សមីការជីវម៉ាស់ឈើ ដើម្បីសាកល្បងធ្វើការប៉ាន់ស្មានជីវម៉ាស់ឈើក្នុងតំបន់សិក្សា។ លទ្ធផលជីវម៉ាស់ឈើក្នុងព្រៃស្រោងមាន **១៣៦,៩៧តោន/ហិកតា** និងព្រៃល្បោះមានប្រមាណជា **៧៧,៣៦តោន/ហិកតា**។ បរិមាណជីវម៉ាស់ឈើដែលបានប៉ាន់ស្មានខាងលើបង្ហាញថា ព្រៃស្រោងមាន ជីវម៉ាស់ឈើប្រហាក់ប្រហែលគ្នានឹងលទ្ធផលសិក្សាស្រាវជ្រាវរបស់អង្គការ JICA ឆ្នាំ២០០២ និងរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧។ ប៉ុន្តែជីវម៉ាស់ឈើក្នុងព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះមានបរិមាណទាបបើធៀបនឹងលទ្ធផលសិក្សាវាយតម្លៃរបស់អង្គការ IUCN និង UNEP-WCMC (២០១០) ដែលបានសហការជាមួយរដ្ឋបាលព្រៃឈើ។ ដោយឡែកបរិមាណកាបូនស្តុកវិញគឺមានតម្លៃស្មើនឹង ៥០% នៃជីវម៉ាស់ឈើ។ ដូច្នេះការស្តុកទុកកាបូន ក្នុងតំបន់សិក្សាតាមប្រភេទព្រៃនីមួយៗ ក្នុងតំបន់គម្រោងគឺ ព្រៃស្រោងមាន ៨៩,០៣តោន/ហិកតា±៣៤,៦៣ និង ព្រៃល្បោះមាន ៥០,២៨តោន/ហិកតា±១៥,១១។

ជារួមលទ្ធផលខាងលើបើធៀបនឹងទិន្នន័យពីអង្គការ IUCN និង UNEP-WCMC (២០១០) អាចសន្និដ្ឋានថា តំបន់សិក្សារបស់ក្រុមហ៊ុន Meng Xin Hong FA (Cambodia) Resource Investment Co.,Ltd គឺស្ថិតនៅក្នុងកម្រិតកាបូនទាបមធ្យមមានតម្លៃចន្លោះពី **១១៤-១៤២តោន/ហិកតា** ចំពោះព្រៃស្រោង និងព្រៃល្បោះមានកម្រិតកាបូនទាបតម្លៃចន្លោះពី **0-១១៤ តោន/ ហិកតា**។

### ច. ការប៉ាន់ស្មានតម្លៃកាបូនស្តុក

ជាគោលការណ៍ការប៉ាន់ស្មានលើតម្លៃកាបូនស្តុក (Carbon Credit) តាមឯកសារសិក្សារបស់ Nophea (2003) បង្ហាញថាការគណនាលើតម្លៃនៃកាបូនត្រូវធ្វើឡើងដោយគិតគូរលើបីចំនុចសំខាន់ៗរួមមាន៖ (១) និន្នាការណ៍នៃការប្រើប្រាស់ដី និងការបង្កើតនូវស្តេនារីយ៉ូនៃដែនកំណត់រយៈពេលជាក់លាក់មួយ (២ការគិតគូរ ( អំពីការអនុវត្តការងារគ្រប់គ្រងព្រៃឈើ និងអត្រានៃធនធានឈើ ដែលចាំបាច់ត្រូវសិក្សាលើ ទី១ អត្រានៃការ ធ្វើអាជីវកម្មបច្ចុប្បន្ន ទី២ ការគ្រប់គ្រងសម្រាប់ទទួលបាននូវតម្លៃសេដ្ឋកិច្ចយូរអង្វែង និងទី ៣ ការគ្រប់គ្រង នូវអត្ថប្រយោជន៍អាកាសធាតុ និង ត្រូវធ្វើការវិភាគលើផលប៉ះពាល់នៃស្តេណារីយ៉ូទាំងបីខាងលើលើកាបូន (៣) ស្តុកដើម្បីធ្វើការប៉ាន់ប្រមាណលើតុល្យភាពនៃកាបូន។ ករណីអនុវត្តតាមបីជំហ៊ានខាងលើបានទើបអាច គណនាតម្លៃកាបូនបាន។

តាមការវិភាគលើបម្រែបម្រួលគម្របព្រៃឈើពីឆ្នាំ ២០០២-២០១០ បង្ហាញថាកម្រិតនៃការបាត់បង់ ព្រៃឈើក្នុងតំបន់គម្រោងប្រចាំឆ្នាំជាមធ្យម ១,៥ភាគរយ ដែលអត្រានេះធ្វើឲ្យព្រៃឈើក្នុងតំបន់គម្រោងបាត់បង់ ប្រមាណជា ៤២,០៩ហិកតាក្នុងមួយឆ្នាំ។ ដូច្នេះយើងអាចសន្មត់ថាក្នុងរយៈពេល ៣០ឆ្នាំក្រោយ រឺនៅឆ្នាំ ២០៤០ ផ្ទៃដីព្រៃនៃតំបន់គម្រោងអាចនឹងមានការ

បាត់បង់ប្រមាណជា ១២៦២,៧០ហិកតា ដែលបង្ហាញថាផ្ទៃដីព្រៃឈើ ដែលមានសុវត្ថិភាពមាន ប្រមាណជា ១៥៤៣,៣០ហិកតាប៉ុណ្ណោះ។ យោងតាមផែនទីព័ត៌មានភូមិសាស្ត្រ បង្ហាញថាទីតាំងគម្រោងស្ថិតនៅក្នុងបរិមាណទឹកភ្លៀងជាមធ្យមទាបជាង ១៧០០មម. និងមានប្រភេទព្រៃសើម ហើយស្ងួតក្នុងរយៈវែង កំណើនជីវៈម៉ាស់ព្រៃលើលើដី (AGB) ប្រមាណជា ១,៥តោនក្នុងហិកតា/ឆ្នាំ (Draft IPCC Good Practice Guidance for LULUCF) ខណៈដែល។ ដូច្នេះក្នុងលក្ខខណ្ឌផ្ទៃដីព្រៃឈើខាងលើទំហំ ១៥៤៣,៣០ហិកតា មានសុវត្ថិភាព ត្រូវបានការពារ និងពុំមានការកាប់ទន្ទ្រាន នោះបរិមាណក កាបូនអាចនឹងកើនឡើងប្រមាណជា ៥១៧៧,៧៧តោនឧស្ម័នកាបូនិច។ ដោយផ្អែកលើតម្លៃកាបូនលើទីផ្សារស្ម័គ្រចិត្តគឺ ៥ដុល្លា/តោន ដូច្នេះក្នុងរយៈពេលគិត ត្រឹមឆ្នាំ២០៤០ តម្លៃកាបូននៃតំបន់គម្រោងគឺទទួលបានថវិកាប្រមាណជា ២៥.៨៨៨,៨៥ដុល្លា។

## ៥.៣.២ ការសិក្សាលើវត្តមានសត្វព្រៃ

### ៥.៣.២.១ វិធីសាស្ត្រក្នុងការសិក្សាវត្តមានសត្វព្រៃ

#### ក. ការសម្ភាស

ការសិក្សាលើវត្តមានសត្វព្រៃ គឺធ្វើតាមរយៈការសម្ភាស ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកបរបាញ់ ឬអ្នកដាក់អន្ទាក់ដែលធ្លាប់ចូលទៅប្រើប្រាស់ ផល-អនុផលព្រៃឈើ បរបាញ់ និងដាក់អន្ទាក់ក្នុង ឬក្បែរទីតាំងគម្រោង។ ការសម្ភាសគឺធ្វើឡើងជាលក្ខណៈមិនផ្លូវការ ដោយគ្រាន់តែពិភាក្សាឬសាកសួរព័ត៌មានវត្តមានសត្វព្រៃក្នុងតំបន់របស់គាត់ ក្នុងកំឡុងពេល ១០ឆ្នាំចុងក្រោយ។

#### ខ. ការដាក់តាំងត្រង់ស៊ិក

បន្ថែមលើព័ត៌មាន ដែលទទួលបានពីការសម្ភាសប្រជាពលរដ្ឋ នៅក្នុងតំបន់គម្រោង ក្រុមការងារសិក្សាវត្តមាន សត្វព្រៃនឹងធ្វើការអង្កេតវត្តមានសត្វព្រៃនៅតាមបន្ទាត់ត្រង់ស៊ិក ចំនួន **៥ត្រង់ស៊ិក** ចម្ងាយសរុបប្រមាណជា **១៣ គីឡូម៉ែត្រ** ដែលនឹងដាក់អង្កេតនៅទីតាំងផ្សេងៗគ្នាក្នុងតំបន់គម្រោង (ដូចផែនទី៥.២៣ បង្ហាញទីតាំងត្រង់ស៊ិកសិក្សាវត្តមានសត្វព្រៃ)។ នៅតាមបណ្តោយ និងសងខាង បន្ទាត់ត្រង់ស៊ិក ក្រុមការងារអង្កេត និងកត់ត្រាលើសម្លេង ដានជើង លាមក រោម ឬស្លាកស្នាមផ្សេងៗដែលបានលឺ ឬជួបនៅទីវាល។

ការសិក្សាស្រាវជ្រាវ និងការកត់ត្រាទិន្នន័យ គឺធ្វើឡើងនៅក្នុងកំឡុងពេលនៃការដើរអង្កេតនៅលើបន្ទាត់ត្រង់ស៊ិក តាមរយៈការពិនិត្យមើលដោយភ្នែកផ្ទាល់ទៅលើវត្តមានសត្វសងខាង (ទាំងខាងឆ្វេង និងស្តាំនៃ បន្ទាត់ត្រង់ស៊ិក) សម្លេង ដានជើង លាមក រោម ឬសញ្ញានៃក្រញ៉ាំលើសំបកឈើ ឬសញ្ញាណផ្សេងៗ ដែលអាចកំណត់ពីវត្តមានរបស់សត្វ ដែលត្រូវកត់ត្រាបញ្ចូលទៅក្នុងតារាងទិន្នន័យ (Worksheet)។

Draft




រូបភាព៥.២៦៖ ត្រង់ស៊ិកសម្រាប់សិក្សាវត្តមានសត្វព្រៃ

### គ. ការអង្កេតផ្ទាល់

ការអង្កេតផ្ទាល់នៅទីវាលជាក់ស្តែងត្រូវបានប្រើវិធីសាស្ត្រដូចខាងក្រោម៖
ថនិកសត្វ៖ អង្កេតលើដាន សម្លេង លាមក ដានជើង (លើដី ស្លឹកឈើ រឺ លើសំបកឈើ) រន្ធនៅលើ ដើមឈើជាដើម ស្ថានភាពជម្រកនិងការបរបាញ់ រឺ ការដាក់អន្ទាក់
បក្សី ៖ សិក្សាពេលព្រឹក និងពេលល្ងាច វាយតម្លៃលើជម្រក និងការសង្កេតផ្សេងៗទៀត
ឧរង្គសត្វរីល្មូន៖ ស្លាកស្នាមបន្សល់ទុកលើសំបកឈើ ដានរឺភស្តុតាងផ្សេងៗទៀតដែលបន្សល់

ការអង្កេតត្រូវបានធ្វើឡើង នៅក្នុងទីតាំងដែលបានដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សាវាយតម្លៃធនធានដើមឈើ និងការដើរអង្កេត ដោយលៃយ៉ាងណាឲ្យគ្របដណ្តប់ទូទាំងតំបន់សិក្សាស្រាវជ្រាវ។ ក្រុមការងារដើរអង្កេតសត្វព្រៃ ត្រូវបានចែកជាពីរក្រុម ហើយដើរក្នុងគំលាតពីគ្នា ២ គីឡូម៉ែត្រ និងដើរក្នុងកំរិតល្បឿន ៥០០ម៉ែត្រ/ម៉ោង ក្នុងគោលបំណងឃ្លាំមើលសត្វ ស្តាប់សំលេង ថតរូបភាព និងកត់ត្រាចំនុចនិយាមការ ដើម្បីរៀបចំផែនទីរបាយសត្វព្រៃ ឬទីជំរកក្នុងទីតាំងសិក្សាស្រាវជ្រាវ។

ប្រភព៖ (Alan Rabinowitz, 2000, ឯកសារបណ្តុះបណ្តាលការអភិរក្ស និងស្រាវជ្រាវសត្វព្រៃនៅលើភូមិសាស្ត្រ)។

### ឃ. ក្រុមសិក្សាវត្តមានសត្វព្រៃ

ការសិក្សាវត្តមានសត្វនៃគម្រោងធ្វើអាជីវកម្មព្រៃនេះ មានសមាជិកចំនួន ៥នាក់ ដែលមានដូចខាងក្រោម៖
១នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផល។
២នាក់ (ជំនួយការអ្នកបច្ចេកទេស)ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាននិងកំណត់អត្តសញ្ញាណសត្វ។
២នាក់ (អ្នកភូមិ) ជំនួយការនាំផ្លូវ ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាន (ជាអ្នកស្គាល់ឈ្មោះសត្វ)។

### ៥.៣.២.២ លទ្ធផលនៃការសិក្សាវត្តមានសត្វព្រៃ

បន្ទាត់ត្រង់ស៊ិកចំនួន៥ ត្រូវបានដើរអង្កេត ដើម្បីសិក្សាវត្តមានសត្វព្រៃ រួមមានថនិកសត្វ ល្មូន និងសត្វស្លាប ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Meng Xin Hong FA (Cambodia) Resource Investment Co.,Ltd ដោយត្រង់ស៊ិចចំនួន២ បានដើរអង្កេតនៅក្នុងព្រៃល្បោះ និងចំនួន ៣ទៀត ដើរអង្កេតក្នុងព្រៃចម្រុះនៃព្រៃស្រោង និងព្រៃល្បោះ។ ការដើរអង្កេតសត្វព្រៃ ក្រុមការងារបានកត់ត្រាទិន្នន័យសត្វលើបន្ទាត់ត្រង់ស៊ិចចម្ងាយប្រមាណជា ១៥៧៥១ម៉ែត្រ។

ជាលទ្ធផលពីការកត់ត្រាទិន្នន័យនៅទីវាលបានបង្ហាញថា ប្រភេទថនិកសត្វមានចំនួន **៦ប្រភេទ** ស្មើនឹងរបាយសត្វសរុបចំនួន **៨ក្បាល** ប្រភេទសត្វល្មូន មានចំនួន **២ប្រភេទ** ស្មើនឹងរបាយសត្វសរុបចំនួន **៣ក្បាល** និងប្រភេទបក្សីមានចំនួន **២៤ប្រភេទ** ស្មើនឹងរបាយ សត្វសរុបចំនួន **៧៤ក្បាល** ។

តារាង៥.២៦៖ ថនិកសត្វ ល្មូន និងបក្សី ដែលបានកត់ត្រាក្នុងទីតាំងសិក្សា

| ប្រភេទ | ទីតាំងសិក្សា (ឆ្នាំ ២០១៨) ផ្ទៃដីសិក្សា (ហិកតា) | |
|---|---|---|
| | ប្រភេទ | ចំនួនសត្វបានកត់ត្រា (ក្បាល) |
| ថនិកសត្វ | ៦ | ១៣ |
| ល្មូន | ៥ | ៦ |
| បក្សី | ២០ | ៨៥ |

### ក. ប្រភេទថនិកសត្វ

ប្រភេទថនិកសត្វចំនួន ៦ប្រភេទត្រូវបានជួបប្រទះ តាមរយៈដាន សម្លេង លាមក និងជួបក្នុងកំឡុងពេលដើរ អង្កេត ហើយចំនួនសត្វប្រមាណជា៨ក្បាល ត្រូវបានកត់ត្រាក្នុងបណ្តាលត្រង់សុិកទាំង៥ ក្នុងចម្ងាយប្រមាណជា ១៥គ.ម។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក. កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានប្រភេទថនិកសត្វតែមួយក្បាលទេគឺពង្រូល ដែលត្រូវបានចាត់ទុកថាជាប្រភេទមានដោយកម្រ ខណ: ៧ប្រភេទផ្សេងទៀតជាប្រភេទមានដោយបង្គួរ។ តែបើតាមបញ្ជីក្រហម IUCN Red List បង្ហាញថាពង្រូល ជាប្រភេទសត្វជិតផុតពូជ(EN) ស្វាក្តាម ជាប្រភេទរងការគំរាមកំហែង និង ៤ ប្រភេទទៀតរួមមាន ជ្រូកព្រៃ កំប្រុកពិណា ឈ្លូស និងក្តាន់ញែង ជាប្រភេទសត្វដែលមានដោយបង្គួរ។

តារាង៥.២៧៖ ចំនួនថនិកសត្វដែលបានកត់ត្រានៅទីវាល

| ល.រ | ប្រភេទសត្វ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | MAFF 2007 | IUCN | ចំនួនសត្វបានកត់ត្រា |
|---|---|---|---|---|---|---|
| ១ | ជ្រូកព្រៃ | Wild Pig | *Sus scrofa* | C | LC | ៤ |
| ២ | កំប្រុកពណ៌ | Variable Squirrel | *Callosciurus finlaysonii* | C | LC | ៤ |
| ៣ | ឈ្លូស | Red Muntjac | *Muntiacus muntjak* | C | LC | ២ |
| ៤ | ក្តាន់ញែង | Lesser Mousedeer | *Tragulus kanchil* | C | LC | ១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | ស្វាក្តាម | Long-tailed Macaque | *Macaca fascicularis* | C | Nt | ១ |
| ៦ | ពង្រូល | Sunda Pangolin | *Manis javanica* | R | EN | ១ |
| ចំនួនរបាយសត្វក្នុងតំបន់សិក្សា | | | | | | ៦ |
| ចំនួនប្រភេទសត្វដែលបានកត់ត្រា | | | | | | ១៣ |

**ចំណាំ៖** *C =Common* (មានដោយបង្គួរ), *R=Rare* (មានដោយកម្រ), *LC=Least of concern, VU=Vulnerable, EN=Endanger, NT= Nearly threat*

បើតាមព័ត៌មានពីការសម្ភាសជាមួយប្រជាពលរដ្ឋមូលដ្ឋានឲ្យដឹងថាតំបន់សិក្សាកាលពី ១០-១៥ឆ្នាំ មុនគឺសម្បូរណ៍ដោយវត្តមានប្រភេទថនិកសត្វធំៗដូចជា ខ្ទីង (Bos gaurus) ទន្សោង (Bos javanicus) ដំរី (Elephas maximus) និងប្រភេទសត្វផ្សេងៗទៀតជាច្រើន។ ប៉ុន្តែដោយសារការបរបាញ់ និងកាប់រុករានព្រៃឈើ ក្នុងតំបន់នេះតាំងពីសតវត្សទី២០ ទើបធ្វើឲ្យសត្វព្រៃដែលជាប្រភេទសំខាន់ៗត្រូវបាត់បង់វត្តមានក្នុង និងជុំវិញតំបន់សិក្សា។ បើតាមការពិនិត្យមើលលើស្ថានភាពជម្រក និងច្រករបៀងរបស់វាប្រភេទសត្វប្រហែលជាអាចនឹងមានវត្តមាន និងបំលាស់ទីនៅក្នុងតំបន់ស្នូលនៃដែនជម្រកសត្វព្រៃបឹងពែរ ដែលបច្ចុប្បន្នអាចនឹងនៅសេសសល់ ព្រៃចាស់ជាជម្រកដ៏សំខាន់។

### ខ. ប្រភេទល្មូន

ប្រភេទល្មូនមានចំនួន **៥ប្រភេទ** ត្រូវបានជួបប្រទះតាមរយៈដាន សម្លេង និងឃើញក្នុងកំឡុងពេល ដើរអង្កេត ហើយចំនួនសត្វប្រមាណជា ៦ក្បាល ត្រូវបានកត់ត្រាក្នុងបណ្តាលត្រង់ស៊ិកទាំង៥។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានប្រភេទល្មូនទាំងនោះជាប្រភេទមានដោយបង្គួរ។

តារាង៥.២៨៖ ចំនួនសត្វល្មូនដែលបានកត់ត្រានៅទីវាល

| ល.រ | ប្រភេទសត្វ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | MAFF (2007) | IUCN Red list | ចំនួនសត្វបានកត់ត្រា |
|---|---|---|---|---|---|---|
| ១ | បង្គួយ | Moustached Lizard | *Calotes mystaceus* | C | | ១ |
| ២ | ត្រកួត | Bengal Monitor | *Varanus bengalensis* | C | LC | ២ |
| ៣ | ពស់ពញ្ញាក់ព្រៃ | Inornate Kukri Snake | *Oligodon inornatus* | C | | ១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | ពស់ស្លាប់កង្កែប | Chequered keelback | *Xenochrophis piscator* | C | | ១ |
| ៥ | ថ្លែន | Long-tailed Sun Skink | *Mabuya longicaudata* | C | | ១ |
| ចំនួនរបាយសត្វក្នុងតំបន់សិក្សា | | | | | | ៥ |
| ចំនួនប្រភេទសត្វដែលបានកត់ត្រា | | | | | | ៦ |

## គ. ប្រភេទបក្សី

ប្រភេទសត្វស្លាបចំនួន **២០ប្រភេទ** ត្រូវបានជួបប្រទះ តាមរយៈសម្លេង ជួប និងស្លាកស្នាមផ្សេងៗ ក្នុងកំឡុងពេលដើរអង្កេត ហើយចំនួនសត្វប្រមាណជា **៨៥ក្បាល** ត្រូវបានកត់ត្រាក្នុងបណ្ដាលត្រង់ស៊ិកទាំង៥។ តាមការកំណត់ក្នុងប្រកាសលេខ ២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានប្រភេទបក្សីចំនួន **៧ប្រភេទ** ជាប្រភេទមានដោយបង្គួរ ខណៈ **១៣ប្រភេទ** ផ្សេងទៀតត្រូវបានបង្ហាញថា ស្ថានភាពរបស់វាមិនស្ទូវសម្បូរណ៍ទេក្នុងប្រទេសកម្ពុជា (តារាងទី ៥.២៩)។

តារាង៥.២៩៖ ចំនួន និងប្រភេទសត្វស្លាបដែលបានកត់ត្រានៅទីវាល

| ល.រ | ប្រភេទសត្វ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ស្ថានភាពនៅកម្ពុជា | IUCN | ចំនួនសត្វបានកត់ត្រា |
|---|---|---|---|---|---|---|
| ១ | សារិកាកែវ | Hill Myna | *Gracula religiosa* | r | $LC^-$ | ២ |
| ២ | សេកក្រិច | Vernal Hanging parrot | *Loriculus Vernails* | r | | ៥ |
| ៣ | ទទា | Chinese Francolin | *Francolinus pintadeanus* | C | LC | ៣ |
| ៤ | លលកបាយ | Soptted Dove | *Streptopelai Chinensis* | C | LC | ១ |
| ៥ | ចាបតេតព្រៃ | Dark-necked tailorbird | *Orthotomus atrogularis* | C | LC | ២ |
| ៦ | មាន់ព្រៃ | Red Junglefowl | *Gallus gallus* | r | $LC^+$ | ១ |
| ៧ | ស្ទាំងលលក | black-Shouldered Kite | Elanus cearuleus | r | | ១ |
| ៨ | អន្ទេបខ្មៅ | Black Drongo | *Dicrurus macrocercus* | C | LC | ២ |
| ៩ | ទៀវព្រៃ | Dollarbird | *Eurystomus orientalis* | r | $LC^-$ | ១ |
| ១០ | ត្រសេះត្នោតចំពុះខ្មៅ | Rufous Woodpecker | *Celeus brachyurus* | r | $LC^+$ | ៤ |
| ១១ | ពពិចពុកមាត់លឿង | Stripe-throated Bulbul | *Pynonotus finlaysoni* | r | LC | ៨ |

Draft

| ល.រ | ប្រភេទសត្វ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ស្ថានភាពនៅកម្ពុជា | IUCN | ចំនួនសត្វបានកត់ត្រា |
|---|---|---|---|---|---|---|
| ១២ | សេកអាត់ | Blossom-headed Parakeet | *Psittacula roseate* | r | | ១៥ |
| ១៣ | ល្អូតស្បូវ | Lesser Coucal | *Centropus bengalensis* | r | LC+ | ៣ |
| ១៤ | ត្រដេវិចទូល | Red-wattled Laping | *Vanellus indicus* | C | LC | ៤ |
| ១៥ | ល្វាចេកព្រៃ | White-rumped Shama | *Copsychus malabaricus* | r | LC- | ៣ |
| ១៦ | ចចាតក្រឹម | Common Kingfisher | *Alcedo atthis* | C | LC | ៩ |
| ១៧ | ចាបជង្គុំចុងកន្ទុយសរ | Zitting Cistcola | *Cisticola juncidis* | r | LC+ | ៦ |
| ១៨ | ទ្រមាក់ខ្លា | Racket-tailed Treepie | *Cry psirina temia* | r | | ៣ |
| ១៩ | មៀម | Spotted Wood Owl | *Strix selputo* | C | | ២ |
| ២០ | ត្រចៀកកាំព្រៃ | Crested Treeswift | *Hemiprocne coronata* | r | LC | ១៥ |
| **ចំនួនរបាយសត្វក្នុងតំបន់សិក្សា** | | | | | | **៨៥** |
| **ចំនួនប្រភេទសត្វដែលបានកត់ត្រា** | | | | | | **២០** |

**ចំណាំ៖** -: ដង់ស៊ីតេកំពុងកើនឡើង, +: ដង់ស៊ីតេកំពុងធ្លាក់ចុះ, *C=common* (មានដោយបង្គួរ), *LC= Least of concern* (មានដោយបង្គួរ), *r = Rare* (មិនសូវសម្បូរណ៍)

តាមការសិក្សាស្រាវជ្រាវរបស់អង្គការ **IUCN** បានបង្កើតនូវបញ្ជីក្រហម **IUCN Red List** ដើម្បីកំណត់ អំពីប្រភេទសត្វដែលងាយរងគ្រោះ ងាយរងគ្រោះជិតផុតពូជ មានដោយកម្រ និងរងការគំរាមកំហែងជាដើម។ ដោយធ្វើការផ្ទៀងផ្ទាត់លទ្ធផលពីការកត់ត្រាជាមួយនឹង **IUCN Red List** បង្ហាញថាសត្វស្លាបចំនួន **១៣ប្រភេទ** ក្នុងចំណោម **២០ប្រភេទ** ជាប្រភេទដែលមានដោយបង្គួរ ប៉ុន្តែក្នុងនោះសត្វស្លាបចំនួន **២ប្រភេទ** ដូចមាន បង្ហាញក្នុងតារាងខាងលើ មាននិន្នាការថយចុះនូវដង់ស៊ីតេរបស់វាជាសកល។

តាមការសម្ភាសជាមួយប្រជាពលរដ្ឋមូលដ្ឋាន បង្ហាញថាក្រៅពីប្រភេទដែលក្រុមការងារបានជួបប្រទះ ក្នុងពេលដើរអង្កេតតាមត្រង់ស៊ិក អាចនឹងមានប្រភេទសំខាន់ៗ (Key Species) មួយចំនួនដូចជា ក្ងោក ត្រយ៉ង់ កេងកងតូច ក្អែក មៀម ទីទុយ និងខ្លែងស្រាកផងដែរ។ ប៉ុន្តែប្រភេទទាំងនោះមិនជាញឹកញាប់ទេ ដែលបានជួបប្រទះ ក្នុងនោះគេសង្កេតឃើញថាតំបន់ព្រៃស្រោងក្រាស់ដែលជាទីតាំងមិនទាន់បោសសំអាតមីននៅឡើយ ដូចនេះអាចនឹងឃើញប្រភេទសត្វស្លាបសំខាន់នេះម្តងម្កាល។

## ឃ. ប្រភេទជីវៈចំរុះនៅក្នុងទឹក

ដោយសារនៅក្នុងតំបន់គម្រោងពុំមានប្រព័ន្ធស្ទឹង បឹង អូរហូរកាត់តំបន់គម្រោង ហេតុដូចនេះ ការសិក្សាអំពីជីវៈចំរុះនៅក្នុងទឹកមិនត្រូវបានសិក្សាទេ។

Draft

# ការសិក្សាស្ថានភាពសង្គម និងសេដ្ឋកិច្ច

Draft

## ៥.៤ ការសិក្សាស្ថានភាពសង្គម និងសេដ្ឋកិច្ច

គោលបំណងនៃការសិក្សានូវធនធានសង្គម-សេដ្ឋកិច្ច គឺដើម្បីយល់ដឹងពីស្ថានភាព និងសក្តានុពលនៃសេដ្ឋកិច្ច-សង្គម របស់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់គម្រោងអភិវឌ្ឍន៍។តាមការសម្ភាសលោកមេឃុំខ្វាវ បានឲ្យដឹងថា នៅក្នុងតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ មិនមានវត្តមានប្រជាជនរស់នៅទេ ហេតុដូចនេះការសិក្សាស្ថានភាពសង្គម និងសេដ្ឋកិច្ច ត្រូវបានធ្វើឡើងជាមួយប្រជាជនដែលរស់នៅក្បែរតំបន់គម្រោងគឺមានភូមិខ្វាវ ភូមិចុងស្ពាន និងភូមិរៀង។

គោលបំណងនៃការសិក្សាទៅលើបរិស្ថាន សង្គម និងសេដ្ឋកិច្ច ក្នុងតំបន់គម្រោងអភិវឌ្ឍន៍ គឺត្រូវបានផ្តោតទៅលើៈ

- ប្រជាសាស្ត្រ និងការតាំងទីលំនៅ
- ជនជាតិ
- ស្ថានភាពសេដ្ឋកិច្ចៈ មុខរបរ ប្រាក់ចំណូល (ប្រភពចំណូលសំខាន់ៗ និងបន្ទាប់បន្សំ)
- ការប្រើប្រាស់ដី
- ការប្រើប្រាស់ទឹក
- ការប្រើប្រាស់ថាមពល
- ការអប់រំ
- សុខភាព និងអនាម័យ
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- សម្បត្តិវប្បធម៌ ទំនៀមទំលាប់ និងសាសនា
- តំបន់ទេសចរណ៍

### ៥.៤.១ វិធីសាស្ត្រស្រាវជ្រាវ

### ក. វិធីសាស្ត្រក្នុងការសិក្សា

វិធីសាស្ត្រក្នុងការសិក្សាស្ថានភាពសេដ្ឋកិច្ច-សង្គម ចែកចេញជាពីរគឺ ការប្រមូលទិន្នន័យបឋម (Primary Data) និងការប្រមូលទិន្នន័យបន្ទាប់បន្សំ (Secondary Data)។

→ **ទិន្នន័យបឋមៈ** គឺបានមកពីការសម្ភាសផ្ទាល់ជាមួយមេឃុំ មេភូមិ និងប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរតំបន់គម្រោង។ ការប្រមូលទិន្នន័យនេះបានប្រើប្រាស់កម្រងសំណួរដើម្បីធ្វើការសម្ភាស។

→ **ទិន្នន័យបន្ទាប់បន្សំៈ** គឺជាឯកសារ ឬរបាយការណ៍ដែលពាក់ព័ន្ធ និងស្ថានភាពភូមិ ឃុំ ក្បែរតំបន់គម្រោង ដែលបានបោះពុម្ពចុងក្រោយគេ។

Draft

## ខ. ការកំណត់ចំនួនសំណាក

យោងទៅតាមស្ថានភាពភូមិសាស្រ្តនៃតំបន់គម្រោង និងការសាកសួរលោកមេឃុំខ្វាវ បានឲ្យដឹងថា ភូមិដែលនៅក្បែរតំបន់គម្រោង មានចំនួន៣គឺ ភូមិខ្វាវ ភូមិចុងស្ពាន និងភូមិរវៀង ដែលភូមិទាំងបីស្ថិតនៅក្នុងឃុំតែមួយគឺឃុំខ្វាវ។ ដើម្បីប្រមូលព័ត៌មានពីសំណាកឲ្យមានប្រសិទ្ធភាព និងគ្រប់គ្រាន់ វិធីសាស្រ្តគំរូសំណាកចៃដន្យ (Random Sampling) ត្រូវបានអនុវត្តក្នុងការសិក្សាស្រាវជ្រាវនេះ។ ការជ្រើសយកសំណាកសម្រាប់គម្រោង **ធ្វើអាជីវកម្មរ៉ែទង់ដែង**នេះ គឺត្រូវជ្រើសរើសយកប្រជាជន ដែលរស់នៅក្បែរតំបន់គម្រោង ហើយត្រូវគណនាតាមរូបមន្តថារ៉ូ (Taro Yamane) ដែលកំណត់យកកម្រិតលំអៀង១០%។ សំណាកប្រជាជនសរុបសម្រាប់ការជួបសម្ភាសន៍គឺ ៩២គ្រួសារ ដោយត្រូវបានគណនាពីចំនួនប្រជាជនសរុបក្នុងភូមិទាំងបីខាងលើ និងបង្ហាញដូចខាងក្រោម៖

តាមរូបមន្តថារ៉ូ៖

$$n = \frac{N}{1 + Ne^2}$$

ដែល៖

- n : ចំនួនសំណាកគំរូ
- N : ចំនួនគ្រួសារសរុប
- e : កំរិតលម្អៀង = ១០%

$$n = \frac{956}{1 + 956\,(0.1)^2} \cong 92$$

ការគណនាសំណាកតាមភូមិនីមួយៗ

តាមរូបមន្ត:

$$nx = \frac{N}{n} dx$$

ដែល:

nx ជាចំនួនសំណាកដែលត្រូវរក

N ជាចំនួនគ្រួសារតាមភូមិ

n ជាចំនួនគ្រួសារសរុប

dx ជាចំនួនសំណាកដែលត្រូវយកសរុប

ភូមិខ្វារ $$nx = \frac{646}{956} \times 92 \cong 62$$

ភូមិចុងស្ពាន $$nx = \frac{125}{956} \times 92 \cong 12$$

ភូមិរវៀង $$nx = \frac{185}{956} \times 92 \cong 18$$

តារាង៥.៣០៖ សំណាកតាមភូមិនីមួយៗ

| ឈ្មោះភូមិ | ចំនួនគ្រួសារសរុប | ចំនួនសំណាក |
|---|---|---|
| ខ្វារ | ៦៤៦ | ៦២ |
| ចុងស្ពាន | ១២៥ | ១២ |
| រវៀង | ១៨៥ | ១៨ |
| **សរុប** | **៩៥៦** | **៩២** |

### ៥.៤.២ លទ្ធផលនៃការសិក្សា

#### ៥.៤.២.១ លក្ខណៈប្រជាសាស្ត្រ

តាមរយៈការចុះទៅសិក្សាដោយផ្ទាល់ ដោយបានធ្វើបទសម្ភាសន៍ជាមួយប្រជាជនចំនួន **៩២គ្រួសារ** នៅក្នុងភូមិ ៣ នៅក្នុងឃុំខ្វារ គឺ ភូមិខ្វារ ភូមិចុងស្ពាន និងភូមិរវៀង បានបង្ហាញថា អ្នកឆ្លើយតបជាបុរសមានចំនួន ២៤នាក់ (២៦.១%) និង ស្ត្រីមានចំនួន ៦៨ នាក់ (៧៣.៩%)។ ពួកគាត់ភាគច្រើនមានអាយុចន្លោះពី៖

តិចជាង ៣០ ឆ្នាំ មានចំនួន ២៣នាក់ ដែលស្មើនឹង ២៥%

ចន្លោះពី ៣១ ដល់ ៥០ ឆ្នាំ មានចំនួន ៤៧ នាក់ ដែលស្មើនឹង ៥១.១%

ច្រើនជាង ៥០ ឆ្នាំ មានចំនួន ២២ នាក់ ដែលស្មើនឹង ២៣.៩%

តាមរយៈភាគរយនៃក្រុមអាយុ របស់អ្នកឆ្លើយតបខាងលើនេះ យើងឃើញថា អ្នកឆ្លើយតបភាគច្រើនមានចន្លោះអាយុពី ៣១ ដល់ ៥០ឆ្នាំ ដែលពួកគាត់ជាជនបង្គោលដ៏សំខាន់នៅក្នុងគ្រួសារហើយមានសិទ្ធិលើការសំរេចចិត្តនៅក្នុងគ្រួសារផងដែរ។

ជាទូទៅប្រជាជន នៅក្នុងឃុំខ្វាវមានសមាជិកគ្រួសារជាមធ្យមចំនួន ៥,២៤ នាក់។ ចំណែកគ្រួសារដែលមានសមាជិក ៥ នាក់ មានច្រើនជាងគេនៅក្នុងឃុំ ដែលមានប្រែកង់រហូតដល់ ២៤ គ្រួសារ នៅខណៈដែលគ្រួសារដែលមានសមាជិក១០នាក់ (១គ្រួសារ) និង ១១នាក់ (១គ្រួសារ) (ក្រាហ្វិក៥.៥)។




ក្រាហ្វិក៥.៥៖ ទំហំនៃសមាជិកគ្រួសារ



រូបភាព៥.២៧៖ ស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់គម្រោង

Draft

### ៥.៤.២.២ ជនជាតិ និងសាសនា

តាមការសិក្សាបានបង្ហាញថា ប្រជាជននៅក្នុងឃុំខ្វាវ គឺជាជនជាតិខ្មែរ១០០% មិនមានជនជាតិភាគតិចរស់នៅតំបន់នោះទេ។ ចំពោះសាសនាគឺប្រជាជនក្នុងឃុំខ្វាវ១០០% កាន់សាសនាព្រះពុទ្ធ មិនមានប្រជាជនកាន់សាសនា គ្រឹស្ត និងអ៊ីស្លាមទេ។ ជាក់ស្តែងនៅក្នុងឃុំខ្វាវ មិនមានវត្តមានវិហារអ៊ីស្លាម និងវិហារយេស៊ូគ្រឹស្តទេ។

### ៥.៤.២.៣ ស្ថានភាពផ្ទះសម្បែង

តាមរយៈការចុះប្រមូលពត៌មានដោយផ្ទាល់នៅក្នុងឃុំខ្វាវ បានសង្កេតឃើញថា ស្ថានភាពផ្ទះសម្បែងរបស់ប្រជាជននៅក្នុងឃុំមានដំបូលប្រក់ក្បឿងច្រើន ដែលមានប្រមាណជា ៤៥.៦% ប្រភេទដំបូលស័ង្កសីមាន ៣៧% ប្រភេទដំបូលស្បូវមាន ១៧.៤%។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទផ្ទះដែលមានដំបូលក្បឿងដែលមានភាគរយច្រើនជាងគេនោះ ភាគច្រើនជាប្រភេទផ្ទះចាស់ៗ ដែលបានសាងសង់យូរឆ្នាំមកហើយ និងមានទំហំតូច និងខ្លះទៀតមានសភាពធ្លុះធ្លាយគ្មានជញ្ជាំងត្រឹមត្រូវឡើយ។ តាមរយៈលក្ខណៈផ្ទះសម្បែងរបស់គាត់អាចបញ្ជាក់បានថាកម្រិតជីវភាពរបស់គាត់នៅមានកម្រិតទាបនៅឡើយ។




ក្រាហ្វិក៥.៦៖ ប្រភេទដំបូលផ្ទះរបស់ប្រជាជននៅក្នុងឃុំខ្វាវ



រូបភាព៥.២៨៖ ស្ថានភាពផ្ទះសម្បែងរបស់ប្រជាជននៅក្នុងតំបន់សិក្សា

### ៥.៤.២.៤ ការប្រើប្រាស់ដី

ភាគច្រើនប្រជាជននៅក្នុងឃុំខ្វាវ មានដីចំនួនបីប្រភេទគឺ ដីលំនៅស្ថាន ដីស្រែ និងដីចម្ការ។ ចំពោះដីលំនៅស្ថានមានការសាងសង់លំនៅស្ថាន និងដាំដំណាំហូបផ្លែ និងបន្លែបន្តិចបន្តួច នៅជិតៗផ្ទះ។ ចំណែកឯដីស្រែ និងដីចម្ការ ជាទូទៅពួកគាត់ប្រើប្រាស់សម្រាប់ធ្វើកសិកម្ម ដូចជាការដាំដំណាំស្រូវជាដើម។ ប៉ុន្តែដីស្រែ និងដីចម្ការភាគច្រើនជាប្រភេទដីថ្មី ដែលទើបតែទន្ទ្រានព្រៃបាន និងគ្មានប្លង់ រឺប័ណ្ណកម្មសិទ្ធត្រឹមត្រូវទេ។ ដីស្រែ និងដីចម្ការទាំងនេះជាដីដែលទុកចោល គ្មានការដាំដុះដំណាំអ្វីឡើយ។



រូបភាព៥.២៩៖ ស្ថានភាពនៃការប្រើប្រាស់ដីនៅក្នុងតំបន់សិក្សា



Draft

# ផែនទីពីឃុំ បង្ហាញពីការប្រើប្រាស់ដីធ្លីលំអិតក្នុងតំបន់គម្រោងអាជីវកម្មរ៉ែទង់ដែង




រូបភាព៥.៣០៖ ផែនទីប្រើប្រាស់ដីនៅក្នុងឃុំខ្វាវ

### ៥.៤.២.៥ កម្រិតនៃការអប់រំ

ចំពោះកម្រិតនៃការអប់រំរបស់ប្រជាជននៅក្នុងឃុំខ្វាវ មានអ្នកដែលមិនចេះអក្សររហូតដល់៤៤នាក់ (៤៧.៨%) បឋមសិក្សាមាន ៣៥នាក់ (៣៨%) អនុវិទ្យាល័យមាន ៧នាក់ (៧.៦%) វិទ្យាល័យមាន ១នាក់ (១.១%) និងចេះអាន និងចេះសរសេរមាន ៥នាក់ (៥.៤%)។ យោងទៅតាមលទ្ធផលនេះបង្ហាញថា ការអប់រំនៅមានកម្រិតនៅឡើយសម្រាប់ប្រជាជននៅក្នុងឃុំខ្វាវ។ មូលហេតុដែលភាគរយនៃអ្នកមិនចេះអក្សរមានភាគរយច្រើន ពីព្រោះយើងសង្កេតឃើញថាអ្នកឆ្លើយតបភាគច្រើនមានអាយុចន្លោះពី ៣១ ដល់ ៥០ឆ្នាំ ដែលអាយុចូលរៀនរបស់ពួកគាត់ស្ថិតនៅក្នុងសម័យសង្គ្រាមស៊ីវិល ដែលធ្វើឲ្យរាំងស្ទះដល់ការសិក្សារបស់ពួកគាត់។




ក្រាហ្វិក៥.៧៖ កម្រិតនៃការអប់រំរបស់ប្រជាជននៅក្នុងឃុំខ្វាវ

Draft

ក្នុងចំណោមអ្នកឆ្លើយតបដែលមិនចេះអក្សរ ៤៧.៨% មានស្ត្រីរហូតដល់ ៧៣% នៅខណៈដែលបុរសមានត្រឹមតែ ២៣% ប៉ុណ្ណោះ។ ទិន្នន័យនេះសរបញ្ជាក់ឲ្យឃើញថា ស្ត្រីភាគច្រើនបានទទួលការអប់រំទាបជាងបុរស។ មូលហេតុដែលធ្វើឲ្យស្ត្រីភាគច្រើនទទួលបានការអប់រំទាបជាងបុរស វាអាចបណ្តាលមកពីកត្តាច្រើនយ៉ាងដូចជា៖

កត្តាសេដ្ឋកិច្ច (គ្រួសារក្រីក្រ ជីវភាពខ្វះខាត គ្មានប្រាក់ផ្គត់ផ្គង់ថ្លៃសិក្សាប្រចាំថ្ងៃ)

កត្តាសង្គម (អសន្តិសុខសង្គម ការរំលោភបំពាន ការបង្ខិតបង្ខំ សាលារៀននៅឆ្ងាយពីផ្ទះ និងទំនៀមទំលាប់ ប្រពៃណីផ្សេងៗ)

កត្តាខ្លួនឯងផ្ទាល់ ( ភាពខ្ជិលច្រអូស គ្មានឆន្ទៈ ខ្សោយប្រាជ្ញា)។




ក្រាហ្វិក៥.៨៖ ភាគរយនៃអ្នកមិនចេះអក្សររវាងបុរស និងស្ត្រី

### ៥.៤.២.៦ មុខរបរ

យោងទៅតាមលទ្ធផលនៃការសិក្សាបានបង្ហាញថា ប្រជាជននៅក្នុងឃុំខ្វាវ ភាគច្រើនប្រកបមុខរបរកសិកម្ម ធ្វើស្រែចម្ការ ដែលមានភាគរយរហូតដល់ ៨៨%។ ខណៈដែល អាជីវករ កម្មករ សិប្បករ និងមុខរបរផ្សេងៗមានកម្រិតទាប (ក្រាហ្វិក៥.៩)។ ជាក់ស្តែង តាមទិន្នន័យដែលទទួលបានពីលោកមេឃុំខ្វាវ ក៏បានបង្ហាញផងដែរថា ឃុំខ្វាវដែលមាន ២,៧៣២ គ្រួសារ មាន ៩០% ដែលប្រកបរបរកសិកម្ម ធ្វើស្រែ និងចម្ការ ដែលប្រហាក់ប្រហែលទៅនឹងលទ្ធផលនៃការសិក្សា។




ក្រាហ្វិក៥.៩៖ មុខរបរចម្បងរបស់ប្រជាជននៅក្នុងឃុំខ្វាវ



រូបភាព៥.៣១៖ ស្ថានភាពមុខរបររបស់ប្រជាជននៅក្នុងឃុំខ្វាវ

## ៥.៤.២.៧ ប្រាក់ចំណូល និងចំណាយប្រចាំខែ

### ក. ប្រាក់ចំណូល

ប្រាក់ចំណូលប្រចាំខែ របស់គ្រួសារនីមួយៗ នៅក្នុងឃុំខ្វាវ មានលក្ខណៈខុសៗគ្នា អាស្រ័យទៅនឹងប្រភពប្រាក់ចំណូល (មុខរបរចំបងនៅក្នុងគ្រួសារ) និងចំនួនអ្នករកប្រាក់ចំណូលនៅក្នុងគ្រួសារ។ តាមរយៈតារាង៤.២៥ បានបង្ហាញថា ប្រាក់ចំណូលជាមធ្យមរបស់អ្នកឆ្លើយតបមានចន្លោះពី តិចជាង២៤មុឺន ២៤-៤០មុឺន ៤០-៨០មុឺន និង៨០-២លាន ដែលមានភាគរយ ២៧,២% ៤៣,៥% ២១,៧% និង៧,៦% ក្នុងតម្លៃរៀងគ្នា។ ដូចនេះ អាចសន្និដ្ឋានបានថា ការប្រកបមុខរបររបស់ពួកគាត់ ពិសេសកសិកម្ម អាចរកប្រាក់ចំណូលជាមធ្យមចន្លោះ ២៤ ៤០មុឺនរៀលនៅក្នុងមួយខែស្មើនឹង ៤៣,៥% ខណៈដែលប្រាក់ចំណូលទាបបំផុតស្មើនឹង ២៤មុឺនរៀល និងចំណូលដែលខ្ពស់ជាងគេនៅចន្លោះ ៨០មុឺន-២លានរៀល។ បើប្រៀបធៀបប្រាក់ចំណូលទាបបំផុតទៅនឹង បន្ទាត់ភាពក្រីក្រ ឃើញថាប្រាក់ចំណូលរបស់ពួកគាត់ ស្ថិតនៅលើបន្ទាត់នៃភាពក្រីក្រដែលបានកំណត់ដោយរដ្ឋាភិបាល (១ដុល្លា/ថ្ងៃ)។

#322P, St.271Z, Sk.Terk Tia, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៥.៣១៖ កម្រិតប្រាក់ចំណូលប្រចាំខែរបស់ប្រជាជននៅក្នុងឃុំខ្វាវ

| ល.រ | ប្រាក់ចំណូល (ម៉ឺនរៀល/ខែ) | ចំនួនគ្រួសារ | ភាគរយ(%) |
|---|---|---|---|
| ១ | < ២៤ | ២៥ | ២៧.២ |
| ២ | ២៤-៤០ | ៤០ | ៤៣.៥ |
| ៣ | ៤០-៨០ | ២០ | ២១.៧ |
| ៤ | ៨០-២០០ | ៧ | ៧.៦ |
| សរុប | | ៩២ | ១០០ |

តារាង៥.៣២៖ កម្រិតប្រាក់ចំណូលប្រចាំខែទៅតាមប្រភេទមុខរបរ

| កម្រិតប្រាក់ចំនូល (ម៉ឺនរៀល) | មុខរបរ (ចំនួន) | | | | | សរុប |
|---|---|---|---|---|---|---|
| | អ្នកលក់ដូរតូចតាច | កសិករ | កម្មករ | សិប្បករ | ផ្សេងៗ | |
| < ២៤ | - | ២៤ | ១ | - | - | ២៥ |
| ២៤-៤០ | ១ | ៣៦ | - | ១ | ២ | ៤០ |
| ៤០-៨០ | - | ១៥ | - | ២ | ៣ | ២០ |
| ៨០-២០០ | - | ៦ | - | ១ | - | ៧ |
| សរុប | ១ | ៨១ | ១ | ៤ | ៥ | ៩២ |

Draft

**ខ. ប្រាក់ចំណាយ**

ជាទូទៅប្រាក់ចំណាយក្នុងគ្រួសារនីមួយៗនៅក្នុងតំបន់សិក្សាពុំសូវមានលក្ខណៈខុសគ្នាប៉ុន្មានទេ។ ការចំណាយនៅក្នុងគ្រួសារភាគច្រើនគឺចំណាយទៅលើ ការធ្វើកសិកម្ម ម្ហូបអាហារប្រចាំថ្ងៃ ថ្លៃអគ្គិសនី ថ្លៃទឹក ថ្លៃថែរក្សាសុខភាព ថ្លៃផ្គត់ផ្គង់ការសិក្សា និងការចំណាយថ្លៃការទិញសម្ភារៈផ្សេងៗ។ ផ្ទុយទៅវិញ កត្តាដែលធ្វើឲ្យការចំណាយមានភាពខុសគ្នាគឺអាស្រ័យទៅលើចំនួនសមាជិកគ្រួសារនៅក្នុងគ្រួសារនីមួយៗ។ ជាក់ស្តែង គ្រួសារដែលមានចំនួនសមាជិកតិច មានតម្រូវការតិច ចំណែកឯគ្រួសារដែលមានសមាជិកគ្រួសារច្រើន មានតម្រូវការច្រើន ដូចនេះទាមទារឲ្យមានការចំណាយច្រើន។

តារាង៥.៣៣៖ កម្រិតប្រាក់ចំណាយប្រចាំខែរបស់ប្រជាជននៅក្នុងឃុំខ្វាវ

| ល.រ | ប្រាក់ចំណាយ (ម៉ឺនរៀល/ខែ) | ចំនួនគ្រួសារ | ភាគរយ (%) |
|---|---|---|---|
| ១ | < ២៥ | ២៩ | ៣១,៥ |
| ២ | ២៥-៤០ | ៤៩ | ៥៣,៣ |
| ៣ | ៤០-៨០ | ១៤ | ១៥,២ |
| សរុប | | ៩២ | ១០០ |

## ៥.៤.២.៨ ការប្រើប្រាស់ថាមពល

### ក. ថាមពលសម្រាប់បំភ្លឺគេហដ្ឋាន

តាមការសិក្សាបានបង្ហាញថា នៅក្នុងឃុំខ្វាវមានបណ្តាញថាមពលអគ្គិសនីដែលជាកម្មសិទ្ធិឯកជន ហើយផ្គត់ផ្គង់បាន ២៤ ម៉ោង/ថ្ងៃ នៅក្នុងតម្លៃ ៣៥០០រៀល/KWH។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រជាជននៅក្នុងឃុំខ្វាវមានត្រឹមតែ ៣២ គ្រួសារ ដែលស្មើរនឹង ៣៤.៨% ប៉ុណ្ណោះ ដែលប្រើប្រាស់ថាមពលអគ្គិសនីក្នុងជីវភាពប្រចាំថ្ងៃ។ ចំពោះគ្រួសារចំនួន ៦០គ្រួសារដែលគ្មានប្រភពថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងការបំភ្លឺគេហដ្ឋាន ពួកគាត់ប្រើប្រាស់ប្រភេទថាមពលផ្សេងៗដូចបានបង្ហាញក្នុងក្រាហ្វិកខាងក្រោមនេះ ៖




ក្រាហ្វិក៥.១០៖ ប្រភេទថាមពលប្រើប្រាស់សម្រាប់បំភ្លឺគេហដ្ឋាន

### ខ. ថាមពលសម្រាប់ចំអិនអាហារ

ចំពោះប្រភេទថាមពល ដែលប្រជាជនប្រើប្រាស់ដើម្បីចំអិនអាហារមានដូចជា អុស ធ្យូង ហ្គាស និងថាមពលអគ្គិសនី។ យោងទៅតាមលទ្ធផលនៃការសិក្សាបានឲ្យដឹងថា ប្រជាជនប្រមាណជា ៨៩,១% នៃប្រជាជនដែលបានធ្វើបទសម្ភាសន៍ បានប្រើប្រាស់អុសជាថាមពលចម្បងសម្រាប់ចំអិនម្ហូបអាហារប្រចាំថ្ងៃរបស់ពួកគាត់។ ចំណែកឯ ៨,៩% ប្រើប្រាស់ធ្យូង ហើយ ១% ចំពោះអ្នកប្រើហ្គាស និងអ្នកប្រើថាមពលអគ្គិសសនី ។ តាមទិន្នន័យនេះ បញ្ជាក់ថាប្រជាជននៅក្នុងឃុំខ្វាវភាគច្រើនប្រើប្រាស់អុស ជាថាមពលសម្រាប់ចំអិនម្ហូបអាហារប្រចាំថ្ងៃ។ មូលហេតុដែលនាំឲ្យពួកគាត់ប្រើប្រាស់អុសសម្រាប់ចំអិនម្ហូបអាហារគឺ ដោយសារកត្តាជីវភាព ដែលធ្វើឲ្យពួកគាត់គ្មានលទ្ធភាពក្នុងការប្រើប្រាស់ថាមពលហ្គាស និងថាមពលអគ្គិសនីសម្រាប់ការចំអិនម្ហូបអាហារប្រចាំថ្ងៃបាន។ ម្យ៉ាងវិញទៀតឃុំខ្វាវគឺជាតំបន់មួយដែលនៅជិតភ្នំ និងមានព្រៃឈើដែលអាចឲ្យប្រជាជនទៅរកអុសនៅក្នុងព្រៃបានដោយមិនចាំបាច់ចំណាយប្រាក់ក្នុងការទិញថាមពលផ្សេងៗដូចជា ហ្គាស និងថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ឡើយ។




ក្រាហ្វិក៥.១១៖ ប្រភេទថាមពលប្រើប្រាស់សម្រាប់ការចំអិនម្ហូបអាហារ

### ៥.៤.២.៩ ការប្រើប្រាស់ទឹក

ប្រជាជននៅក្នុងឃុំខ្វាវ ប្រើប្រាស់ទឹកច្រើនប្រភពផ្សេងៗគ្នាដោយអាស្រ័យទៅតាមរដូវប្រាំង និងរដូវវស្សា។ តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា នៅរដូវប្រាំងប្រជាជនប្រើប្រាស់ទឹកទុយយោ (បណ្ដាញទឹកស្អាត) និងប្រភពទឹកក្រោមដីដូចជា៖ ទឹកអណ្ដូងស្នប់ ទឹកអណ្ដូងលូ និងទឹកអណ្ដូងជីកដោយដៃ ចំណែកឯនៅរដូវវស្សា ប្រជាជននិយមប្រើប្រាស់ប្រភពទឹកលើដីដូច

ជា៖ ទឹកភ្លៀង ទឹកបឹង/ស្រះ និងទឹកស្ទឹង/អូរជាដើម។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់ឃុំខ្វាវមិនសូវសំបូរទឹកប្រើប្រាស់ទេ បើទោះបីជានៅក្នុងតំបន់មានប្រភពទឹកជាច្រើនក៏ដោយ។ ភាគច្រើនប្រជាជនប្រើប្រាស់ទឹកភ្លៀង ពីព្រោះទឹកភ្លៀងជាប្រភពដែលងាយស្រួលក្នុងការទាញយកមកប្រើប្រាស់។ តាមក្រាហ្វិក ៥.១២ ក៏បានបង្ហាញដែរថាភាគរយនៃគ្រួសារដែលប្រើប្រាស់ទឹកភ្លៀងមានចំនួនច្រើនដែលមានរហូតដល់ ៤២,១% នៃគ្រួសារដែលបានធ្វើបទសម្ភាសន៍ទាំងអស់។




ក្រាហ្វិក៥.១២៖ ប្រភពទឹកសម្រាប់ប្រើប្រាស់របស់ប្រជាជន

Draft





រូបភាព៥.៣២៖ ប្រភពទឹកសម្រាប់ប្រើប្រាស់ និងបរិភោគ




ក្រាហ្វិក៥.១៣៖ ប្រភពទឹកសម្រាប់បរិភោគរបស់ប្រជាជននៅក្នុងឃុំខ្វាវ



រូបភាព៥.៣៣៖ ប្រភពទឹកសម្រាប់ប្រើប្រាស់ និងបរិភោគ

### ៥.៤.២.១០ សុខភាព និងអនាម័យ

#### ក. ការសម្អាតទឹកសម្រាប់បរិភោគប្រចាំថ្ងៃ

ការសម្អាតទឹក គឺអាចបង្ហាញពីការអនុវត្តអនាម័យប្រចាំថ្ងៃ និងមូលហេតុដែលនាំឲ្យមានជម្ងឺផ្សេងៗផងដែរ។ តាមលទ្ធផលនៃការសិក្សាបានបង្ហាញថា គ្រួសារចំនួន ៧៣,៩% មិនបានធ្វើការសម្អាតទឹកសម្រាប់បរិភោគប្រចាំថ្ងៃនោះទេ នៅខណៈដែលគ្រួសារចំនួន ១៩,៦% ដែលបរិភោគទឹកដាំពុះ និង ៦,៥% ប៉ុណ្ណោះដែលចម្រោះទឹកមុនពេលបរិភោគ។ ផ្ទុយទៅវិញ ប្រភពទឹកដែលពួកគាត់បរិភោគ និងប្រើប្រាស់ប្រចាំថ្ងៃ មានប្រភពមកពី ទឹកភ្លៀង ទឹកស្ទឹង/អូរ ទឹកបឹង/ស្រះ ទឹកអណ្តូងលូ និងទឹកអណ្តូងជីក ដែលភាគច្រើនប្រភពទឹកទាំងនេះ ជាប្រភពទឹកដែលមិនស្អាតហើយអាចបង្ករជាជម្ងឺផ្សេងៗបាន។




ក្រាហ្វិក៥.១៩៖ វិធីសាស្ត្រសម្អាតទឹករបស់ប្រជាជននៅក្នុងឃុំខ្វាវ

#### ខ. ការប្រើប្រាស់បង្គន់អនាម័យ

ការប្រើប្រាស់បង្គន់អនាម័យ អាចបង្ហាញឲ្យឃើញអំពីសុខភាព អនាម័យ និងសោភ័ណភាពនៅក្នុងតំបន់។ ក្នុងករណីដែលប្រជាជនបានអនុវត្តន៍អនាម័យ ដោយបន្ទោបង់នៅក្នុងបង្គន់អនាម័យនោះមានន័យថា ការអនុវត្តអនាម័យរបស់ពួកគាត់មានភាពល្អប្រសើរ និងមិនអាចបង្ករហេតុប៉ះពាល់ដល់សុខភាពឡើយ។ យោងតាមលទ្ធផលនៃការសិក្សាបានបង្ហាញថា គ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ប្រចាំថ្ងៃមានត្រឹមតែ ៥,៥% (ប្រភេទបង្គន់ចាក់ទឹក) ខណៈដែលគ្រួសារដែលគ្មានបង្គន់អនាម័យ

ប្រើប្រាស់មានរហូតដល់ ៩៤,៦% នៃ៩២គ្រួសារដែលបានធ្វើបទសម្ភាសន៍។ ចំពោះគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ទាំងអស់ ពួកគាត់ភាគច្រើនទៅបន្ទោរបង់នៅក្នុងព្រៃជិតផ្ទះ (៣៩%) ជីកកប់ (៥៩,៤%) និងប្រើប្រាស់បង្គន់ជាមួយអ្នកជិតខាង (១,៦%)។ លទ្ធផលនេះយើងឃើញថា ប្រជាជននៅក្នុងឃុំខ្វាវ ប្រឈមមុខទៅនឹងបញ្ហានៃការអនុវត្តអនាម័យ និងការខ្វះខាតបង្គន់អនាម័យប្រើប្រាស់។ បញ្ហានេះច្រើនបណ្តាលមកពីកត្តាជីវភាពកម្រិតនៃការអប់រំទាប និងការយល់ដឹងរបស់ប្រជាជននៅមានកម្រិត ដែលជាហេតុធ្វើឲ្យពួកគាត់ប្រឈមមុខទៅនឹងជម្ងឺផ្សេងៗ ដែលទាក់ទងទៅនឹងសុខភាពអនាម័យខ្លួនប្រាណរបស់ពួកគាត់ទាំងអស់គ្នា។

តារាង៥.៣៤៖ ប្រភេទថាមពលដែលប្រើសម្រាប់បំភ្លឺក្នុងគេហដ្ឋាននៅក្នុងឃុំខ្វាវ

| ល.រ | ការប្រើប្រាស់បង្គន់ | ចំនួនគ្រួសារ | ភាគរយ(%) |
|---|---|---|---|
| ១ | មាន | ៥ | ៥,៤ |
| ២ | គ្មាន | ៨៧ | ៩៤,៦ |
| សរុប | | ៩២ | ១០០ |




ក្រាហ្វិក៥.១៥៖ ភាគរយនៃការបន្ទោបង់របស់គ្រួសារដែលគ្មានបង្គន់ប្រើប្រាស់

## គ. ស្ថានភាពសំណល់រឹង និងរាវ

### គ.១ បរិមាណសំណល់

តាមរយៈការសម្ភាសប្រជាជនចំនួន ៩២ គ្រួសារនៅក្នុងឃុំខ្វាវ សង្កេតឃើញថា បរិមាណសំណល់ដែលបានបញ្ចេញនៅក្នុងមួយថ្ងៃៗ មានបរិមាណតិចប៉ុណ្ណោះគឺប្រមាណជា ០.១គ.ក ទៅ ០.៣ គ.ក រឺតិចជាងនេះ។ មូលហេតុនៃការបញ្ចេញសំណល់តិចបែបនេះ ដោយសារតែសេដ្ឋកិច្ចរបស់ប្រជាជននៅក្នុងភូមិមានលក្ខណៈមិនសូវល្អប្រសើរទេ។ ដោយសារនៅក្នុងគ្រួសារនីមួយៗមានប្រាក់ចំណូលស្មើរនឹងប្រាក់ចំណាយ។

### គ.២ សមាសធាតុនៃសំណល់

ចំពោះសំណល់រឹងភាគច្រើន គឺមានសំណល់សរីរាង្គ ដែលមានសំណល់អាហារ បន្លែ និងសំណល់ផ្លែឈើ រួមជាមួយនឹងសំណល់ប្លាស្ទិកខ្លះៗ។ ចំណែកឯសំណល់រាវ មានប្រភេទសំណល់រាវផ្ទះបាយ បោកគក់ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ។

### គ.៣ ការគ្រប់គ្រងសំណល់

ចំពោះការគ្រប់គ្រងសំណល់រឹង ដែលបានបញ្ចេញពីសកម្មភាពប្រចាំថ្ងៃ ប្រជាជនគ្រប់គ្រងដោយប្រើវិធីសាស្ត្រ កប់ឬដុតនៅក្បែផ្ទះ។ ចំណែកឯសំណល់ផ្ទះបាយ យកទៅធ្វើជាចំនីសត្វ ឬធ្វើជាជីកំប៉ុស្តិ៍សម្រាប់ដាំដំណាំ។

## ឃ. បញ្ហាសុខភាព

នៅក្នុងឃុំខ្វាវ មានមណ្ឌលសុខភាពចំនួនមួយកន្លែងដែលអាចផ្តល់ភាពងាយស្រួលដល់ប្រជាជននៅក្នុងឃុំ ដើម្បីទទួលបានសេវាសុខភាពនៅក្នុងសហគមន៍របស់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីដែលមានជម្ងឺធ្ងន់ធ្ងរពួកគាត់ទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្ត ឬទៅមន្ទីរពេទ្យឯកជនមួយចំនួន។ តាមលទ្ធផលបានបង្ហាញថា ប្រជាជនភាគច្រើន ច្រើនតែកើតមានជម្ងឺមួយចំនួនដូចជាៈ ជម្ងឺប្រដាប់រំលាយអាហារ ផ្លូវដង្ហើម សើរស្បែក គ្រុនក្តៅ គ្រុនឈាម គ្រុនចាញ់ គ្រុនផ្តាសាយ ឈឺក្បាល ចុកពោះ រាគរូស ចុកដៃជើង និងជម្ងឺផ្សេងៗ។ ក្នុងចំណោមប្រភេទជម្ងឺទាំងនេះ មានប្រភេទជម្ងឺមួយចំនួនបណ្តាលមកពី ការបរិភោគចំនីអាហារ បញ្ហាអាកាសធាតុ និងជាពិសេសដោយសារការអនុវត្តអនាម័យប្រចាំថ្ងៃ។ តាមទិន្នន័យបានបង្ហាញថា ប្រជាជនភាគច្រើនមានជម្ងឺផ្តាសាយដែលមាន ៣០,៥% ជម្ងឺគ្រុនក្តៅមាន ២៣,៧% និងជម្ងឺរាគរូសមាន ១០,៩% នៃប្រជាជនដែលបានសម្ភាសន៍។ ជាងនេះទៅទៀត ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរៀបចំទុកដាក់មើលថែរក្សាគ្រួសារ ជាពិសេសទៅលើបញ្ហាសុខភាពប្រចាំថ្ងៃ ទោះបីជាពួកគាត់ទទួលបានការអប់រំ និងយល់ដឹងតិចតួចក៏ដោយ។ ជាក់ស្តែងអ្នកឆ្លើយតបប្រមាណ ៧៣.៩% (ក្រាហ្វិក៤.១៥) នៃអ្នកឆ្លើយតបនៅក្នុងឃុំខ្វាវ បរិភោគទឹកឆៅ ដោយមិនបានធ្វើការសំអាតជាមុនឡើយ។ លើសពីនេះ

ប្រភពទឹកដែលពួកគាត់បរិភោគប្រចាំថ្ងៃ ភាគច្រើនជាប្រភពទឹកដែលមិនស្អាតដូចជាៈ ទឹកភ្លៀង ទឹកអូរ បឹង ស្ទឹង និងស្រះជាដើមដែលសំបូរទៅដោយមេរោគផ្សេងៗដែលអាចបង្ករជាជម្ងឺ។




ក្រាហ្វិក៥.១៦៖ ប្រភេទជម្ងឺរបស់ប្រជាជននៅក្នុងឃុំខ្វារ

### ៥.៤.២.១១ យេនឌ័រ

តាមរយៈការចុះសិក្សាដោយផ្ទាល់នៅក្នុងឃុំខ្វារបានបង្ហាញថា ការចូលរួមរបស់ស្ត្រីមានអត្រាខ្ពស់ជាងបុរស។ ជាក់ស្តែង នៅក្នុងចំណោម ៩២ គ្រួសារ ដែលក្រុមការងារបានធ្វើបទសម្ភាសន៍ មានស្ត្រីចូលរួមចំនួន ៦៨% នៅខណៈដែលបុរសមានត្រឹមតែ ២៥% ប៉ុណ្ណោះដែលបានចូលរួម។ ទន្ទឹមនឹងនោះ ស្ត្រីនៅក្នុងឃុំខ្វារមានសកម្មភាពក្នុងការរកប្រាក់ចំនូល ដើម្បីផ្គត់ផ្គង់នៅក្នុងគ្រួសារគួរឲ្យកត់សំគាល់។ ក្នុងនោះស្ត្រីចំនួន ៨៦,៧៦% ប្រកបមុខរបរ កសិកម្ម ៤,៤១% ជាសិប្បករ ចំនួន ១,៤៧% ជាអាជីវកម្មចំនួន ១,៤៧% និងធ្វើការងារផ្សេងៗមាន ៥,៨៨% ។ លើសពីនេះទៅទៀត តាមទិន្នន័យក៏បានបង្ហាញផងដែរថា ក្នុងចំណោមអ្នកចូលរួមទាំងអស់មានភាគរយស្ត្រីជាមេគ្រួសារ រហូតដល់ ៤៦,៥១ % ដែលប្រហាក់ប្រហែលគ្នាទៅនឹងបុរសដែលមាន ៥៣,៤៩%។ លើសពីនេះទៅទៀត ស្ត្រីនៅក្នុងឃុំក៏បានចូលរួមនៅក្នុងសកម្មភាពផ្សេងៗ និងកិច្ចអភិវឌ្ឍន៍សង្គមផងដែរ។ បើតាមការសាកសួរជាមួយ លោកមេឃុំខ្វារបានឲ្យដឹងថា ស្ត្រីបានបំរើដល់វិស័យអប់រំមានចំនួន រហូតដល់ ៤៣នាក់ ក្នុងចំណោមគ្រូបង្រៀនសរុប ៧៦នាក់ និងបានបំរើដល់វិស័យសុខាភិបាលចំនួន ២នាក់ផងដែរ។ ចំណែក

ឯនៅក្នុងវិស័យអប់រំវិញ សង្កេតឃើញថា ចំនួនស្ត្រីនៅក្នុងឃុំបានចូលរៀននៅថ្នាក់បឋមសិក្សា និងថ្នាក់អនុវិទ្យាល័យមានចំនួនច្រើន។ ជាក់ស្តែងមានស្ត្រីចំនួន ៣៥,២៩% បានចូលរៀននៅថ្នាក់បឋមសិក្សា ចំនួន ១០,២៩%បានចូលរៀននៅថ្នាក់អនុវិទ្យាល័យ និងចំនួន ៧,៣៥% អាចអាន និងសរសេរបាន។ ម្យ៉ាងវិញទៀត នៅក្នុងឃុំទាំងមូលគ្មានការប្រព្រឹត្តនូវអំពើហិង្សានៅក្នុងគ្រួសារឡើយ ដោយសារតែស្ត្រីនៅក្នុងភូមិមានភាពរឹងមាំ ហើយពួកគាត់ក៏មានចំនេះដឹងគ្រប់គ្រាន់ដែលអាចជៀសវាងការប្រព្រឹត្តអំពើទាំងនេះបាន។

### ៥.៤.២.១២ ស្ត្រី និងការប្រែប្រួលអាកាសធាតុ

### ក. ផលវិបាកនៃការប្រែប្រួលអាកាសធាតុ

ការកើនឡើងនូវកំដៅផែនដី និងគ្រោះមហន្តរាយធម្មជាតិដូចជា ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត និងកំនើននីវ៉ូទឹកសមុទ្រ ត្រូវបានគេព្យាករណ៍ទុកថា នឹងអាចធ្វើឲ្យមានបញ្ហាដែលទាក់ទងទៅនឹងការបំពុលទឹក និងបញ្ហាសន្តិសុខស្បៀង ដែលគំរាមកំហែងដល់សុខភាពមនុស្ស និងសកម្មភាពរស់នៅប្រចាំថ្ងៃ ជាពិសេសក្រុមដែលងាយរងគ្រោះ (CDRI, 2014 cited in Bates et al., 2008 ; UC,2009)។ តែទោះជាយ៉ាងណាក៏ដោយ ឃុំខ្វាវគឺជាឃុំមួយដែលស្ថិតនៅតំបន់ភ្នំ និងនៅក្បែរដែនជំរកសត្វព្រៃបឹងពែរ ដែលសំបូរទៅដោយព្រៃឈើ ដែលជាប្រភពទាក់ទាញទឹកភ្លៀង និងអាចការពារគ្រោះមហន្តរាយធម្មជាតិផ្សេងៗបាន។ ដូច្នេះប្រជាជននៅក្នុងតំបន់ ជាពិសេសស្ត្រី ពុំសូវប្រឈមមុខខ្លាំងទៅលើបញ្ហាការប្រែប្រួលអាកាសធាតុទេ។

ជាទូទៅប្រជាជននៅក្នុងឃុំខ្វាវ ភាគច្រើនប្រកបមុខរបរកសិកម្ម និងប្រកបការងារក្រៅពីកសិកម្មមួយចំនួនដូចជា៖ លក់ដូរ សិប្បករ និងកម្មករនៅក្រុមហ៊ុនដាំកៅស៊ូ។ ជាក់ស្តែងតាមលទ្ធផលនៃការសិក្សាបានបង្ហាញឲ្យឃើញថា ប្រជាជនរហូតដល់ ៨៨% ប្រកបរបរកសិកម្ម ក្នុងនោះមានស្ត្រី រហូតដល់ ៨៦,៧៦%។ នៅក្នុងឃុំនេះក៏មានក្រុមហ៊ុនបានធ្វើការអភិវឌ្ឍ លើដំណាំកសិឧស្សាហកម្មកៅស៊ូ គឺក្រុមហ៊ុន ខេន និងក្រុមហ៊ុនសោភ័ណ្ឌភារី អភិវឌ្ឍន៍លើដំណាំចន្ទី ដែលគ្របដណ្តប់លើផ្ទៃដីជាង ១០០០ ហិកតា។ ក្រុមហ៊ុនទាំងពីរនេះបានបង្ករលក្ខណៈងាយស្រួលដល់ប្រជាជននៅក្នុងតំបន់ ជាពិសេសស្ត្រីក្នុងការរកប្រាក់ចំនូលបន្ថែមចូលគ្រួសារក្រៅពីការធ្វើកសិកម្ម។

### ខ. ប្រព័ន្ធធារាសាស្ត្រ និងប្រភពទឹក

តំបន់គម្រោងជាតំបន់ភ្នំដែលជាផ្ទៃរងទឹកភ្លៀងដ៏សំខាន់ ដូច្នេះវាជាប្រភពទឹកដ៏សំខាន់ផងដែរសម្រាប់ស្ទឹង និងអូរផ្សេងៗនៅក្បែរតំបន់គម្រោង។ ស្ទឹង និងអូរសំខាន់ៗនៅក្បែរតំបន់គម្រោងមានដូចជា៖ អូរខ្វាវ បឹងឈ្នួន អូរបើក អូរស្រែដម អូរបាក់រនាស់ និងជាពិសេសស្ទឹង

ដីក្រែងដែលជាស្ទឹងមេដ៏ចំបងមួយក្នុងការទ្រទ្រង់ដល់ វិស័យកសិកម្ម និងសកម្មភាពប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងតំបន់។ នៅក្នុងតំបន់គម្រោងស្ថិតនៅតំបន់ភ្នំដែលសណ្ឋានដីមានលក្ខណៈជាទីជំរាល ជាខ្សែទឹកហូរពីលើចុះមកផ្នែកខាងក្រោម និងហូរចូលស្ទឹង អូរ និងត្រពាំងតូចធំជាច្រើន ដែលខ្លះអាចរីងនៅរដូវប្រាំង និងខ្លះទៀតមិនរីងស្ងួតពេញមួយឆ្នាំ។

# ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈ ដែលមានស្រាប់ក្នុងតំបន់

Draft

## ៥.៥ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ក្នុងតំបន់

### ៥.៥.១ ផ្លូវគមនាគមន៍

ឃុំខ្វាវ មានផ្លូវលំចំនួន ៨ខ្សែ ដែលមានប្រវែងសរុប ១៣៥០១គ.ម ហើយភាគច្រើនជាផ្លូវប្រភេទគ្រួសក្រហមមានសភាពទ្រុឌទ្រោម និងហុយ។ ផ្លូវក្រាលគ្រួសក្រហម១ខ្សែចេញពីភូមិបាយអរ ទៅភូមិអូរ ក៏សាងដោយក្រុមហ៊ុន ខាំ សុមេធ ចំណែក១ខ្សែទៀតចាប់ពីភូមិស្រោងកាត់តាមភូមិព្រះធាតុ ត្រូវបានក៏សាងដោយអង្គការ ឯផ្លូវ២ខ្សែផ្សេងទៀត ក៏សាងដោយមូលនិធិឃុំ គឺ១ខ្សែទៅភូមិអូរ និង១ខ្សែទៅខ្វាវ។ បច្ចុប្បន្នផ្លូវក្រាលកៅស៊ូ ១ខ្សែកំពុងស្ថាបនាដែលមានទំហំទទឹង ៦ម សាងសង់ដោយ កងវិស្វកម្មកងទ័ពជើងគោកនៅឆ្នាំ ២០១៣-២០១៤ ដែលស្ថិតនៅក្នុងភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង។



រូបភាព៥.៣៤៖ ការដ្ឋានសាងសង់ផ្លូវក្រាលកៅស៊ូ ស្ថិតនៅភូមិខ្វាវ

ការក៏សាងផ្លូវក្រាលកៅស៊ូនេះគឺមានសារៈសំខាន់ដើម្បីៈ

- → សម្រួលដល់ការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋក្នុងភូមិ ភ្ញៀវទេសចរណ៍ វិនិយោគិន ចេញចូល និងទស្សនាក្នុងតំបន់។
- → សម្រួលដល់ប្រជាជន និងវិនិយោគិន នាំចេញនាំចូលធនធាន និងផលិតផល ទិន្នផលកសិកម្ម ជាពិសេសផលិតផលស្រូវ។

→ ការពារមិនឱ្យឆាប់ខូច និងពិសេសកាត់បន្ថយការហុយដែលអាចប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋក្នុងតំបន់។

ចំពោះភូមិខ្វារ កំពុងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញទូរស័ព្ទ សាលារៀន និងមណ្ឌលសុខភាព។ ផ្លូវលំមាន ២ខ្សែគឺ ទី១ មានប្រវែង ២គ.ម ដែលស្ថិតនៅក្នុងភូមិ និងមួយខ្សែទៀតមានប្រវែង ៨គ.ម ដែលចេញពីភូមិខ្វារទៅភូមិចុងស្ពាន។

ចំណែកឯភូមិចុងស្ពាន មានបណ្តាញផ្លូវលំប្រវែង ៦០០ម ដែលសាងសង់នៅឆ្នាំ២០០៧ ដោយក្រុមហ៊ុន ខាំ សុមេធ។ លើសពីនេះ សហគមន៍បានក៏សាងផ្លូវលំចំនួន ១ខ្សែដោយខ្លួនឯងទៅសាលារៀនដែលមានប្រវែង ១គ.ម និងមានផ្លូវ ១ខ្សែទៀតមានប្រវែង ១៧គ.ម ដែលជាប្រភេទផ្លូវរទេះ។ នៅពេលបច្ចុប្បន្ន ភូមិនេះមិនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នៅឡើយទេ ដូចជា ផ្លូវថ្នល់ បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញលូទឹកសំអុយ សាលារៀន មណ្ឌលសុខភាព និងប្រព័ន្ធធារាសាស្ត្រ។



រូបភាព៥.៣៥៖ ផ្លូវថ្នល់ក្រាលក្រួសក្រហម ស្ថិតនៅភូមិខ្វារ

ចំណែកឯនៅក្នុងភូមិរវៀង មានផ្លូវលំចំនួន ១ខ្សែ ដែលមានប្រវែង ១៨៧០ម ទំហំ ៥ម ដែលជាប្រភេទផ្លូវក្រាលគ្រួសក្រហម។ លើសពីនេះ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធនានា ក្នុងភូមិមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ។ ជាពិសេស ចំពោះបណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញលូទឹកសំអុយ បណ្តាញទូរស័ព្ទមណ្ឌលសុខភាពនិងប្រព័ន្ធធារាសាស្ត្រ។

## ៥.៥.២ បណ្ដាញទឹកស្អាត

ក្នុងឃុំខ្វាវមានបណ្ដាញទឹកស្អាតមួយកន្លែង ដែលបានស្ថាបនាដោយអង្គការ និងសហគមន៍នៅក្នុងភូមិ មានលក្ខណៈជាអាងបេតុងមានទំហំ ៣x៣ម ដែលបានកសាងឡើងក្នុងឆ្នាំ ២០០៣។ នៅពេលបច្ចុប្បន្ន បណ្ដាញនេះបានគ្រប់គ្រងដោយភ្នាក់ងារឯកជន ដែលផ្គត់ផ្គង់នៅក្នុងតម្លៃ ១៥០០រៀល/ម៣។ ប៉ុន្តែបណ្ដាញទឹកស្អាតនេះមិនបានផ្គត់ផ្គង់ដល់ភូមិចុងស្ពាន និងភូមិរវៀងទេ ពោលគឺបណ្ដាញទឹកនេះគ្របដណ្ដប់បានតែមួយផ្នែកនៅក្នុងភូមិខ្វាវតែប៉ុណ្ណោះ។ ម៉្យាងទៀត ប្រព័ន្ធទឹកស្អាតសហគមន៍នៅមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ទឹកស្អាតដែលមានគុណភាពល្អ និងសុវត្ថិភាពខ្ពស់នៅឡើយទេ។ ប៉ុន្តែប្រជាជនមួយចំនួនតូច ក៏បានស្តុកទឹកភ្លៀងទុកប្រើប្រាស់សម្រាប់ហូបក្នុងរដូវប្រាំង និងរដូវវស្សាផងដែរ។



រូបភាព៥.៣៦៖ អាងផ្គត់ផ្គង់ទឹកស្អាតក្នុងភូមិខ្វាវ

ចំណែកឯប្រជាជនក្នុងភូមិចុងស្ពាន និងភូមិរវៀងភាគច្រើនប្រើប្រាស់អណ្ដូងជីកដៃ និងស្រះទឹករួមសម្រាប់បំពេញតម្រូវការមូលដ្ឋានរបស់គាត់។ ការប្រើប្រាស់នេះរួមមានការទទួលទាន ការចំអិនអាហារ ងូត បោកគក់ និងស្រោចស្រពដំណាំជាដើម។ នៅក្នុងឃុំនេះ មានប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលមានពាង សម្រាប់ស្តុកទឹកភ្លៀងទុកហូប និងប្រើប្រាស់ទាំងរដូវប្រាំង និងរដូវវស្សា។



រូបភាព៥.៣៧៖ អណ្តូងលូប្រើប្រាស់រួមរបស់ប្រជាជន ស្ថិតនៅភូមិខ្វារ

ចំពោះភូមិខ្វារ ប្រជាជនដែលមានទីតាំងជិតផ្សារអាចទទួលសេវាកម្មទឹកស្អាតបាន ប៉ុន្តែប្រជាពលរដ្ឋមួយចំនួន បានប្រើប្រាស់ទឹកភ្លៀងដែលស្តុកទុកពីរដូវវស្សា ដើម្បីទុកហូប និង ប្រើប្រាស់ទឹកអណ្តូងលូរួម ដោយសារអណ្តូងលូមានភាពថ្លារស្អាតជាងប្រព័ន្ធទឹកស្អាត។

Draft



រូបភាព៥.៣៨៖ អណ្តូងលូសាធារណៈរបស់ប្រជាជន ស្ថិតនៅភូមិខ្វារ

## ៥.៥.៣ បណ្តាញអគ្គិសនី

ឃុំខ្វារមានបណ្តាញអគ្គិសនីគ្របដណ្តប់ពីរភូមិ គឺភូមិខ្វារ និងភូមិព្រះធាតុ។ បច្ចុប្បន្នបណ្តាញអគ្គិសនីនេះបានផ្គត់ផ្គង់ ៨៣៨គ្រួសារ ដោយមិនរាប់បញ្ចូលម៉ាស៊ីនភ្លើងផ្ទាល់ឯកជន។ លើសពីនេះ គ្រួសារប្រើប្រាស់អាគុយមាន ១៣០០គ្រួសារ និងគ្រួសារប្រើប្រាស់ចន្លុះ ទៀន និងចង្កៀងប្រេងកាតមាន ៣៩៨គ្រួសារ។ ចំណែកឯភូមិខ្វារ គឺជាភូមិមួយដែលមានការផ្គត់ផ្គង់ថាមពលអគ្គិសនី

ដោយភ្នាក់ងារឯកជន ដែលផ្គត់ផ្គង់បានក្នុងរយៈពេល ២៤ម៉ោង/ថ្ងៃ នៅក្នុងតម្លៃ ៣៥០០រៀល/KWH ។ តាមការផ្ដល់ព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋានបានឲ្យដឹងថា នៅពេលបច្ចុប្បន្ននេះ មានប្រជាជនចំនួន ២១០គ្រួសារ ដែលប្រើប្រាស់បណ្ដាញអគ្គិសនី និងប្រើប្រាស់អាគុយមាន ១០២គ្រួសារ ចំណែកគ្រួសារប្រើប្រាស់ចន្លុះ ទៀន និងចង្កៀងប្រេងកាតមាន ៣៦៦គ្រួសារ។



រូបភាព៥.៣៩៖ បណ្ដាញអគ្គិសនីផ្គត់ផ្គង់ប្រជាជន ស្ថិតក្នុងភូមិខ្វារ

ចំណែកភូមិចុងស្ពាន មិនទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីឡើយ។ ប្រជាជននៅទីនោះភាគច្រើនប្រើប្រាស់អាគុយ ដែលមានប្រមាណជា ៩០% ចំណែកការប្រើប្រាស់ចន្លុះ ទៀន និងចង្កៀងប្រេងកាតប្រមាណ ១០% និង ប្រជាជនប្រើប្រាស់ថាមពលព្រះអាទិត្យមាន ២គ្រួសារផងដែរ។ រីឯនៅក្នុងភូមិរវៀង ក៏គ្មានថាមពលអគ្គិសនីសម្រាប់ផ្គត់ផ្គង់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ ដោយសារការគ្មានថាមពលអគ្គិសនីគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់។ ម៉្យាងវិញទៀត ជីវភាពរបស់ប្រជាជននៅក្នុងតំបន់ក៏គ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីរ៉ាប់រងការចំណាយទៅលើការប្រើប្រាស់ថាមពលអគ្គិសនីបានផងដែរ។ ដូច្នេះទើបប្រជាជនចំនួន ៧៥% ប្រើប្រាស់ចន្លុះ ទៀន និងចង្កៀងប្រេងកាត និងប្រមាណ ២៥% ប្រើប្រាស់អាគុយ ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### ៥.៥.៤ បណ្តាញទូរគមនាគមន៍

ឃុំខ្វាវ គឺជាឃុំមួយដែលគ្មានវិស័យទូរគមនាគមន៍ ដែលរួមបញ្ចូលទាំងប៉ុស្តិ៍ប្រៃសណីយ៍ និងប្រព័ន្ធអ៊ីនធើណេតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃឡើយ។ នៅក្នុងឃុំមានតែបណ្តាញទូរស័ព្ទចំនួន៤ ខ្សែសម្រាប់ប្រើប្រាស់ ដែលបណ្តាញទូរស័ព្ទនេះបានក៏សាងឡើងនៅក្នុងឆ្នាំ ២០០៩។ ចំណែកឯភូមិចុងស្ពាន មានបណ្តាញទូរស័ព្ទរបស់ក្រុមហ៊ុន Metfone ដែលបានបង្កើតបណ្តាញទូរស័ព្ទថ្មីមួយបន្ថែមទៀតនៅក្នុងភូមិ ដើម្បីពង្រីកតំបន់សេវារបស់ខ្លួនឲ្យកាន់តែមានភាពទូលំទូលាយ និងគ្របដណ្តប់នៅពេញផ្ទៃប្រទេសកម្ពុជា។ រីឯក្នុងភូមិរវៀង មានបណ្តាញទូរស័ព្ទគ្រប់ប្រព័ន្ធ ប៉ុន្តែពុំសូវមានសេវាល្អទេ។



រូបភាព៥.៤០៖ ខ្សែបណ្តាញប្រព័ន្ធទូរស័ព្ទ ក្រុមហ៊ុន Metfone ក្នុងភូមិខ្វាវ

## ៥.៦ សេវាកម្មសាធារណៈ

### ៥.៦.១ សេវាកម្មរដ្ឋបាលសាធារណៈ

យោងតាមប្រកាសរបស់អន្តរក្រសួងលេខ ៣៨៥៦ ប្រ.ក ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ និងតម្លៃសមរម្យ បច្ចុប្បន្ននេះឃុំខ្វាវ បានបម្រើសេវាមិនគិតថ្លៃដូចជា ការចុះសំបុត្រកំណើត សំបុត្រអាពាពិពាហ៍ សំបុត្រមរណៈភាព និងសេវាផ្សេងៗទៀតដោយឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋ។ កាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឃុំខ្វាវ បានទទួលប័ណ្ណសរសើរប្រភេទលេខ១ អំពីលក្ខណៈសម្បត្តិភូមិឃុំមានសុវត្ថិភាពដែលបានផ្តល់ដោយឯកឧត្តម ស ខេង ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ៥.៦.២ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

ក្រៅពីសេវាកម្មរដ្ឋបាលសាធារណៈ ឃុំខ្វាវក៏មានប៉ុស្តិ៍នគរបាលរដ្ឋបាលមួយកន្លែង ដែលអាចជួយការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងឃុំ។ ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថានៅក្នុងឃុំនេះពុំសូវមានបញ្ហាអសន្តិសុខនិងអសណ្តាប់ធ្នាប់អ្វីកើតឡើងនោះទេ។

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ គឺជាកត្តាដ៏សំខាន់ដែលជួយជំរុញឲ្យមានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតឲ្យមានភាពរីកចម្រើន។ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ត្រូវបានបង្កើតឡើងនៅក្នុងខែមិនា ឆ្នាំ ២០០៩។ នៅក្នុងឆ្នាំ ២០១០ រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់យកគោលការណ៍កសាងភូមិ ឃុំមានសុវត្ថិភាព ដើម្បីលើកកម្ពស់ និងជម្រុញចលនា ការពារសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈនៅគ្រប់ពេល ដែលមានគ្រប់ស្ថាប័នទាំងរដ្ឋ និងឯកជន ត្រូវរួមគ្នាពង្រឹងទូទាំងប្រទេស។

លក្ខណៈសម្បត្តិ៥យ៉ាង នៃភូមិ ឃុំមានសុវត្ថិភាពរួមមាន៖

→ គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

→ គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

→ គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សានៅក្នុងគ្រួសារ

→ គ្មានក្មេងទំនើង

→ គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។



រូបភាព៥.៩១៖ ប៉ុស្តិ៍នគរបាល រដ្ឋបាលខ្វាវ

## ៥.៦.៣ បញ្ហាមីន និងគ្រាប់មិនទាន់ផ្ទុះ

យោងតាមការសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជននៅក្នុងតំបន់បានឲ្យដឹងថា នៅតំបន់គម្រោងជាតំបន់ ដែលធ្លាប់បានញុំញីដោយសារសង្គ្រាមជាច្រើនទសវត្សមកហើយ ១៩៧០)-១៩៧៥១៩៧៥ ,-១៩៧៩ និង ១៩៧៩-១៩៩៨ (ដែលបានបន្សល់ទុកនូវគ្រាប់មីនដែលមិនទាន់ផ្ទុះជាច្រើននៅពាសពេញផ្ទៃដី។

តាមការវាស់វែងនៅក្នុងផែនទី បានបង្ហាញថា តំបន់ដែលមានគ្រាប់មីន រឺគ្រាប់មិនទាន់ផ្ទុះ មានចំងាយ ២,១ គ.ម ពីទីតាំងរោងចក្រ។ ចំណែកឯ ពីតំបន់ដែលមានគ្រាប់មីន ទៅមន្ទីរពិសោធន៍របស់ក្រុមហ៊ុន មានចំងាយ ១,៩ គ.ម និងមានចំងាយ ១.៦ គ.មពីការិយាល័យ។ តែទោះជាយ៉ាងណាក៏ដោយ ម្ចាស់គម្រោងអាជីវកម្ម បានសហការជាមួយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា CMAC ហើយបានធ្វើការបោសសម្អាតគ្រាប់មីនមិនទាន់ផ្ទុះនៅក្នុងតំបន់នោះ ដើម្បីការពារកុំឲ្យបង្កគ្រោះថ្នាក់ដល់បុគ្គលិក និងកម្មករនៅពេលកំពុងបំពេញការងារ។

Draft

ផែនទីបង្ហាញតំបន់មីនក្នុងគម្រោងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន MENG XIN HONG FA ( Cambodia ) Resources Investment Co., Ltd




រូបភាព៥.៤២៖ ផែនទីទីតាំងមីនក្នុងតំបន់គម្រោង

## ៥.៦.៤ សេវាអប់រំ

វិស័យអប់រំ ជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់បណ្តុះបណ្តាលធនធានមនុស្សទាំងចំណេះដឹង វប្បធម៌ ប្រពៃណីទំនៀមទំលាប់ និងសិល្បៈ។ ការអប់រំនេះត្រូវផ្តោតសំខាន់លើមូលដ្ឋានគ្រឹះដើម្បីពង្រឹងតាំងពីដំបូង ជាពិសេសកុមារដែលជាទំពាំងស្នងឬស្សីក្នុងការកសាង គ្រប់គ្រងប្រទេសជាតិឱ្យរីកចម្រើន និងគង់វង្ស។ ឃុំខ្នារ ក៏ដូចជាឃុំផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាដែរ មានការគិតគូរយ៉ាងខ្លាំងទៅលើវិស័យអប់រំ។ ទោះជាយ៉ាងណាក៏ដោយ ឃុំនេះគឺជាឃុំដែលពុំទាន់មានស្ថានភាពសេដ្ឋកិច្ចរីកចម្រើនលើគ្រប់វិស័យដូចនៅតំបន់ទីក្រុង និងទីប្រជុំជននោះទេ។ ជាក់ស្តែងតាមការធ្វើបទសម្ភាសន៍ជាមួយលោកមេឃុំខ្នារ បានឱ្យដឹងថាក្នុងឃុំមានសាលាបឋមសិក្សាចំនួន ៦ខ្នង (គ្រូបង្រៀន៧៦នាក់ និងសិស្ស២៥៦៥នាក់) និងអនុវិទ្យាល័យចំនួន១ខ្នង (គ្រូ ១០នាក់ និងសិស្ស ២៥០នាក់) និងគ្មានសាលាថ្នាក់វិទ្យាល័យទេ។ លើសពីនេះទៅទៀត សាលារៀនទាំងនេះ ជាប្រភេទបេតុង និងឈើដែលមានលក្ខណៈចាស់ និងមិនសូវមានផាសុខភាពប៉ុន្មាននោះទេ។







Draft



រូបភាព៥.៨៣៖ សាលារៀន នៅក្នុងឃុំខ្វារ

## ៥.៦.៥ សេវាសុខាភិបាល

សេវាសុខភាព គឺជាសេវាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ការរស់នៅរបស់មនុស្សទូទៅ។ តាមការចុះសិក្សាដោយផ្ទាល់បានឲ្យដឹងថា បច្ចុប្បន្ននេះ នៅក្នុងឃុំខ្វារ មានមណ្ឌលសុខភាពចំនួនមួយកន្លែងគឺ **មណ្ឌលសុខភាពខ្វារ**។ មណ្ឌលសុខភាពនេះមានទីតាំងស្ថិតនៅក្នុងភូមិខ្វារ ដែលជាទីតាំងល្អមួយសម្រាប់បម្រើសេវាកម្មដល់ប្រជាជននៅក្នុងឃុំ។ មណ្ឌលសុខភាពនេះមានទំហំ ៨មx១១ម ដែលសាងសង់ឡើងនៅក្នុងឆ្នាំ ១៩៩៧ ដោយរដ្ឋាភិបាល ដែលមានគ្រូពេទ្យចំនួន ០៥នាក់ ប្រចាំការសម្រាប់ព្យាបាលជូនប្រជាជន។ តាមរយៈការសម្ភាសជាមួយប្រជាជនទាំង៣ភូមិគឺ ភូមិខ្វារ ភូមិរវៀង និងភូមិចុងស្ពាន បានបង្ហាញថា នៅក្នុងចំណោមគ្រួសារដែលកើតមានជម្ងឺទាំងអស់ មានរហូតដល់ ៥៦,២% ដែលទៅព្យាបាលជម្ងឺនៅមណ្ឌលសុខភាព។ ប៉ុន្តែបើសិនជាក្នុងករណីធ្ងន់ធ្ងរ ពួកគាត់ក៏ទៅព្យាបាលនៅមន្ទីពេទ្យឯកជននៅក្នុងទីរួមខេត្តផងដែរ។ នៅក្នុងឃុំខ្វារក៏មានឱសថស្ថាន ១កន្លែងផងដែរ ដែលមានគ្រូពេទ្យចំនួន ០១នាក់ដែលនៅប្រចាំការ។



រូបភាព៥.៩៥៖ មណ្ឌលសុខភាពខ្វារ

## ៥.៦.៦ ជំនឿ សាសនា និងទីសក្ការៈបូជា

នៅក្នុងឃុំខ្វារ ប្រជាជនមានជំនឿទៅលើសាសនាព្រះពុទ្ធ។ តាមការចុះសិក្សាដោយផ្ទាល់បានឲ្យដឹងថា ប្រជាជននៅក្នុងឃុំស្ទើរតែទាំងអស់ ប្រកាន់ព្រះពុទ្ធសាសនា។ នៅក្នុងឃុំនេះមានវត្តអារាមចំនួន ២គឺ វត្តចាស់ និងវត្តព្រះធាតុ។ វត្តព្រះធាតុ គឺជាវត្តដ៏ស័ក្តសិទ្ធិមួយតាមជំនឿរបស់ប្រជាជនបានទៅធ្វើបុណ្យ និងបន់ស្រន់។ វត្តនេះជាវត្តបុរាណ ដែលមានប្រាសាទមួយនៅក្នុងនោះគឺប្រាសាទព្រះធាតុ។ ចំណែកឯវត្តចាស់ ជាវត្តបុរាណមួយដែលស្ថិតនៅក្នុងឃុំខ្វារ ប៉ុន្តែវត្តនេះត្រូវបានសាងសង់ជាថ្មីក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការបែកបាក់ខូចខាតទាំងស្រុង។ លើសពីនេះ ភូមិនីមួយៗក៏មានតួបអ្នកតាម្ចាស់ទឹកម្ចាស់ដី ដែលប្រជាពលរដ្ឋតែងតែទៅបន់ស្រន់ បួងសួង ដើម្បីសុំឲ្យជាសះស្បើយពីជម្ងឺនានា និងសុំលាភសក្ការៈផ្សេងៗជាដើម។

## ៥.៦.៧ ប្រាសាទបុរាណ

### ក. ប្រាសាទតាឥន្រ្ទ

ប្រាសាទតាឥន្រ្ទជាសំណង់ស្ថាបត្យកម្មខ្មែរ ស្ថិតក្នុងចន្លោះសតវត្សទី១១ និងទី១២ ដែលសោយរាជ្យដោយព្រះបាទសូរ្យវរ្ម័នទី២។ ប្រាសាទនេះមានទំហំ ៥x៥ម៉ែត្រ និងមានកំពស់ប្រហែល ៦ទៅ៧ ម៉ែត្រ ត្រូវបានសង់ឡើងដោយថ្មបាយក្រៀមជាគ្រឹះ និងថ្មភក់ជាតួជញ្ជាំង។

ប្រាសាទនេះមានទីតាំងនៅភូមិចុងស្ពាន ឃុំខ្វាវ ស្រុកជីក្រែង នៅត្រង់ផ្លូវកែងរវាងភូមិចុងស្ពាន និងផ្លូវចូលទៅក្នុងតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ត្រង់ចំណុចលេខ (។ ប្រាសាទនេះហ៊ុំព័ទ្ធជុំវិញទៅដោយចំការ និងផ្ទះរបស់ប្រជាជន ដែលមានចំងាយប្រហែលត្រឹមតែ ៨ ទៅ ១០ម៉ែតប៉ុណ្ណោះ។ តាមច្បាប់បេតិកភ័ណ្ឌ គ្រប់ប្រាសាទដែលបានរកឃើញទាំងអស់នៅទូទាំងប្រទេស ដែលមិនទាន់មានកំណត់ចុះបញ្ជីច្បាស់លាស់ ហើយស្ថិតនៅក្នុងការស្រាវជ្រាវតាមលក្ខណៈបុរាណវិទ្យា ត្រូវតែដកគំលាតយ៉ាងហោចណាស់ ៣០០ម៉ែតពីតួប្រាសាទ។



រូបភាព៥.៤៥៖ ប្រាសាទតាឥន្រ្ទ

Draft



រូបភាព៥.៤៦៖ ដីចម្ការ និងផ្ទះប្រជាជននៅជិតប្រាសាទតាឥន្ទ្រ

**ខ. ប្រាសាទប្រាំ**

ប្រាសាទប្រាំ ក៏ជាសំណង់ស្ថាបត្យកម្មខ្មែរ ដែលមានក្បូរក្បាច់រចនាល្អប្រណិត ប៉ុន្តែគួរឲ្យសោកស្តាយបំផុតពីព្រោះ តួប្រាសាទទាំងមូល មានសភាពបាក់បែក និងទ្រុឌទ្រោមខ្លាំងជាងប្រាសាទតាឥន្ទ្រទៅទៀត។ ប្រាសាទនេះមានទំហំស្រដៀងគ្នាទៅនឹងប្រាសាទតាឥន្ទ្រដែរគឺ ៥x ៥ ម៉ែត្រ និងមានកំពស់ប្រហែល ៣ ម៉ែត្រ ដែលត្រូវបានសង់ឡើងដោយថ្មបាយក្រៀមជាគ្រឹះ ជាតួជញ្ជាំង ។

ប្រាសាទប្រាំ មានទីតាំងនៅភូមិខ្វារ ឃុំខ្វារ ស្រុកជីក្រែង នៅតាមផ្លូវចូលទៅភូមិចុងស្ពាន និងតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ ប្រាសាទនេះហ៊ុំព័ន្ធជុំវិញទៅដោយដើមឈើ និងកូនរុក្ខជាតិតូចជាច្រើន មានចំងាយប្រមាណជា ៣០០ ទៅ ៤០០ម៉ែត្រពីផ្ទះ និងដីស្រែរបស់ប្រជាជន។



រូបភាព៥.៤៧៖ ប្រាសាទប្រាំ

## គ. ប្រាសាទល្បើក

ប្រាសាទល្បើក ជាប្រាសាទចំណាស់តូចមួយ ដែលបានបាក់បែកខូចទ្រង់ទ្រាយទាំងស្រុង នៅសល់តែផ្ទាំងថ្មមួយចំនួនប៉ុណ្ណោះ។ ប្រាសាទនេះមានទំហំប្រហែលជា ៤ x ៣ ម៉ែត និងមានកំពស់ប្រហែល ៣ ទៅ ៤ ម៉ែតដែលមានទីតាំងស្ថិតនៅក្នុងភូមិចុងស្ពាន ឃុំខ្វាវ ស្រុកជីក្រែង ស្ថិតនៅក្នុង ព្រៃយ៉ាងជ្រៅ ក្នុងតំបន់គម្រោងដែលពុំសូវមានគេបានស្គាល់ និងពុំធ្លាប់មានភ្ញៀវទេសចរណ៍មកទស្សនា

ឡើយ។ ប្រាសាទនេះធ្លាប់បានឮ និងស្គាល់តាមរយៈប្រជាពលរដ្ឋបានធ្លាប់ចូលទៅស្វែងរកអនុផលព្រៃឈើក្នុងតំបន់នោះ។ តាមគោលការណ៍នៃការធ្វើអាជីវកម្មរបស់ក្រុមហ៊ុន គឺទាមទារមិនឲ្យមានផលប៉ះពាល់ ឈូសឆាយ ប្រាសាទនេះទេ ។ ម៉្យាងទៀតក្រុមហ៊ុន ត្រូវសហការណ៍ជាមួយមន្ទីរទេសចរណ៍ និងមន្ទីរវប្បធម៌ ដើម្បី អភិរក្សប្រាសាទនេះ សម្រាប់ភ្ញៀវទេសចរណ៍មកទស្សនានាថ្ងៃអនាគត។



រូបភាព៥.៤៨៖ ប្រាសាទល្បើក

## ឃ. ប្រាសាទភ្នំដុប

ប្រាសាទនេះមានទីតាំងស្ថិតនៅក្នុងភូមិចុងស្ពាន ឃុំខ្វាវ ស្រុកជីក្រែង ក្រៅតំបន់គម្រោង។ ប្រាសាទនេះ ក៏ជាប្រាសាទបាក់បែកមួយដែរ ដែលមានទំហំប្រហែល ៥x៥ ម៉ែត កំពស់ប្រហែល ៥ ម៉ែត ធំជាងប្រាសាទល្បើក។ ប្រាសាទនេះស្ថិតនៅមិនឆ្ងាយពីភូមិប្រជាជនរស់នៅ ដែលមានការថែរក្សា និងអភិរក្សពី សំណាក់ប្រជាជននៅតំបន់នោះផងដែរ។ តាមការសម្ភាសន៍លោកប្រធានមន្ទីរវប្បធម៌ និងមន្ទីរទេសចរណ៍ នឹងមានផែនការអភិរក្សប្រាសាទនេះសម្រាប់ភ្ញៀវទេសចរណ៍មកទស្សនា។



រូបភាព៥.៥៩៖ ប្រាសាទភ្នំដុប

Draft

## ផែនទីបង្ហាញតំបន់ប្រាសាទនានា ក្នុងនិងក្បែរតំបន់គម្រោងអាជីវកម្មរ៉ែទង់ដែង




រូបភាព៥.៥០៖ ទីតាំងប្រាសាទក្នុងឃុំខ្នារ

### ៥.៥.៨ ស្ពានបុរាណ

ឃុំខ្វាវ មានស្ពានបុរាណជាច្រើនដូចជា៖ ស្ពានតាអុង ស្ពានតូច ស្ពានខ្វាវ ស្ពានភូមិអូរ ស្ពានថ្ម ស្ពានក្មេង និងស្ពានតាដៀវ។ ស្ពានទាំងនេះ ត្រូវបានកសាងឡើងកសាងឡើងនៅក្នុងអំឡុងសតវត្សទី១២នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ជាព្រះមហាក្សត្រដ៏ល្បីល្បាញរបស់ចក្រភពខ្មែរនាសម័យមហានគរ ដ៏រុងរឿង។ បច្ចុប្បន្ននេះស្ពានបុរាណទាំងនេះនៅតែបន្តបម្រើដល់ប្រជាជននៅក្នុងឃុំជាធម្មតា ប៉ុន្តែសម្រាប់រថយន្តធន់ធ្ងន់មិនត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់ឡើយ។ ដើម្បីការពារស្ពានបុរាណ និងថែរក្សាកេរ្តិ៍ដំណែលទាំងនេះឱ្យបានគង់វង្សយូរអង្វែង អាជ្ញាធរបានបោះបង្គោលបេតុងនៅលើផ្លូវចរាចរណ៍ខាងមុខស្ពានបុរាណ(ស្ពានតាអុង)សម្រាប់រារាំងរថយន្តធន់ធ្ងន់មិនឱ្យឆ្លងកាត់។




រូបភាព៥.៥១៖ ស្ពានតាអុង




រូបភាព៥.៥២៖ ស្ពានតូច ក្នុងភូមិចុងស្ពាន



រូបភាព៥.៥៣៖ ស្ពានតាជៀវ ក្នុងភូមិខ្វាវ

Draft

# ផែនទីបង្ហាញតំបន់ស្ពានបុរាណនានា ក្បែរតំបន់គម្រោងអាជីវកម្មរ៉ែទង់ដែង




| UTM | X | Y |
|---|---|---|
| Bay-Or Bridge | 434988 | 1483997 |
| Ta-Oung Bridge | 436196 | 1483529 |
| Touch Bridge | 439338 | 1483392 |
| Ta-Diev Bridge | 444623 | 1483252 |

រូបភាព៥.៥៤៖ ទីតាំងស្ពានក្នុងឃុំខ្វាវ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ការសិក្សាដីផ្ទះ ស្រែចំការ ក្លូង និងក្បែរតំបន់គម្រោង ធ្វើអាជីវកម្មរ៉ែទង់ដែង

# ការសិក្សាដីផ្ទះ ស្រែចំការ ភូមិ និងក្បែរតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង

| ទីតាំងទី ១ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង នៅប៉ែកខាងត្បូង តំបន់គម្រោងធ្វើអាជីវកម្មរ៉ែ មានចំងាយ ប្រហែល ២០០ ម៉ែតពីតំបន់គម្រោង។ |
| B | **ចំណុចនិយាម:** X: 443154, Y: 1483517 |
| ១ | **ឈ្មោះម្ចាស់ដី: ឈ្មោះ ជន ចយ** |
| ២ | **ទំហំដី:** ០,៥ ហិកតា |
| ៣ | **ស្ថានភាពដី:** ជាដីចម្ការថ្មីៗ និងមានព្រៃដែលពុំទាន់ទ្រួសត្រាយអស់នៅឡើយ។ |
| ៤ | **ស្ថានភាពដំណាំ:** មានដាំដំណាំដំឡូងមីថ្មីៗ មិនទាន់បានប្រមូលផលនៅឡើយទេ។ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** កាន់កាប់នៅឆ្នាំ ២០១៣ ដោយបានទទួលការវាស់វែងពីក្រុមយុវជនស្ម័គ្រចិត្ត និងប័ណ្ណកម្មសិទ្ធិបណ្ដោះអាសន្ន។ |



Draft

រូបភាព៥.៥៥៖ ស្ថានភាពដីចំការដំឡូងមីរបស់ឈ្មោះ ជន ចយ

| ទីតាំងទី ២ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅភូមិខ្ទារ ឃុំខ្ទារ ស្រុកជីក្រែង នៅប៉ែកខាងត្បូង ឆៀងខាងកើតតំបន់គម្រោងធ្វើអាជីវកម្មរ៉ែ ដែលមានចំងាយ ប្រហែល ២០០ ម៉ែតពីតំបន់គម្រោង។ |
| B | **ចំណុចនិយាម:** X: 442787, Y: 1483871 |
| ១ | **ឈ្មោះម្ចាស់ដី:** ឈ្មោះ អ៊ុយ ប៊ិន |
| ២ | **ទំហំដី:** ១,៥ ហិតា |
| ៣ | **ស្ថានភាពដី:** ជាដីផ្ទះ និងមានព្រៃដែលពុំទាន់ទ្រូសត្រាយអស់នៅឡើយ។ |
| ៤ | **ស្ថានភាពដំណាំ:** មិនមានដំណាំអ្វីគួឲ្យកត់សម្គាល់ទេ មានតែស្មៅ និងដើមឈើមួយចំនួន។ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** កាន់កាប់នៅឆ្នាំ ២០១៣ ដោយបានទទួលការវាស់វែងពីក្រុមយុវជនស្ម័គ្រចិត្ត និងប័ណ្ណកម្មសិទ្ធិបណ្តោះអាសន្ន។ |







រូបភាព៥.៥៦៖ ស្ថានភាពផ្ទះរបស់ឈ្មោះ អ៊ុយ ប៊ិន

| ទីតាំងទី ៣ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ឆៀងខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442660,Y: 1483858 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ២ ហិកតា |
| ៣ | **ស្ថានភាពដី:** ជាដីទំនេរ |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីដែលកាប់ទន្រ្ទានរួចប្រហែល ១ហិកតា គ្មានផ្ទះ និងចម្ការអ្វីឡើយ។ តាមការសាងសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ ក្នុងឆ្នាំ២០១៣។ |



រូបភាព៥.៥៧៖ ស្ថានភាពដី នៅចំណុចនិយាមកា(X: 442660,Y: 1483858)

| ទីតាំងទី ៤ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងកើត ឆៀងខាងត្បូង នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 443113 ,Y: 1484332 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |

| | |
|---|---|
| ២ | **ទំហំដី:** ១,៥ ហិកតា |
| ៣ | **ស្ថានភាពដី:** ជាដីទើបតែទន្រ្ទានថ្មីៗ |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីដែលកាប់ទន្រ្ទានរួចប្រហែល១,៥ ហិកតាគ្មានផ្ទះ និងចម្ការអ្វីឡើយ។ តាមការសាងសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ ក្នុងអំឡុងដើមឆ្នាំ២០១៤ នេះទេ។ |



រូបភាព៥.៥៨៖ ស្ថានភាពដីនៅចំណុចនិយាមកា (X: 443113 ,Y: 1484332)

| ទីតាំងទី ៥ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ឆៀងខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 443149 ,Y: 1484279 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** 30 x 40m |

| | |
|---|---|
| ៣ | **ស្ថានភាពដី:** ជាដីទើបតែទន្ទ្រានថ្មីៗ |
| ៤ | **ស្ថានភាពដំណាំ:** ដំណាំដំឡូងមី |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីប្រហែល 30 x 40m ជាដីចម្ការ ។ តាមការសាងសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្ទ្រាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្ទ្រានធ្វើជាចម្ការ ក្នុងឆ្នាំ ២០១៤។ |



រូបភាព៥.៥៩៖ ស្ថានភាពដំណាំដំឡូងមីនៅចំណុចនិយាមកា(X: 442836 ,Y: 1484259)

| ទីតាំងទី ៦ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ឆៀងខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442941 ,Y: 1484796 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ១,៥ ហិកតា |

| | |
|---|---|
| ៣ | **ស្ថានភាពដី:** ជាដីទើបតែទន្ទ្រានថ្មីៗគ្មានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** មានដើមឈើតូច ធំ មួយចំនួន និងគ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីដែលកាប់ទន្ទ្រានរួចប្រហែល១,៥ ហិកតាគ្មានផ្ទះ និងចម្ការអ្វីឡើយ។ តាមការសាងសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្ទ្រាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្ទ្រាន ក្នុងឆ្នាំ២០១៣ ។ |



រូបភាព៥.៦០៖ ស្ថានភាពដីនៅចំណុចនិយាមកា(X: 442941 ,Y: 1484796)

| **ទីតាំងទី ៧** | |
|---|---|
| A | **ទីតាំងដី:** នៅខាងលិចផ្លូវចូលទៅតំបន់គម្រោងអាជីវកម្មរ៉ែ។ |
| B | **ចំណុចនិយាម:** X: 442776 ,Y: 1485079 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ៧ ហិកតា |
| ៣ | **ស្ថានភាពដី:** ជាដីចម្ការចាស់ និងមានផ្ទះចាំចម្ការមួយខ្នង |

| | |
|---|---|
| ៤ | **ស្ថានភាពដំណាំ:** ដំណាំដំឡូងមី |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីដែលកាប់ទន្រ្ទានរួចចំនួន ៧ហិកតា មានផ្ទះចាំចម្ការមួយខ្នង និងចម្ការដំឡូងមី។ តាមការសាងសួរពត៌មានពីអ្នកចាំចម្ការបានឲ្យដឹងដឹងថា ម្ចាស់ដីនៅទីរួមខេត្តសៀបរាប ប៉ុន្តែមិនស្គាល់ឈ្មោះទេ។ ដីនេះដាំដំណាំបាន ២ ឆ្នាំរួចមកហើយ ដែលឆ្នាំទីមួយ ដាំសណ្តែក បន្ទាប់មកដាំដំឡូងមីបានប្រមូលផលម្តង និងកំពុងដាំលើកទី៣។ |







រូបភាព៥.៦១៖ ស្ថានភាពដីនៅចំណុចនិយាមកា(X: 442776 ,Y: 1485079)

| **ទីតាំងទី ៨** | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង នៅក្បែរកន្លែងជីកថ្មបាយក្រៀម។ |
| B | **ចំណុចនិយាម:** X: 442950 ,Y: 1486805 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ១ ហិកតា |

| | |
|---|---|
| ៣ | **ស្ថានភាពដី:** ជាដីចំណាស់ សំបូរទៅដោយថ្មបាយក្រៀម |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ស្ថានភាពផ្ទះ:** ផ្ទះស្បូវចំនួន ១៨ ខ្នង |
| ៦ | **ប្រវត្តិនៃការកាន់កាប់ដី ៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញការដ្ឋានជីកថ្មបាយក្រៀមមួយកន្លែង ដែលស្ថិតនៅប៉ែកខាងកើតនៃតំបន់គម្រោង និងមានកម្មករជីកថ្មចំនួន ១៨ គ្រួសារ និងផ្ទះចំនួន ១៨ ខ្នង សម្រាប់រស់នៅបណ្តោះអាសន្ន និងជីកថ្មបាយក្រៀម ។ តម្លៃពលកម្ម គិតទៅតាមចំនួនដុំថ្មដែលជីកបានគឺ ៥$ ( ២ម៉ឺនរៀល) ក្នុងមួយដុំ ដែលក្នុងមួយថ្ងៃពួកគាត់ជីកបាន ពី ១ ទៅ ៣ដុំ ប៉ុន្តែប្រសិនបើមានភ្លៀងធ្លាក់ ពួកគាត់មិនអាចជីកបានឡើយ។ |



រូបភាព៥.៦២៖ ស្ថានភាពផ្ទះកម្មករជីកថ្មបាយក្រៀម

Draft

| ទីតាំងទី ៩ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅក្បែរផ្ទះកម្មករជីកថ្មបាយក្រៀម ។ |
| B | **ចំណុចនិយាម:** X: 442929 ,Y: 1486990 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** មិនស្គាល់ទំហំ |
| ៣ | **ស្ថានភាពដី:** ជាដីព្រៃទើបតែរានថ្មីមិនមានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ស្ថានភាពផ្ទះ:** : ផ្ទះស្បូវទៀមនៅជាប់ដី |
| ៦ | **ប្រវត្តិនៃការកាន់កាប់ដី ៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទះ |

| | |
|---|---|
| | ស្បូវទៀមនៅជាប់ដីមួយខ្ទង នៅក្បែរការដ្ឋានជីកថ្មបាយក្រៀម ដែលស្ថិតនៅប៉ែកខាងកើតនៃតំបន់គម្រោង។ ដោយសារតែ មិនបានជួបជាមួយម្ចាស់ផ្ទះ ក្រុមការងារមិនទទួលបានពត៌មានលំអិត អំពីទំហំ និងប្រវត្តិកាន់កាប់ដីរបស់ម្ចាស់ផ្ទះទេ។ |



រូបភាព៥.៦៣៖ ស្ថានភាពដីនៅចំណុចនិយាមកា(X: 442929 ,Y: 1486990)

| ទីតាំងទី ១០ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅខាងកើតផ្លូវ ចូលទៅតំបន់ធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 443024 ,Y: 1487005 |
| ១ | **ឈ្មោះម្ចាស់ដី:** សាន សូរិយា |
| ២ | **ទំហំដី:** ១០ ហិកតា |
| ៣ | **ស្ថានភាពដី:** ដីថ្មី ទើបតែរាន មានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** បន្លែបន្តិចបន្តួច |
| ៥ | **ស្ថានភាពផ្ទះ៖** ផ្ទះឈើមួយខ្នង |
| ៦ | **ប្រវត្តិនៃការកាន់កាប់ដី៖** គ្រួសាររបស់ អ្នកមីង សាន សូរិយា មានស្រុកកំណើតនៅខេត្តកំពង់ធំ។ លុះមកឆ្នាំ ២០១៣ អ្នកមីងបានទិញដីពីម្ចាស់ដីនៅក្នុងតំបន់គម្រោងអាជីវកម្មរ៉ែ ក្នុងតម្លៃ ១៥០០ដុល្លា/ ហិកតា ដោយមិនបានដឹងថាដីនេះមានប៉ះពាល់ជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងនេះទេ។ បច្ចុប្បន្ននេះអ្នកមីង និងគ្រួសារបានផ្លាស់ទីលំនៅពីខេត្តកំពង់ធំ មកនៅលើដីរបស់ខ្លួន ដោយបានបានសង់ផ្ទះ និងកំពុងធ្វើការឈូសឆាយដី គ្រោងនឹងដាំដំឡូងមី។ |

Draft







រូបភាព៥.៦៨៖ ស្ថានភាពផ្ទះ ចំការ និងដីរបស់ឈ្មោះ សាន សូរិយា

Draft

| ទីតាំងទី ១១ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងជើង ឆៀងខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442929 ,Y: 1486990 |
| ១ | **ឈ្មោះម្ចាស់ដី:** ឈ្មោះ **ស៊ុំ ធួន** និង **ស៊ុំ រួន** |
| ២ | **ទំហំដី:** ១ ហិកតា |
| ៣ | **ស្ថានភាពដី:** ដីព្រៃ ទើបរានថ្មី មិនមានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ស្ថានភាពផ្ទះ៖** ផ្ទះឈើកំពុងសាងសង់ចំនួន ៣ ខ្នង |
| ៦ | **ប្រវត្តិនៃការកាន់កាប់ដី៖** ដីនេះមានទំហំប្រហែល ១ ហិកតា។ នៅក្នុងឆ្នាំ ២០១១ ឈ្មោះ ស៊ុំ ធួន បានទ្រួសត្រាយព្រៃដើម្បីយកដីមកប្រើប្រាស់តាមតំរូវការ។ បច្ចុប្បន្ននេះ ឈ្មោះស៊ុំ ធួន និងប្អូន ឈ្មោះ ស៊ុំ រួនបានមកសង់ផ្ទះថ្មី និងប្រកបមុខលក់ដូរបន្តិចបន្តួច។ |



រូបភាព៥.៦៥៖ ស្ថានភាពផ្ទះ កំពុងសាងសង់របស់ឈ្មោះ ស៊ុំ ធូន និង ស៊ុំ វួន

Draft

| ទីតាំងទី ១២ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងជើង ឆៀងខាងកើត នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442855 ,Y: 1487247 |
| ១ | **ឈ្មោះម្ចាស់ដី:** ប្ដីឈ្មោះ **សុង សាក**, ប្រពន្ធឈ្មោះ **វ៉ាន់ ថាន** |
| ២ | **ទំហំដី:** ៦ ហិកតា |
| ៣ | **ស្ថានភាពដី:** ដីស្រែ |
| ៤ | **ស្ថានភាពដំណាំ:** មានដំណាំ |
| ៥ | **ស្ថានភាពផ្ទះ៖** គ្មានផ្ទះ |
| ៦ | **ប្រវត្តិនៃការកាន់កាប់ដី៖** ដីនេះមានទំហំប្រហែល ៦ ហិកតា។ នៅក្នុងឆ្នាំ ២០១១ ម្ដាយឈ្មោះ ប្រមលី និងឪពុក ឈ្មោះ នួន វ៉ាន់ បានញែកដីអោយកូន ឈ្មោះ វ៉ាន់ ថាន និងកូនប្រសារឈ្មោះ សុង សាក ដើម្បីធ្វើស្រែ។ |



រូបភាព៥.៦៦៖ ស្ថានភាពដីស្រែរបស់ឈ្មោះ **សុង សាក** និង ប្រពន្ធឈ្មោះ **វ៉ាន់ ថាន**

Draft

| **ទីតាំងទី ១៣** | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងកើត ឆៀងខាងជើងនៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442868,Y: 1487407 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ (នៅទីរួមខេត្ត សៀមរាប) |
| ២ | **ទំហំដី:** ៣០ ហិតា |
| ៣ | **ស្ថានភាពដី:** ជាដីចាស់ គ្មានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** ម្ចាស់ដីនៅរស់នៅទីរួមខេត្ត សៀមរាប តាមការសាកសួរពត៌មានពីអ្នកចាំដី បានឲ្យដឹងថា ម្ចាស់ដីនេះកាន់កាប់ដីបាន១១ ឆ្នាំ ហើយ គឺនៅក្នុងឆ្នាំ ២០០៥ ។ ប៉ុន្តែបច្ចុប្បន្ននេះ គាត់បានឈូសឆាយដើម្បី ដាំស្មៅសម្រាប់ចិញ្ចឹមគោចំនួន ៣២ ក្បាល។ |



រូបភាព៥.៦៧៖ សកម្មភាពចុះទៅពិនិត្យស្ថានភាពដី ផ្ទះ និងសម្ភាសន៍ជាមួយអ្នកចាំដី

Draft

| ទីតាំងទី ១៤ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងកើត ឆៀងខាងជើងនៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 442809 ,Y: 1487462 |
| ១ | **ឈ្មោះម្ចាស់ដី:** ឈ្មោះ ប្តី **នួន វ៉ាន់** និង ឈ្មោះ ប្រពន្ធ **ប្រម លី** |
| ២ | **ទំហំដី:** ១០ ហិតា |
| ៣ | **ស្ថានភាពដី:** ជាដីផ្ទះ និងចម្ការដំឡូងមី។ |
| ៤ | **ស្ថានភាពដំណាំ:** ដំណាំដំឡូងមីទើបតែដាំថ្មី។ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** កាន់កាប់នៅឆ្នាំ ២០០៥ ប៉ុន្តែពួកគាត់ទើបតែមករស់នៅចុងឆ្នាំ ២០១២។ ដីនេះក៏ធ្លាប់ បានទទួលការវាស់វែងពីក្រុមយុវជនស្មគ្រ័ចិត្ត និងប័ណ្ណកម្មសិទ្ធិបណ្តោះអាសន្នផងដែរ។ |







រូបភាព៥.៦៨៖ ស្ថានភាពផ្ទះ និងដីរបស់ឈ្មោះ ប្ដី នួន វ៉ាន់ និង ឈ្មោះ ប្រពន្ធ ប្រមលី

Draft

| **ទីតាំងទី ១៥** | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X:439528 , Y: 1484856 |
| ១ | **ឈ្មោះម្ចាស់ដី:** ប្រហែល **៣០ គ្រួសារ** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ៣០០ហិកតា |
| ៣ | **ស្ថានភាពដី:** ដីស្រែចាស់ មានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីស្រែ ប្រហែល ៣០០ ហិកតា នៅក្នុងផ្ទៃដីស្រាវជ្រាវ របស់គម្រោងអាជីវកម្មរ៉ែទង់ដែង។បើតាម ការសាកសួរពត៌មានពីលោកមេឃុំ ចុង ស្ថាន លោក មុត ឆៃ បានឲ្យដឹងថាដីស្រែទាំងនេះ មាន ម្ចាស់ប្រហែល ៣០ គ្រួសារ ដែលកាន់កាប់យូរឆ្នាំណាស់មកហើយ។ |



រូបភាព៥.៦៩៖ ស្ថានភាពដីប៉ះពាល់ នៅខាងត្បូង ឈៀងខាងលិចតំបន់គម្រោង

| ទីតាំងទី ១៦ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X:439528 , Y: 1484856 |
| ១ | **ឈ្មោះម្ចាស់ដី:** ប្រហែល **២០ គ្រួសារ** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ៣០០ហិកតា |
| ៣ | **ស្ថានភាពដី:** ដីស្រែចាស់ មានដំណាំ |
| ៤ | **ស្ថានភាពដំណាំ:** មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីស្រែប្រហែល **៣០០ ហិកតា** នៅក្នុងផ្ទៃដីស្រាវជ្រាវ របស់គម្រោងអាជីវកម្មរ៉ែទង់ដែង។ បើតាមការសាកសួរពត៌មានពីលោកមេឃុំ ចុង ស្ពាន **លោក មុត នៃ** បានឲ្យដឹងថាដីស្រែទាំងនេះមាន ម្ចាស់ប្រហែល **២០ គ្រួសារ** ដែលកាន់កាប់យូរឆ្នាំណាស់មកហើយ។ |



រូបភាព៥.៧០ៈ ស្ថានភាពដីនៅខាងត្បូង ឆៀងខាងលិចទីតាំងគម្រោង

| ទីតាំងទី ១៧ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង នៃតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 441517 ,Y: 1482996 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ១៥ ហិកតា |
| ៣ | **ស្ថានភាពដី:** កំពុងឈូសឆាយ |
| ៤ | **ស្ថានភាពដំណាំ:** គ្មាន |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដែលកាប់ទន្រ្ទានរួចប្រហែល ១៥ ហិកតា គ្មានផ្ទះ ។ តាមការសាកសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ។ |



រូបភាព៥.៧១៖ ស្ថានភាពដីនៅចំណុចនិយាមការ (X: 441517 ,Y: 1482996)

| ទីតាំងទី ១៨ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ក្រៅតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង។ |
| B | **ចំណុចនិយាម:** X: 441403 ,Y: 1483003 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ១០ ហិកតា |
| ៣ | **ស្ថានភាពដី:** ទើបឈូសឆាយរួច |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដីដែលកាប់ទន្ទ្រាន និងទើបឈូសឆាយរួចប្រហែល ១០ ហិកតា គ្មានផ្ទះ និងដំណាំ ។ តាមការសាកសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្ទ្រាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្ទ្រានថ្មីៗ។ |

Draft



រូបភាព៥.៧២៖ ស្ថានភាពដីនៅចំណុចនិយាមការ (X: 441403 ,Y: 1483003)

| **ទីតាំងទី ១៩** | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ក្រៅតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ខាងជើងផ្លូវ។ |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ១០ ហិកតា |
| ៣ | **ស្ថានភាពដី:** កំពុងឈូសឆាយ |
| ៤ | **ស្ថានភាពដំណាំ:** គ្មាន |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ផ្ទៃដែលកាប់ទន្រ្ទានរួច ដែលកំពុងតែឈូសឆាយដើម្បីយកដីធ្វើចម្ការប្រហែល ១០ ហិកតា។ តាមការសាកសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ។ |



រូបភាព៥.៧៣៖ ស្ថានភាពដីនៅចំណុចខាងត្បូង ក្រៅតំបន់គម្រោង

| ទីតាំងទី ២០ | |
|---|---|
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ក្រៅតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ខាងជើងផ្លូវ។ |
| B | **ចំណុចនិយាម:** X: 440102 ,Y: 1482997 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ៨ ហិកតា |
| ៣ | **ស្ថានភាពដី:** ដីចម្ការដែលឈូសឆាយរួច |
| ៤ | **ស្ថានភាពដំណាំ:** ដំឡូងមី |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ដីចម្ការដែលបានឈូសឆាយរួចមួយកន្លែងមានទំហំប្រហែល ៨ ហិកតា។ តាមការសាងសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ។ |



រូបភាព៥.៧៤៖ ស្ថានភាពដីកំពុងឈូសឆាយនៅខាងត្បូងទីតាំងគម្រោង( X: 440102 ,Y:

| | |
|---|---|
| | **ទីតាំងទី ២១** |
| A | **ទីតាំងដី:** ស្ថិតនៅប៉ែកខាងត្បូង ក្រៅតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ខាងជើងផ្លូវ។ |
| B | **ចំណុចនិយាម:** X: 441485 ,Y: 1483497 |
| ១ | **ឈ្មោះម្ចាស់ដី:** មិនស្គាល់ឈ្មោះ |
| ២ | **ទំហំដី:** ប្រហែល ៣០ ហិកតា |
| ៣ | **ស្ថានភាពដី:** ដីចម្ការដែលឈូសឆាយរួច |
| ៤ | **ស្ថានភាពដំណាំ:** គ្មានដំណាំ |
| ៥ | **ប្រវត្តិនៃការកាន់កាប់ដី៖** នៅពេលចុះសិក្សាស្រាវជ្រាវក្រុមការងារបានប្រទះឃើញ ដីចម្ការដែលបានឈូសឆាយរួចមួយកន្លែងមានទំហំប្រហែល ៣០ ហិកតា។ តាមការសាកសួរពត៌មានពីអ្នកដែលនៅជិតខាង ក៏មិនទទួលបានអត្តសញ្ញាណ ឈ្មោះម្ចាស់ដី និងឆ្នាំកាប់ទន្រ្ទាននោះដែរ។ តែតាមការពិនិត្យជាក់ស្តែងអាចវាយតំលៃបានថា ដីនេះប្រហែលទើបតែកាប់ទន្រ្ទានថ្មីៗ។ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៥.៧៥៖ ស្ថានភាពដីកំពុងឈូសឆាយនៅខាងត្បូងទីតាំងគម្រោង

ដូចនេះ សន្និដ្ឋានថា គ្រួសារដែលប៉ះពាល់សរុបមាន **៨០គ្រួសារ** ក្នុងនោះ មានដីចម្ការស្រែ និងផ្ទះ **៦២គ្រួសារ** និងផ្ទះនៅក្នុងការដ្ឋានជីកថ្មបាយក្រៀម ចំនួន **១៨គ្រួសារ**។ ដីស្រែសរុបមានជាង **៦០៦ហិកតា** ស្មើរនឹង **៥១គ្រួសារ**។ ដីចម្ការសរុបមានចំនួន **៦១,១២ហិកតា** ស្មើរនឹង**១១គ្រួសារ**។ ហើយចំពោះគ្រួសារដែលមានផ្ទះ ហើយគ្មានដីចម្ការមាន **១៩គ្រួសារ**។

A3

Draft

#322P, St 271Z, Sk Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៦៖

# ការចូលរួមជាសាធារណៈ

Draft

# ជំពូកទី៦៖ ការចូលរួមជាសាធារណៈ

## ៦.១ សេចក្ដីផ្ដើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គមពេញលេញ តំរូវឱ្យមានការចូលរួមជាសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ដើម្បីឱ្យមានភាពត្រឹមត្រូវ និងអាចទទួលយកបាន។ ការសិក្សានេះ **ក្រុមហ៊ុន គ្រីអេធីវ គ្រីនឌីហ្សាញ** (Creative Green Design Co., Ltd) បានចុះធ្វើការសម្ភាសជាមួយក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ម្ចាស់គម្រោង និងប្រជាជនជុំវិញតំបន់គម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង ដែលមានទីតាំងស្ថិតនៅក្នុងឃុំខ្នាវ ស្រុកជីក្រែង ខេត្តសៀមរាប។ ការសម្ភាស និងពិគ្រោះយោបល់នេះ ដើម្បីទទួលបានសំណួរ សំណូមពរ និងអនុសាសន៍ផ្សេងៗ ក្នុងការជួយកែលំអរ បញ្ចៀស និងកាត់បន្ថយផលប៉ះពាល់ពីគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ ឱ្យនូវកំរិតអប្បបរមា និងអាចទទួលយកបាន។

ការចូលរួមជាសាធារណៈត្រូវបានធ្វើឡើង ដើម្បីឱ្យសាធារណៈជនពាក់ព័ន្ធបានដឹងឮថា មានក្រុមហ៊ុន MENG XIN HONG FA (CAMBODIA) RESOURCES INVESTMENT CO., LTD បានមកវិនិយោគធ្វើអាជីវកម្មរ៉ែទង់ដែងនៅក្នុងតំបន់របស់ពួកគាត់។ ម៉្យាងវិញទៀត ការចូលរួមជាសាធារណៈនេះ តម្រូវឲ្យជនពាក់ព័ន្ធទាំងឡាយធ្វើការផ្ដល់មតិយោបល់សម្រាប់កែលំអ ផ្ដល់សំណូមពរ និងស្ថាបនាក្នុងការជួយសម្រួលដល់ការអនុវត្តគម្រោងឲ្យបានល្អប្រសើរ មានភាពរលូន និងមានប្រសិទ្ធិភាពឲ្យស្របទៅតាមបរិបទអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។

ការចូលរួមជាសាធារណៈ ត្រូវការជាចាំបាច់សម្រាប់ធ្វើការវាយតំលៃលើហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលមានឥទ្ធិពលលើកត្តាសេដ្ឋកិច្ចសង្គម បរិស្ថានធម្មជាតិ សហគមន៍ទាំងមូលដ្ឋាន តាមរយៈគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។ ដូច្នេះទាមទារឲ្យមានការចូលរួមជាសាធារណៈ ដែលផ្ដោតសំខាន់លើការចុះផ្សាយ ស្ទាបស្ទង់មតិ ការជួបពិភាក្សាជាមួយ មន្ទីរ/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីទទួលបាននូវគំនិតរិះគន់ យោបល់គាំទ្រ ព័ត៌មានលំអិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ និងអនុសាសន៍នានា ដែលអាចជាប្រភពទិន្នន័យមួយដ៏សំខាន់ក្នុងការសម្រេចចិត្ត។

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ ក្រុមហ៊ុនទីប្រឹក្សាបានធ្វើការពិគ្រោះយោបល់ចំនួន២លើគឺ លើកទី១ បានធ្វើឡើងនពេលចុះសិក្សាវាយតំលៃ និងលើកទី២បានធ្វើឡើងនៅពេលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានបញ្ចប់។

## ៦.២ គោលបំណងនៃការពិគ្រោះយោបល់

គោលបំណងនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជនជាមួយក្រសួង មន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋមានដូចតទៅៈ

- ផ្សព្វផ្សាយដល់សាធារណៈជន និងអ្នកដែលពាក់ព័ន្ធនឹងគម្រោងទាំងអស់ឱ្យបានដឹងឮពីគោលបំណងរបស់គម្រោងអាជីវកម្ម និងបានដឹងឮថាមានគម្រោងអាជីវកម្មរ៉ែទង់ដែងមួយក្នុងតំបន់របស់គាត់។
- ដកស្រង់មតិយោបល់ចូលរួមសហការណ៍ និងការគាំទ្រពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋានលើគម្រោងអាជីវកម្មរ៉ែនេះ ដើម្បីឲ្យការអភិវឌ្ឍនេះដំណើរការទៅបានរលូន។
- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ ការងឿងឆ្ងល់របស់មន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ និងប្រជាពលរដ្ឋ ចំពោះគម្រោងធ្វើអាជីវកម្មរ៉ែនេះ និងការបកស្រាយរបស់ក្រុមហ៊ុន ពោលគឺរកវិធីសាស្រ្តសម្របសម្រួល និងកែលំអរ ដែលអាចទទួលយកបានទាំងសងខាង។

## ៦.៣ វិធីសាស្រ្តនៃការប្រឹក្សាយោបល់

ការប្រឹក្សាពិគ្រោះយោបល់ជាសាធារណៈបានធ្វើឡើងចំនួន២លើកគឺ លើកទី១ បានធ្វើឡើងនៅពេលរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះបរិស្ថាននិងសង្គម ចំណែកលើកទី២បានធ្វើឡើងនៅពេលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានបញ្ចប់។ ការប្រជុំពិភាក្សា ពិគ្រោះយោបល់ពីមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធលើកទី១ បានធ្វើឡើងនៅថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១៤ដោយប្រើប្រាស់កម្រងសំនួរសម្រាប់សម្ភាសន៍ផ្ទាល់ជាមួយប្រធានមន្ទីរ និងមន្រ្តីជំនាញពាក់ព័ន្ធមួយចំនួន។ រីឯការប្រជុំប្រឹក្សាពិគ្រោះយោបល់លើកទី២បានធ្វើឡើងនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ដោយប្រើប្រាស់វិធីសាស្រ្តធ្វើបទបង្ហាញពីលទ្ធផលនៃរបាយការណ៍វាយតំលៃដែលបានសិក្សារួច នៅសាលាខេត្តសៀមរាប។

ចំណែកអាជ្ញាធរមូលដ្ឋាន ប្រើប្រាស់វិធីសាស្រ្តប្រជុំពិភាក្សា និងពិគ្រោះយល់បល់ ដែលមានការចូលរួមសំណាក់ប្រធានឃុំខ្វាវ និងមេភូមិទាំង៣ ដែលពាក់ព័ន្ធនឹងតំបន់គម្រោង។

រីឯប្រជាពលរដ្ឋត្រូវបានប្រើប្រាស់វិធីសាស្រ្តសម្ភាសន៍តាមគេហដ្ឋាន ដោយជ្រើសរើសប្រជាជនតំណាងទាំង ៣ភូមិ ចេញពីភូមិខ្វាវ ចុងស្ពាន និងភូមិរៀង។ ការពិគ្រោះយោបល់ជាមួយប្រជាជន បានប្រើប្រាស់កម្រងសំនួរដើម្បីសាកសួរ ប្រជាជន ដោយកំណត់យកប្រជាជនតំណាងចេញពីភូមិទាំង៣ ចំនួន៩២គ្រួសារ។

មន្ទីរ-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងចំនួនប្រជាជនដែលចូលរួមមានដូចខាងក្រោម៖

តារាង ៦.១៖ វិធីសាស្ត្រក្នុងការពិគ្រោះយោបល់ជាសាធារណៈលើកទី១

| ការប្រឹក្សាពិគ្រោះយោបល់លើកទី១ | | | |
|---|---|---|---|
| **វិធីសាស្ត្រ** | **អ្នកដែលត្រូវសម្ភាសន៍** | **ពេលវេលា** | **អ្នកចូលរួម** |
| ស្នើរសុំពិគ្រោះយោបល់និងសម្ភាសន៍ផ្ទាល់នៅសាលាខេត្ត | - សាលាខេត្តសៀមរាប<br>- មន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប<br>- មន្ទីរបរិស្ថានខេត្តសៀមរាប<br>- អភិបាលស្រុកជីក្រែង | ១៥ ធ្នូ ២០១៤<br>ម៉ោង ២:៣០-៣:៣០ ល្ងាច | - អភិបាលរងខេត្ត<br>- ប្រធានមន្ទីររ៉ែ និងថាមពល<br>- ប្រធានមន្ទីរបរិស្ថាន<br>- អភិបាលស្រុកជីក្រែង<br>- ក្រុមហ៊ុនទីប្រឹក្សា ៤នាក់ |
| ស្នើរសុំពិគ្រោះយោបល់ និងប្រជុំតាមមន្ទីរដែលពាក់ព័ន្ធ | មន្ទីរធនធានទឹក និងឧតុនិយម ខេត្តសៀមរាប | ១៥ ធ្នូ ២០១៤<br>ម៉ោង ៣:២០-៤:២០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- ប្រធានមន្ទីរ |
| | រដ្ឋបាលព្រៃឈើ ខេត្តសៀមរាប | ១៦ ធ្នូ ២០១៤<br>ម៉ោង ៤:០០-៥:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- នាយខ័ណ្ឌរដ្ឋបាល |
| | មន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ខេត្តសៀមរាប | ១៦ ធ្នូ ២០១៤<br>ម៉ោង ១០:០០-១១:០០ ព្រឹក | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- អនុប្រធានមន្ទីរ |
| | មន្ទីរទេសចរណ៍ ខេត្តសៀមរាប | ១៦ ធ្នូ ២០១៤<br>ម៉ោង ២:០០-៣:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- ប្រធានមន្ទីរ |
| | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប | ១៦ ធ្នូ ២០១៤<br>ម៉ោង ៣:០០-៤:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- អនុប្រធានមន្ទីរ |
| | នាយកដ្ឋានភូគព្ភសាស្ត្រ | ២២ ធ្នូ ២០១៤<br>ម៉ោង ៤:០០-៥:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ២នាក់<br>- ប្រធានមន្ទីរ<br>- ជំនួយការ |

Draft

| | | | |
|---|---|---|---|
| | មន្ត្រីជំនាញរបស់ក្រុមហ៊ុន ម៉េង ស៊ីន ហុងហ្វា | ១១ តុលា ២០១៤<br>ម៉ោង ៣:០០-៤:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៥នាក់<br>- មន្ត្រីជំនាញ ២នាក់ |
| ស្នើរសុំពិគ្រោះយោបល់ និងប្រជុំនៅសាលាឃុំខ្វាវ | ប្រធានឃុំខ្វាវ<br>មេភូមិខ្វាវ<br>មេភូមិចុងស្ពាន<br>មេភូមិរវៀង | ៩ វិច្ឆិកា ២០១៤<br>ម៉ោង ៧:០០-១១:០០ ព្រឹក | - ក្រុមហ៊ុនទីប្រឹក្សា ៤នាក់<br>- មេឃុំខ្វាវ ១នាក់<br>- មេភូមិខ្វាវ ១នាក់<br>- មេភូមិចុងស្ពាន ១នាក់<br>- មេភូមិរវៀង ១នាក់ |
| ស្នើរសុំសម្ភាសន៍តាមផ្ទះប្រជាជន | ជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិដែលនៅជុំវិញតំបន់គម្រោង | ៩-១០ វិច្ឆិកា ២០១៤<br>ម៉ោង ១០:០០-៥:០០ ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា ៦នាក់<br>- តំណាងប្រជាជន ទាំង៣ភូមិ ៩២នាក់ |

តារាង ៦.២៖ វិធីសាស្ត្រក្នុងការពិគ្រោះយោបល់ជាសាធារណៈលើកទី២

| ការប្រឹក្សាពិគ្រោះយោបល់លើកទី២ | | | |
|---|---|---|---|
| **វិធីសាស្ត្រ** | **ពេលវេលា** | **ឈ្មោះអ្នកចូលរួម** | **តួនាទី** |
| ស្នើរសុំពិគ្រោះយោបល់នៅសាលាខេត្តសៀមរាប | ០៣ មីនា ២០១៥<br>ម៉ោង<br>៨:០០-១១:០០ព្រឹក | ឯកឧត្តម ស៊ិន រុន | អភិបាលរងខេត្តសៀមរាប |
| | | លោក ភួង លីណា | ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប |
| | | លោក មាស ផូរ៉ានី | ប្រធានមន្ទីររ៉ែនិងថាមពលខេត្តសៀមរាប |
| | | លោក រី អញ្ចលី | អនុប្រធានមន្ទីរវប្បធម៌ ខេត្តសៀមរាប |
| | | លោក ពៅ ប៊ុនធឿន | អភិបាលស្រុកជីក្រែង |
| | | លោក ប៊ូ ជុំសម្បត្តិ | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប |
| | | អ្នកនាង សួន បញ្ញាស័ក្ក | មន្ត្រីក្រសួងបរិស្ថាន |
| | | លោក ឈឹម វឌ្ឍនៈ | អនុប្រធានការិយាល័យមន្ទីររ៉ែនិងថាមពល |
| | | លោក ឃួន សុខាន់ឌី | មន្ត្រីក្រសួងបរិស្ថាន |
| | | លោក ចេវ ផល | ប្រធានការិយាល័យអប្សរា |
| | | លោក ហុក ហុងសា | អនុប្រធានមន្ទីរសាធារណៈការ |
| | | លោក ផន គីរីគឹង | ការិយាល័យបច្ចេកទេសរ៉ែ និងថាមពល |

Draft

| | | | |
|---|---|---|---|
| | | លោក ទូស សាភឿន | ប្រធានក្រុមហ៊ុន Creative Green Design |
| | | អ្នកនាង ភី ណៃគីម | បុគ្គលិកក្រុមហ៊ុន Creative Green Design |
| ស្នើរសុំពិគ្រោះយោបល់ នៅសាលាខេត្តសៀមរាប | ០៣ មីនា ២០១៥ ម៉ោង ៨:០០-១១:០០ព្រឹក | លោក សុខ ថុល | នាយករដ្ឋបាលស្ដីទីសាលាខេត្តសៀមរាប |
| | | លោក សោ ពិសិទ្ធ | អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប |
| | | លោក Yan Peng Cheng | ប្រធានគ្រប់គ្រងក្រុមហ៊ុន Meng Xing Hong Fa |
| | | លោក Cao Yi | អនុប្រធានក្រុមហ៊ុន Meng Xing Hong Fa |
| | | លោក Che Yi Lin | វិស្វករ ក្រុមហ៊ុន Meng Xing Hong Fa |
| | | លោក កែវ សាន់ឌី | អ្នកបកប្រែក្រុមហ៊ុន Meng Xing Hong Fa |
| | | លោក សូ ផល្លា | នាយកផ្នែកខណ្ឌរដ្ឋបាលព្រៃឈើ |
| | | លោក យូ ចំរើន | ប្រធានការិយាល័យធនធានទឹក |
| | | លោក ងន ស៊ុនធី | អនុប្រធានការិយាល័យសេដ្ឋកិច្ច |
| | | លោក ទូច បូរាណ | បុគ្គលិកក្រុមហ៊ុន Creative Green Design |
| | | លោក សំ មិថុនា | បុគ្គលិកក្រុមហ៊ុន Creative Green Design |
| | | ហាង្ស វិចិត្រ | បុគ្គលិកក្រុមហ៊ុន Creative Green Design |

Draft

## ៦.៤ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយសាលាខេត្តសៀមរាប និងមន្ទីរដែលពាក់ព័ន្ធលើកទី១

### ៦.៤.១ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយអភិបាលខេត្តសៀមរាប

**ឯកឧត្តម គីម នៃហៀង** អភិបាលរងខេត្តសៀមរាប បានផ្ដល់ឱកាសឱ្យក្រុមការងារ **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** (CGD) ជួបសម្ភាសន៍ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង២:៣០ ដល់៣:៣០ល្ងាច។ ការជួបសម្ភាសន៍នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងដូចខាងក្រោម៖

**<u>សំណួរទី១៖</u>** តើឯកឧត្តមធ្លាប់បានជ្រាបពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងដែរឬទេ?

**<u>ចម្លើយទី១៖</u>** បាទ, ខ្ញុំធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង។

**សំណួរទី២៖** ក្រុមហ៊ុនបានផ្តល់ជូននូវព័ត៌មានដល់សាលាខេត្តសៀមរាបអំពីការវិនិយោគ និងការធ្វើអាជីវកម្មរ៉ែទង់ដែងដែរឬទេ?

**ចម្លើយទី២៖** បាទ,ជាការពិតណាស់ ក្រុមហ៊ុនអភិវឌ្ឍន៍លើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែនេះក៏បានផ្តល់ដំណឹងជូនដល់សាលាខេត្តឲ្យបានជ្រាបផងដែរ។

**សំណួរទី៣៖** តើឯកឧត្តមដឹងពីស្ថានភាពភូមិសាស្ត្រនិងគម្របព្រៃឈើនៅស្រុកជីក្រែងដែរឬទេ?

**ចម្លើយទី៣៖** ខ្ញុំក៏បានដឹងពីស្ថានភាពភូមិសាស្ត្រ និងគម្របព្រៃឈើនៅស្រុកជីក្រែងខ្លះដែរ។ នៅក្នុងតំបន់នេះគឺសម្បូរទៅដោយព្រៃស្រោង និងព្រៃគម្រប

**សំណួរទី៤៖** តើឯកឧត្តមធ្លាប់បានចុះត្រួតពិនិត្យនៅក្នុងការដ្ឋាន និងតំបន់គម្រោងអាជីវកម្មរ៉ែនេះដោយផ្ទាល់ដែរឬទេ?

**ចម្លើយទី៤៖** ចំពោះខ្ញុំ មិនធ្លាប់បានចុះទៅទីតាំងគម្រោងនោះដោយផ្ទាល់ទេ ។

**សំណួរទី៥៖** តើក្បែរតំបន់គម្រោងធ្វើអាជីវកម្មរ៉ែនេះមានប្រាសាទ ឬតំបន់ប្រវត្តិសាស្ត្រដែរឬទេ? បើមាន តើមានអ្វីខ្លះ?

**ចម្លើយទី៥៖** នៅក្បែរតំបន់គម្រោងធ្វើអាជីវកម្មនេះក៏មានប្រាសាទ និងតំបន់ប្រវត្តិសាស្ត្រមួយចំនួនផងដែរ ដែលមានដូចជាបឹងឈ្នួន ស្ពានកំបោរអរ ស្ពានតាជៀវ ប្រាសាទល្បើក និងប្រាសាទភ្នំដុកជាដើម។

**សំណួរទី៦៖** តើការធ្វើអាជីវកម្មនេះមានផលប៉ះពាល់ប្រាសាទបុរាណ ឬតំបន់ប្រវត្តិសាស្ត្រទាំងអស់នេះដែរឬទេ? បើមាន, តើមានអ្វីខ្លះ ចូររៀបរាប់?

**ចម្លើយទី៦៖** ជាធម្មតាការអភិវឌ្ឍប្រាកដជាមាននូវហេតុប៉ះពាល់តិច ឬច្រើនទៅតាមទំហំនៃការវិនិយោគ ប៉ុន្តែបើសិនជាក្រុមហ៊ុនវិនិយោគគោរពតាមគោលនយោបាយដែលរដ្ឋាភិបាលបានកំណត់ និងការណែនាំពីក្រុមហ៊ុនកុងស៊ុលតង់នោះផលប៉ះពាល់ប្រាកដជាមានតិច។

**សំណួរទី៧៖** តើតំបន់គម្រោងប៉ះពាល់វប្បធម៌ ឬទំនៀមទំលាប់ប្រជាជនក្នុងតំបន់ ឬជនជាតិភាគតិចឬទេ?

**ចម្លើយទី៧៖** តំបន់អនុវត្តន៍គម្រោងនេះមិនបានធ្វើឲ្យមានផលប៉ះពាល់ដល់វប្បធម៌ ឬទំនៀមទំលាប់ប្រជាជនក្នុងតំបន់ ឬជនជាតិភាគតិចអ្វីទេ ពីព្រោះទីតាំងគម្រោងស្ថិតនៅឆ្ងាយពីទីតាំងដែលមានប្រជាជនរស់នៅ។

**សំណួរទី៨៖** តើឯកឧត្តមដឹងថាការធ្វើអាជីវកម្មមានផលប៉ះពាល់ដល់បរិស្ថាន សង្គម និង សេដ្ឋកិច្ចអ្វីខ្លះ?

<u>ចម្លើយទី៨៖</u> ជាធម្មតា ការអភិវឌ្ឍតែងតែផ្ដល់នូវការប៉ះពាល់មិនថាតិចឬច្រើនទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយប្រសិនបើក្រុមហ៊ុន បានអនុវត្តន៍ទៅតាមច្បាប់ដែលរដ្ឋាភិបាលបានចែងនោះវានឹងមិនបណ្ដាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ។

<u>សំណួរទី៩៖</u> តើវិធានការអ្វីខ្លះដែលក្រុមហ៊ុនត្រូវអនុវត្តន៍ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន?
<u>ចម្លើយទី៩៖</u> សម្រាប់វិធានការកាត់បន្ថយដែលក្រុមហ៊ុនគួរតែអនុវត្តន៍ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានដូចជា៖

- សូមឱ្យក្រុមហ៊ុនចិន (MENG XIN HONG FA) បង្ហាញចំណុចនិយាមការដើម្បីឱ្យខាងសាលាខេត្តរៀបចំគណៈកម្មការចុះពិនិត្យដោយផ្ទាល់ ជាពិសេសផ្នែកសុរិយោដីដើម្បីសិក្សាវាយតម្លៃថាតើមានការប៉ះពាល់អ្វីខ្លះ? តើគម្រោងនេះមានប៉ះពាល់ទៅដល់ដីស្រែដីចំការប្រជាជន ដីព្រៃឈើ និងសត្វព្រៃក្នុងទំហំប៉ុណ្ណា។
- រដ្ឋាភិបាលចង់ឱ្យមានការអភិវឌ្ឍដែលមានផលប៉ះពាល់តិចតួចបំផុតដល់ប្រជាជនជាពិសេសត្រូវដោះស្រាយជម្លោះផ្សេងៗដែលអាចកើតមាន

<u>សំណួរទី៩៖</u> តើឯកឧត្តមមានអនុសាសន៍ និងសំណូមពរអ្វីខ្លះទៅលើគម្រោងអាជីវកម្មនេះ?
<u>ចម្លើយទី៩៖</u> ខ្ញុំមានអនុសាសន៍ និងសំណូមពរមួយចំនួនដូចជា៖

- សូមក្រុមហ៊ុនធ្វើរបាយការណ៍រៀងរាល់ត្រីមាស ឬឆមាស និងរបាយការវិសមញ្ញ
- សូមឱ្យក្រុមហ៊ុនយកចិត្តទុកដាក់ពីបញ្ហាសង្គម កុំឱ្យប៉ះពាល់ប្រជាជន
- សូមឱ្យក្រុមហ៊ុនយកចិត្តទុកដាក់ពីបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ការពារការហុយដី ជាពិសេស បញ្ហាបរិស្ថានដោយបញ្ចៀសឱ្យបាននូវផលប៉ះពាល់អតិប្បរមា
- សូមក្រុមហ៊ុន មេត្តាកុំគេងប្រវញ្ចទៅលើកម្លាំងពលកម្មរបស់កម្មករ
- សូមឱ្យក្រុមហ៊ុនគោរព ច្បាប់ការងារ ស្តង់ដារតាមបច្ចេកទេស និងសៀវភៅបន្ទុកដែលជាកិច្ចសន្យារវាង ក្រុមហ៊ុនកុងស៊ុលតង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រោយបញ្ចប់គម្រោង ក្រុមហ៊ុនត្រូវលប់ដី និងដាំដើមឈើឡើងវិញ
- ខ្ញុំគាំទ្រពេញទំហឹងចំពោះការអភិវឌ្ឍដែលស្របច្បាប់ និងលើកទឹកចិត្តចំពោះការអភិវឌ្ឍដែលមានលក្ខណៈបែបនេះ។

### ៦.៨.២ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរ បរិស្ថានខេត្តសៀមរាប

**លោក តួច លីណា** ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប បានផ្ដល់ឱកាសឱ្យក្រុមការងារគ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ នៅវេលាម៉ោង៣:៣០ ដល់៤:៣០ល្ងាច ដើម្បីជួបសម្ភាសន៍ និងពិភាក្សាមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែង។ ក្រុមការងារក៏មាននូវកម្រងសំណួរមួយចំនួនដូចខាងក្រោម៖

**សំណួរទី១៖** តើលោកបានដឹងពីគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែង នៅក្នុងស្រុកជីក្រែងខេត្តសៀមរាបដែររឺទេ?

**ចម្លើយទី១៖** បាទខ្ញុំបានដឹងពីគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនៅក្នុងស្រុកជីក្រែងនេះ ប៉ុន្តែមន្ទីរបរិស្ថានខេត្តសៀមរាបមិនបានចុះពិនិត្យការដ្ឋានដោយផ្ទាល់ទេ ហើយក៏គ្មានទំនាក់ទំនងនឹងក្រុមហ៊ុនដែរ។

**សំណួរទី២៖** តើមានតំបន់ការពារធម្មជាតិ ឬទេសភាពនៅក្បែរតំបន់គម្រោងដែរឬទេ? បើមានតើមានអ្វីខ្លះ? ស្ថិតនៅចម្ងាយប៉ុន្មានពីទីតាំងគម្រោង?

**ចម្លើយទី២៖** តំបន់គម្រោងអាជីវកម្មរ៉ែនេះពុំស្ថិតនៅក្នុងតំបន់ការពារធម្មជាតិទេ ប៉ុន្តែតំបន់នោះជាតំបន់គ្របដណ្តប់ដោយប្រាសាទបុរាណ ភ្នំ បឹងបុរាណជា និងក្បែរផ្លូវទឹកបុរាណ។

**សំណួរទី៣៖** តើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះ មានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់ធនធានទឹក?

**ចម្លើយទី៣៖** ខ្ញុំមិនអាចឆ្លើយពីតបបានពីទំហំនៃផលប៉ះពាល់ជាក់លាក់បាននៅឡើយទេ ប៉ុន្តែគម្រោងអាជីវកម្មនេះអាចប៉ះពាល់ដល់ការហូរនៃសារធាតុរ៉ែទៅលើផ្លូវទឹក និងអាចធ្វើឲ្យមានការបាត់បង់ដល់គម្របព្រៃឈើ

**សំណួរទី៤៖** តើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់ធនធានដី?

**ចម្លើយទី៤៖** ក្រុមហ៊ុនអាជីវកម្មអាចប្រើប្រាស់សារធាតុគីមីមួយចំនួនដែលបានប្រើប្រាស់ដើម្បីទាញយកសារធាតុរ៉ែ ដូច្នេះវាអាចធ្វើឲ្យមានផលប៉ះពាល់ដល់ដីធ្ងន់ធ្ងរ។ ចំពោះដំណាក់កាលពាក់កណ្តាលសម្រេច ផលប៉ះពាល់អាចមានដូចជា ការបំពុលដោយសំលេង ដីហុយ អាចខ្ទាតកំទេចថ្ម នៅពេលធ្វើការបំបែកថ្មជាដើម

**សំណួរទី៥៖** តើគម្រោងធ្វើអាជីវកម្មរ៉ែទង់ដែងនេះមានផលប៉ះពាល់យ៉ាងដូចម្តេចដល់ប្រាសាទឬស្ពានបុរាណក្នុង និងក្បែរតំបន់គម្រោង?

**ចម្លើយទី៥៖** គម្រោងអាជីវកម្មរ៉ែនេះ ក៏អាចធ្វើឲ្យមានផលប៉ះពាល់ដល់ប្រាសាទ បឹងឈ្នួន (បឹងបុរាណ) ស្ពានតាដៀវដែលជាស្ពានបុរាណស្ថិតនៅក្បែគម្រោងផងដែរ។

**សំណួរទី៦៖** តើក្រុមហ៊ុនគួរតែអនុវត្តន៍នូវវិធានការអ្វីខ្លះ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអតិបរមាពេលកំពុងអនុវតន៍គម្រោង?

**ចម្លើយទី៦៖** ក្រុមហ៊ុនអាចរៀបចំបច្ចេកទេសឲ្យបានសមស្របមួយចំនួនមុននឹងដំណើរការទាញយក និងចម្រាញ់រ៉ែដូចខាងក្រោម៖

- សំណល់រាវៈ ក្រុមហ៊ុនត្រូវរៀបចំជាអាងចំពោះឱ្យច្បាស់លាស់

- សំណល់រឹង៖ ទុកដាក់នៅទីកន្លែងឲ្យបានសមស្រប
- សំលេង៖ កំណត់ពេលវេលាធ្វើការឲ្យបានច្បាស់លាស់
- រំញ័រ៖ ក្រុមហ៊ុនត្រូវមានវិធីសាស្ត្រកាត់បន្ថយ។ លើសពីនេះ ក្រុមហ៊ុនត្រូវរក្សាទុកតំបន់ជីកគាស់យករ៉ែឱ្យបានច្បាស់លាស់ និងត្រូវរក្សាទុកតំបន់ណាដែលមានគម្របព្រៃឈើ។

**សំណួរទី៧៖** តើលោកគាំទ្រ ចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងនេះដែរឬទេ? តើលោកចង់ឱ្យមានការវិនិយោគបែបនេះនៅក្នុងតំបន់ទៀតដែរឬទេ?
**ចម្លើយទី៧៖** បាទ, ខ្ញុំមានការគាំទ្រចំពោះគម្រោងនេះ ប្រសិនបើទទួលផលប្រយោជន៍ពីការវិនិយោគច្រើនជាងផលប៉ះពាល់ចំពោះការអភិវឌ្ឍនៅពេលដែលវាពុំមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើធនធានធម្មជាតិ

**សំណួរទី៨៖** តើលោកមានសំណូមពរ និងអនុសាសន៍យ៉ាងដូចម្តេចខ្លះចំពោះអាជីវកម្មនេះ?
**ចម្លើយទី៨៖** ខ្ញុំមានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖

- សូមស្នើឱ្យរាល់គម្រោងវិនិយោគ គួរតែមានទំនាក់ទំនងល្អជាមួយអ្នកដែលមានការពាក់ព័ន្ធនិងមានការចូលរួមទាំងអស់គ្នា និងមានភាពស្និទស្នាល ដើម្បីធ្វើការងាយស្រួល និងរលូន។
- គួរធ្វើយ៉ាងណាឱ្យមានផលប៉ះពាល់ក្នុងកំរិតទាបបំផុត។
- ផ្តល់ទិន្នន័យឲ្យបានច្បាស់លាស់ពីផលប៉ះពាល់ និងជួយស្វែងរកនូវវិធានការដើម្បីកាត់បន្ថយ និងកែសម្រួល។

### ៦.៤.៣ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប

**លោក មាស ដូរ៉ានី** ប្រធានមន្ទីររ៉ែ និងថាមពល និង **លោក ផន គិរីវុឌ្ឍបាន** មន្ត្រីមន្ទីររ៉ែ និងថាមពលខេត្តសៀមរាបបានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍ជាមួយ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ នៅវេលាម៉ោង២:៣០ ដល់៣:៣០ល្ងាច។ ការជួបសម្ភាសន៍នេះបានភ្ជាប់នូវកម្រងសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់ដែងមួយចំនួនដូចខាងក្រោម៖

**សំណួរទី១៖** តើលោកធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងដែរឬទេ?
**ចម្លើយទី១៖** បាទ, ខ្ញុំក៏ធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងនេះផងដែរ។

**សំណួរទី២៖** តើលោកធ្លាប់ចុះទៅពិនិត្យមើលដោយផ្ទាល់នៅទីតាំងគម្រោងអាជីវកម្មរ៉ែទង់ដែងដែរឬទេ?

**ចម្លើយទី២៖** បាទ, ខ្ញុំធ្លាប់បានចុះទៅពិនិត្យមើលដោយផ្ទាល់នៅទីតាំងគម្រោងអាជីវកម្មរ៉ែទង់ដែង ដល់ការដ្ឋាននៅក្នុងឃុំខ្វាវ។

**សំណួរទី៣៖** តើដំណើរការចម្រាញ់រ៉ែមានតម្រូវការសារធាតុគីមីអ្វីដែរឬទេ? បើមាន តើអ្វីខ្លះ?
**ចម្លើយទី៣៖** តាមលក្ខណៈគីមី គេប្រើប្រាស់អាស៊ីតដើម្បីចម្រាញ់រ៉ែ

**សំណួរទី៤៖** តើវិធានការមានប្រសិទ្ធភាពអ្វីខ្លះដែលត្រូវអនុវត្តន៍ក្រោយបញ្ចប់គម្រោងអាជីវកម្មរ៉ែ ដើម្បីបញ្ចៀសហេតុប៉ះពាល់បរិស្ថានឱ្យនៅកម្រិតអប្បបរមា?
**ចម្លើយទី៤៖** តាមយោបល់របស់ខ្ញុំវិធានការដើម្បីកាត់បន្ថយ និងបញ្ចៀសហេតុប៉ះពាល់បរិស្ថានឱ្យនៅកម្រិតអប្បបរមាមានដូចជា៖

- គួរដាំដើមឈើឡើងវិញ ពេលកាប់ឆ្ការរួច និងគួរសិក្សាពីសត្វព្រៃ
- ធ្វើអាងប្រព្រឹត្តកម្មដើម្បី កាត់បន្ថយផលពីសំណល់រាវ
- គួរតែសិក្សាលើសារធាតុមួយចំនួននៅរោងចក្រដូចជា វិទ្យុសកម្ម។ល។

**សំណួរទី៥៖** តើលោកមានចំណាប់អារម្មណ៍ ឬការព្រួយបារម្ភយ៉ាងណាចំពោះគម្រោងអាជីវកម្មរ៉ែនេះ?
**ចម្លើយទី៥៖** ខ្ញុំក៏មានការព្រួយបារម្ភណ៍មួយចំនួនផងដែរដូចជា ផលប៉ះពាល់ផ្នែកសង្គម បរិស្ថានជីវចំរុះ និងវប្បធម៌។ ឧទាហរណ៍៖ ប្រជាជនធ្លាប់អាស្រ័យអនុផលព្រៃឈើក្នុងតំបន់គម្រោងនោះនឹងរងផលប៉ះពាល់សេដ្ឋកិច្ចក្នុងគ្រួសារគាត់ ពេលដែលអាជីវកម្មរ៉ែទង់ដែងដំណើរការ (ក្រុមហ៊ុនឈូសឆាយអស់ព្រៃ និងការហាមមិនឱ្យពួកគាត់ឆ្លងកាត់ជាដើម)

Draft

**សំណួរទី៦៖** តើលោកគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងនៅជីក្រែងដែរឬទេ? តើលោកចង់ឱ្យមានការអភិវឌ្ឍបែបនេះនៅក្នុងតំបន់ផ្សេងៗទៀតដែរឬទេ?
**ចម្លើយទី៦៖** ខ្ញុំគាំទ្រចំពោះគម្រោងអាជីវកម្មរ៉ែទង់ដែងស្រុកជីក្រែង ព្រោះវាជាគំរូសម្រាប់ក្រុមហ៊ុនដទៃក្នុងការវិនិយោគធ្វើអាជីវកម្មក្នុងប្រទេសយើង ហើយខ្ញុំក៏ចង់ឲ្យមានការអភិវឌ្ឍបែបនេះនៅក្នុងតំបន់ផ្សេងៗទៀតផងដែរ។

**សំណួរទី៧៖** តើលោកមានសំណូមពរ និងអនុសាសន៍យ៉ាងដូចម្តេចខ្លះចំពោះគម្រោងអាជីវកម្មរ៉ែនេះ?
**ចម្លើយទី៧៖** ខ្ញុំមានសំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖

- សូមឱ្យក្រុមហ៊ុនសហការណ៍ជាមួយមន្ទីរពាក់ព័ន្ធឱ្យបានជិតស្និទ និងគ្រប់គ្រាន់តាមប្រព័ន្ធបច្ចេកវិទ្យា
- សូមក្រុមហ៊ុនគោរពតាមអាជ្ញាប័ណ្ណដែលបានទទួល
- សូមក្រុមហ៊ុនផ្តល់របាយការណ៍សមញ្ញ និងវិសមញ្ញដល់មន្ទីរពាក់ព័ន្ធ

- ក្រុមហ៊ុនត្រូវមានអ្នកតំណាង សម្រាប់ធ្វើការទាក់ទងដើម្បីបង្កើនភាពងាយស្រួលក្នុងការផ្តល់ពត៌មានទៅវិញទៅមក។

### ៦.៨.៨ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយអភិបាលស្រុកជីក្រែង

**លោក ពៅ ម៉ុនធឿន** អភិបាលស្រុកជីក្រែង ខេត្តសៀមរាប បានផ្តល់ឱកាសឱ្យក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) ជួបសម្ភាសន៍ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ នៅវេលាម៉ោង២:៣០ ដល់ ៣:៣០ល្ងាច។ ការជួបសម្ភាសន៍នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអាជីវកម្មរ៉ែទង់នៅដែងស្រុកជីក្រែងមួយចំនួន ដូចខាងក្រោម៖

**សំណួរទី១៖** តើលោកធ្លាប់បានជ្រាបពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែងដែរឬទេ?

**ចម្លើយទី១៖** បាទ, ខ្ញុំធ្លាប់បានដឹងពីគម្រោងអាជីវកម្មរ៉ែទង់ដែងនៅស្រុកជីក្រែង។ លើសពីនេះទៅទៀតខ្ញុំក៏ធ្លាប់បានចុះទៅពិនិត្យដល់ការដ្ឋានអាជីវកម្មរ៉ែទង់ដែងនេះដោយផ្ទាល់ផងដែរ

**សំណួរទី២៖** តើក្រុមហ៊ុនម៉េង ស៊ីន ហុង ហ្វា (MENG XIN HONG FA) ធ្វើអាជីវកម្មជីករ៉ែទង់ដែងមានលក្ខណៈយ៉ាងដូចម្តេចដែរ?

**ចម្លើយទី២៖** ការដ្ឋានជីករ៉ែនេះមានលក្ខណៈដូចត្រពាំង ទោះបីជាចង់កែសម្រួលក៏ប្រហែលជាពិបាកផងដែរ

**សំណួរទី៣៖** តើប្រជាជននៅតំបន់នោះ ធ្វើកសិកម្មដូចម្តេច?

**ចម្លើយទី៣៖** ប្រភេទដីតំបន់នោះជាដីចំណោទ និងជាដីព្រៃ ដូច្នេះជាទូទៅប្រជាជនហែកព្រៃធ្វើចំការពនេតចរ។ បច្ចុប្បន្នប្រជាជននៅតែធ្វើស្រែចំការបានដូចធម្មតា ហើយក្រុមនិស្សិតក៏ធ្លាប់ចុះវាស់វែងដីធ្លីទាំងអស់នេះរួចមកហើយផងដែរ។

**សំណួរទី៤៖** តើអាជ្ញាធរមូលដ្ឋានគាំទ្រឬទេ ចំពោះការវិនិយោគធ្វើអាជីវកម្មរ៉ែទង់ដែងនេះ?

**ចម្លើយទី៤៖** អាជ្ញាធរសប្បាយចិត្តចំពោះការអភិវឌ្ឍនេះ ប៉ុន្តែប្រជាជនមួយចំនួនតូចមិនសប្បាយចិត្តឡើយព្រោះគាត់ត្អូញត្អែថា រដ្ឋាភិបាលកំពុងលក់ព្រៃ និងលក់ភ្នំ។ បើទោះជាយ៉ាងនេះក្តីប្រជាជនមួយនៅតែគាំទ្រចំពោះការធ្វើអាជីវកម្មរ៉ែនេះដោយពួកគាត់គិតថា ក្រុមហ៊ុននឹងអាចជួយអភិវឌ្ឍន៍ភូមិឃុំរបស់គាត់ឲ្យមានការរីកចម្រើន។

**សំណួរទី៥៖** តើលោកមានចំណាប់អារម្មណ៍ សំណូមពរ និងអនុសាសន៍អ្វីខ្លះចំពោះការធ្វើអាជីវកម្មរ៉ែនេះ?

**ចម្លើយទី៥៖** ខ្ញុំមានចំណាប់អារម្មណ៍ សំណូមពរ និងអនុសាសន៍មួយចំនួនដូចជា៖

- សូមឱ្យក្រុមហ៊ុនមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានដូចជាភូមិ ឃុំ ស្រុកនិងខេត្ត
- សូមឱ្យក្រុមហ៊ុនផ្តល់របាយការណ៍ស្តីពីដំណើការប្រចាំខែរបស់ខ្លួន